ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# សិក្សាសង្គម

## ភូមិវិទ្យា

៧



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាសង្គម

## ថ្នាក់ទី ៧

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៨៤ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោកស្រី មាស សុក្ខន | លោក មួង សុជាត |
| | លោក ទិត សៀង | លោកស្រី បែន នាង |
| | លោក អេង វ៉ាត | លោកមាស ជុតិមា |
| **អ្នកវាយអត្ថបទ** | លោកស្រី ម៉ក់ វាសនា | |
| **វិចិត្រករ** | លោក ឡុង សុវណ្ណា | |
| **អ្នករៀបរៀង** | លោក រ័ត្ន សារិម (សីលធម៌-ពលរដ្ឋវិជ្ជា) | |
| | លោក លឹម ហ៊ិន (ភូមិវិទ្យា) | |
| | លោក ខាត់ ធី (ប្រវត្តិវិទ្យា) | |
| | លោក គង់ ហាក់ (គេហវិទ្យា) | |
| **អ្នករចនាទំព័រ** | លោក ហាក់ វណ្ណថា | |
| **អ្នកឯកទេស** | លោក ទ្រី ម៉េង | |
| **គណៈកម្មការពិនិត្យ** | លោកស្រី ជិន យ៉ាហាន | លោក ស៊ីវ ធួន |
| | លោក ប៉ុល សារិទ្ធ | លោកស្រី ស្វាយ ធឿម |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ២២១១ អយក.ប្រក. ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ ២០១៨

ISBN 9-789-995-000-820

# អារម្ភកថា

សៀវភៅសិក្សាសង្គមថ្នាក់ទី ៧ នេះ គណៈកម្មការនិពន្ធបានរៀបចំចងក្រងឡើងដោយផ្អែកលើកម្មវិធីសិក្សាថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា។ នៅក្នុងកម្មវិធីសិក្សាថ្មី មុខវិជ្ជាសិក្សាសង្គមមានមុខវិជ្ជារងចំនួនបួន គឺភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌-ពលរដ្ឋវិជ្ជា និងគេហវិទ្យា។

ខ្លឹមសារមេរៀនដែលមាននៅក្នុងសៀវភៅនេះនឹងជួយប្អូនៗឱ្យមានចំណេះដឹងអំពីយេនឌ័រ និងសិទ្ធិមនុស្ស ការបង្កើតចំណងមិត្តភាព ការចូលរួមធ្វើឱ្យគ្រួសារមានសុភមង្គល ដំណើរការនៃការបោះឆ្នោតតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ការកំណត់ជ្រើសរើសអាជីពសម្រាប់ខ្លួនទៅអនាគត ទ្រឹស្តីនៃការអប់រំសំខាន់របស់ព្រះពុទ្ធសាសនា វិជ្ជាធ្វើម្ហូប ការដេរប៉ាក់ ការរក្សាសុវត្ថិភាពនៅក្នុងគេហដ្ឋាន ជីវភាពរស់នៅរបស់ប្រជាជននៃប្រទេសលោកខាងលិច និងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជានាសម័យបុរាណ ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់អាស៊ីពីអតីតកាល នៅតំបន់វាលលិហ តំបន់ប៉ូល តំបន់អេក្វាទ័រ ព្រមទាំងមានបំណិនចេះរៀបចំផែនការនិងរៀបចំចាត់ចែងសកម្មភាពផ្សេងៗ ។

គ្រប់មេរៀនដែលមាននៅក្នុងសៀវភៅនេះ គឺមានទម្រង់ដូចគ្នាទាំងអស់ដូចជា ការកំណត់វត្ថុបំណងនៃមេរៀនសម្រាប់ឱ្យប្អូនៗ ដឹងពីអ្វីដែលនឹងត្រូវសិក្សានៅក្នុងមេរៀននីមួយៗ រូបភាពច្បាស់ល្អ ងាយយល់ទាក់ទងនឹងខ្លឹមសារមេរៀន អត្ថបទមេរៀន ការសង្ខេបមេរៀន សំណួរនៅចុងបញ្ចប់មេរៀន និងនៅចុងបញ្ចប់នៃជំពូកនីមួយៗមានតេស្តបញ្ចប់ជំពូកសម្រាប់វាយតម្លៃលើចំណេះដឹង នៅពេលរៀនចប់ជំពូកនីមួយៗ ។

តាមរយៈខ្លឹមសារមេរៀនដែលមាននៅក្នុងសៀវភៅនេះ ប្អូននឹងទទួលបានចំណេះដឹង បំណិនឥរិយាបថតាមរយៈការសង្កេត ការបញ្ចេញមតិយោបល់ ការពិភាក្សាជាដៃគូឬជាក្រុម ការពិចារណាការស្រាវជ្រាវ ប្រសើរជាងការទន្ទេញមេរៀនចាំមាត់តែមិនយល់ច្បាស់ ។ ម្យ៉ាងទៀតក្នុងការរៀបចំសៀវភៅសិក្សានេះ ក៏មានការចូលរួមផ្តល់យោបល់កែលម្អពីសំណាក់លោកគ្រូអ្នកគ្រូនៅតាមបណ្តាខេត្តក្រុងមួយចំនួនផងដែរ ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅសិក្សាសង្គមថ្នាក់ទី ៧ នេះ នឹងក្លាយជាមិត្តដ៏ល្អរបស់ ប្អូនៗសិស្សានុសិស្សជាក់ជាមិនខាន ។ ទន្ទឹមគ្នានេះដែរ គណៈកម្មការនិពន្ធរីករាយនឹងទទួលយកមតិកែលម្អពីសំណាក់លោកគ្រូ អ្នកគ្រូ និងប្រិយមិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន ។

គណៈកម្មការនិពន្ធ

**ជំពូក 1 ៖ មនុស្សជាច្រើនរស់នៅមជ្ឈដ្ឋានក្ដៅ ( ភូមិវិទ្យា)**
1. ទិដ្ឋភាពទូទៅនៃមជ្ឈដ្ឋានក្ដៅ.......................2
2. មជ្ឈដ្ឋានក្ដៅពិភពកសិករ.......................6
3. ទីក្រុងធំៗក្នុងតំបន់ចន្លោះត្រូពិច.......................10
4. ប្រជាជនកាប់គាស់រានព្រៃអេក្វាទ័រ.......................14
5. កសិករនៅអាស៊ីមូសុង.......................18
6. ការដាំដុះនិងការចិញ្ចឹមសត្វនៅតំបន់វាលស្មោង.......................22
**ជំពូក 2 ៖ មនុស្សតិចតួចរស់នៅមជ្ឈដ្ឋានគាបសង្កត់ពីធម្មជាតិ**
1. ប្រជាជនក្នុងតំបន់វាលលំហាក្ដៅ.......................28
2. ជីវភាពក្នុងអូស៊ីស.......................32
3. អាជីវកម្មធនធានធម្មជាតិតំបន់វាលលំហ.......................36
4. មនុស្សក្នុងមជ្ឈដ្ឋានប៉ូល.......................38
5. ជីវភាពបច្ចុប្បន្នក្នុងតំបន់ប៉ូល.......................42
6. ប៉ូលទាំងពីរជាកន្លែងផ្សងព្រេង.......................46
**ជំពូក 3 ៖ មណ្ឌលអាកាសធាតុកំណត់ដំណុះប្រជាជន**
1. មនុស្សនិងមណ្ឌលអាកាសធាតុ.......................52
2. មនុស្សរៀបចំដែនដីទៅតាមអរិយធម៌របស់ខ្លួន.......................56
3. ប្រៀបធៀបជីវភាពប្រជាជនក្នុងតំបន់ទាំងបី.......................60
**ជំពូក 4 ៖ តើមនុស្សលើភពផែនដីរស់នៅទីណាខ្លះ**
1. កំណើនប្រជាជនពិភពលោក.......................66
2. របាយប្រជាជនពិភពលោក.......................70

# ជំពូកទី 1 មនុស្សជាច្រើនរស់នៅមជ្ឈដ្ឋានក្តៅ



តំបន់ត្រូពិច

តំបន់អេក្វាទ័រ

*ផែនទីបង្ហាញពីតំបន់ត្រូពិច និងតំបន់អេក្វាទ័រ*

ជំពូកនេះ យើងនឹងលើកយកមេរៀនចំនួនប្រាំមួយមកសិក្សា ដើម្បីបង្ហាញឱ្យដឹងថា ៖

តើទេសភាពប្រទេសក្តៅមានលក្ខណៈដូចៗគ្នាដែរឬទេ?

តើមនុស្សភាគច្រើនរស់នៅកន្លែងណាខ្លះ ?

តើការរៀបចំដែលសង្គមមនុស្សបានធ្វើឱ្យសម្រេចឡើងនៅតំបន់ក្តៅមានអ្វីខ្លះ ?

តើសង្គមមនុស្សក្នុងមជ្ឈដ្ឋានក្តៅ រៀបចំទីកន្លែងរស់នៅតាមរបៀបតែមួយឬយ៉ាងណា ?

មេរៀនទី

# 1 ទិដ្ឋភាពទូទៅនៃមជ្ឈដ្ឋានក្ដៅ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាពីទិដ្ឋភាពទូទៅនៃមជ្ឈដ្ឋានក្ដៅ
- ❑ បង្ហាញពីតំបន់អេក្វាទ័រ តំបន់វាលស្មៅ តំបន់វាលស្ពិប និងតំបន់វាលលំហ
- ❑ កំណត់ពីផលប៉ះពាល់ដែលបណ្ដាលមកពីការបាត់បង់ព្រៃឈើ ។

ហេតុអ្វីបានជា គេប្រទះឃើញមានព្រៃស្ដុក និងវាលលំហនៅមជ្ឈដ្ឋានក្ដៅ ?

## 1. តំបន់អេក្វាទ័រ




*ព្រៃអេក្វាទ័រ*

នៅតំបន់អេក្វាទ័រ រុក្ខជាតិដុះលូតលាស់គ្មានឈប់ឈរដោយសារមានភ្លៀងធ្លាក់ស្ទើររាល់ថ្ងៃនិងមានសីតុណ្ហភាពស្ថិតនៅជុំវិញ 25°C ។ តំបន់នេះជាព្រៃស្ដុកដែលបង្កើតបានជាខ្សែក្រវាត់បៃតងអេក្វាទ័រ ។

នៅព្រៃស្ដុកអេក្វាទ័រ មានដើមឈើច្រើនប្រភេទណាស់ដូចជា ឈើខ្មៅ អាកាស៊ូ អូគូមេ ... ដុះជាជាន់ថ្នាក់ មានកម្ពស់ផ្សេងៗពីគ្នាខ្លះដល់ជាង 70m ។ ព្រៃស្ដុកពុំសូវមានសត្វធំៗទេ សម្បូរតែបក្សី

ស្មៅ ល្មួន និងសត្វល្អិត ហើយមានមនុស្សរស់នៅតិចតួច ។ នៅតំបន់អេក្វាទ័រ ដើមឈើនិងវល្លិប្រទាក់គ្នាយ៉ាងញឹក ដែលពិបាកជ្រៀតចូលណាស់ ទោះជាយ៉ាងនេះក៏ដោយ ក៏សព្វថ្ងៃមនុស្សបានសាកល្បងធ្វើសញ្ច័យទៅលើមជ្ឈដ្ឋានដ៏លំបាកនេះហើយ ។

## 2. តំបន់វាលស្មោង

កាលណាគេឃ្លាតឆ្ងាយពីអេក្វាទ័រ ទៅខាងជើងឬខាងត្បូង គេនឹងជួបតំបន់មួយដែលមានរដូវប្រាំង និងរដូវវស្សា ។ ជាបឋមព្រៃស្លុកត្រូវបានជំនួសដោយព្រៃរបោះ ។ ពេលដែលរដូវប្រាំងកាន់តែអូសបន្លាយ ដើមឈើក៏កាន់តែខ្សត់ទៅៗ ។ វាលស្មៅធំល្វឹងល្វើយមួយដែលធន់និងភាពរាំងស្ងួតក៏បង្ហាញរូបរាងឡើងគឺជាតំបន់វាលស្មោង ។ នៅរដូវវស្សា ស្មៅមានកម្ពស់ដល់ 2m ដែលអាចឱ្យពពួកសត្វព្រៃលាក់ខ្លួនបាន ។



*តំបន់វាលស្មោងនៅបៀគីណាផាសូ*

## 3. តំបន់វាលស្តិប និងតំបន់វាលលំហ

បើយើងឃ្លាតជាបន្តទៅទៀតពីអេក្វាទ័រផុតពីវាលស្មោងទៅ យើងជួបតំបន់មួយ ហៅថាវាលស្តិប ។ នៅតំបន់នេះរដូវប្រាំងមានរយៈពេលជាង៩ខែ ។ តំបន់វាលស្តិបសម្បូរស្មៅតែគ្មានដើមឈើទេ ។

វាលលំហ ជាតំបន់ដែលគ្មានរដូវវស្សា គ្មានទឹក គ្មានដើមឈើ មានតែដីខទេ ។ ផ្ទៃដីគ្របដណ្តប់ដោយដុំថ្ម ក្រួស និងខ្សាច់ ។ ពេលថ្ងៃក្តៅខ្លាំង ឯពេលយប់ត្រជាក់ខ្លាំង និងមានខ្យល់បក់យ៉ាងខ្លាំងទៀតផង ។ វាលលំហពោរពេញទៅដោយភាពមិនអនុគ្រោះ ហើយខ្សត់មនុស្សណាស់ ។

សព្វថ្ងៃវាលលំហកំពុងវាតទីទៅលើវាលស្ពិប ដែលស្ថិតនៅក្បែរៗនោះបន្តិចម្តងៗ ដូចជាតំបន់សាហែលនៅភាគខាងត្បូងវាលលំហសាហារ៉ា ដែលអ្នកស្រុកបង្ខំចិត្តបោះបង់ចោលលំនៅស្ថានរបស់គេជាបន្តបន្ទាប់ ។



*តំបន់វាលស្ពិបនៅអាល់សេរី*



*តំបន់វាលលំហ ( សាហារ៉ា)*

*សន្និដ្ឋាន*

នានាភាពនៃទេសភាពធម្មជាតិក្នុងមជ្ឈដ្ឋានក្តៅ មានទំនាក់ទំនងទៅនឹងរយៈពេលវែងឬខ្លីនៃរដូវវស្សា។ តំបន់ព្រៃស្ដុកនិងតំបន់វាលលំហខ្សត់មនុស្សណាស់ ។ តំបន់ត្រូពិចមានរដូវពីរ គឺរដូវប្រាំង និងរដូវវស្សា ជាពិសេសតំបន់ត្រូពិចមូសុងមានមនុស្សរស់នៅកុះករ ។

តាមរយៈមេរៀនខាងលើ យើងជាពលរដ្ឋត្រូវជួយថែរក្សាការពារព្រៃឈើឱ្យបានគង់វង្ស ដើម្បីកុំឱ្យប្រទេសយើងក្លាយជាវាលលំហដូចនៅទ្វីបអាហ្វ្រិក ។

**មេរៀនសង្ខេប**

- តំបន់អេក្វាទ័រ ជាតំបន់ដែលមានសីតុណ្ហភាពស្ថិតនៅជុំវិញ 25°C ហើយមានភ្លៀងធ្លាក់ស្ទើររាល់ថ្ងៃ ។ ព្រៃស្ដុកបង្កើតបានជាខ្សែក្រវាត់បៃតងអេក្វាទ័រ និងមានមនុស្សរស់នៅតិចតួច ។
- តំបន់វាលស្មៅងសម្បូរស្មៅខ្ពស់ៗ មានដើមឈើឯណោះមួយឯណោះមួយ មានរដូវពីរគឺ រដូវប្រាំង និងរដូវវស្សា ។
- តំបន់វាលស្ពិបមានរដូវប្រាំងវែង (៩ខែ) មានសុទ្ធតែស្មៅទាបៗ គ្មានដើមឈើទេ ។
- តំបន់វាលលំហ គ្មានរដូវវស្សា គ្មានទឹក ពេលថ្ងៃក្តៅខ្លាំង ពេលយប់ត្រជាក់ខ្លាំង ។ តំបន់នេះមានមនុស្សរស់នៅតិចតួចណាស់ ។

## សំណួរ

1. តើតំបន់អេក្វាទ័រមានទិដ្ឋភាពទូទៅដូចម្ដេចខ្លះ ?
2. ចូររៀបរាប់ពីទិដ្ឋភាពទូទៅនៃតំបន់វាលស្មៅ ។
3. តើតំបន់វាលស្ដិបស្ថិតនៅត្រង់ណា ? មានលក្ខណៈដូចម្ដេច ?
4. ទិដ្ឋភាពទូទៅនៃតំបន់វាលលំហាមានលក្ខណៈដូចម្ដេច ? ចូរបញ្ជាក់ ។
5. តើសព្វថ្ងៃនេះ តំបន់ព្រៃស្ដុកបានទទួលរងនូវផលប៉ះពាល់ដែរឬទេ ? ចូរបញ្ជាក់ ។
6. តើលក្ខណៈពិសេសតំបន់វាលស្មៅមានអ្វីខ្លះ ?
7. បច្ចុប្បន្នតំបន់វាលលំហាកាន់រួមតូចឬកាន់តែរីកធំ ? តើមានអ្វីដែលគួរឱ្យកត់សម្គាល់ដែរឬទេ ? ចូរបញ្ជាក់ ។
8. តើការធ្វើសញ្ជ័យទៅលើតំបន់ព្រៃស្ដុកនិងនាំមកនូវផលប៉ះពាល់អ្វីខ្លះដល់បរិស្ថានពិភពលោក ?
9. តើការបាត់បង់ព្រៃឈើនៅកម្ពុជានាំមកនូវផលប៉ះពាល់អ្វីខ្លះដល់បរិស្ថានប្រទេសយើង ?
10. ចូរបំពេញតារាងប្រៀបធៀបលក្ខខណ្ឌធម្មជាតិតំបន់អេក្វាទ័រនិងតំបន់ត្រូពិច ៖

| លក្ខខណ្ឌធម្មជាតិ | តំបន់អេក្វាទ័រ | តំបន់ត្រូពិច |
|---|---|---|
| រដូវប្រាំង | | |
| រដូវវស្សា | | |
| រុក្ខជាតិ | | |

*ពន្យល់ពាក្យ*

សញ្ជ័យ : ការវាយដណ្ដើម ។

ខ្សែក្រវាត់បៃតង : ជាពាក្យសំគាល់ព្រៃស្ដុកនៅតំបន់អេក្វាទ័រ ។

មេរៀនទី

# 2 មជ្ឈដ្ឋានក្ដៅពិភពកសិករ

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីជីវភាពកសិករក្នុងមជ្ឈដ្ឋានក្ដៅ
- កំណត់ពីបម្រែបម្រួលជីវភាពរបស់ប្រជាកសិករ
- បណ្ដុះស្មារតីអភិវឌ្ឍកសិកម្ម តាមមូលដ្ឋាន ។

មនុស្សភាគច្រើនក្នុងមជ្ឈដ្ឋានក្ដៅជាកសិករ ប៉ុន្តែជួនកាលពួកគេរងទុក្ខវេទនា ដោយក្ដីអត់ឃ្លាន ។ ហេតុអ្វី ?

## 1. កសិកររស់នៅក្នុងគ្រួសារក្នុងតំបន់ចន្លោះត្រូពិច

មនុស្សជាង 3 000 លាននាក់រស់ក្នុងប្រទេសក្ដៅនៃតំបន់ចន្លោះត្រូពិច ។ អាស៊ីអាគ្នេយ៍ ឥណ្ឌា និងចិន ជាតំបន់ដែលមានប្រជាជនរស់នៅណែនណាន់តាន់តាប់ជាងគេក្នុងពិភពលោក ។

មនុស្សក្នុងមជ្ឈដ្ឋានក្ដៅមិនដែលស្គាល់សិសិររដូវទេ ព្រោះសីតុណ្ហភាពត្រជាក់បំផុតមានត្រឹម 18°C ប៉ុណ្ណោះ ។ កម្ដៅច្រើនអនុគ្រោះខ្លាំងដល់ការងារស្រែចម្ការ ។



*ផ្ទះកសិករប្រទេសកេនយ៉ា*

ស្ទើរគ្រប់ទីកន្លែង កសិកម្មប្រើប្រាស់អស់ជាងពាក់កណ្ដាលនៃប្រជាជនក្នុងតំបន់ក្ដៅ ។ កសិករ រស់នៅក្នុងភូមិ មានផ្ទះសម្បែងសង់ពីសម្ភារៈដែលរកបាននៅនឹងកន្លែង ដូចជា ដីឥដ្ឋ ឬស្សី ឈើ ស្លឹកត្នោត ស្បូវជាដើម ។ ប៉ុន្តែបច្ចុប្បន្នលំនៅស្ថានកសិករបានវិវត្តមួយកម្រិត ផ្ទះភាគច្រើនប្រក់ស័ង្កសី ប្រក់ក្បឿង និងមានទម្រង់ប្រហែលៗគ្នា ។

## 2. បច្ចេកទេសបុរាណក្នុងការបង្កបង្កើនផល

កសិករដាំដំណាំដើម្បីចិញ្ចឹមគ្រួសារ ។ កសិកម្មចិញ្ចឹមពោះនេះ ផលិតជាពិសេសនូវគ្រាប់ធញ្ញជាតិ ។ កសិករភាគច្រើន ធ្វើស្រែចម្ការតាមរបៀបដូនតាពីបុរាណ គឺកសិកម្មប្រពៃណី ។

នៅទ្វីបអាហ្វ្រិក គេធ្វើកសិកម្មដោយប្រើកម្លាំងមនុស្ស និងឧបករណ៍យ៉ាងសាមញ្ញដូចជា ចប ឈើស្រួចសម្រាប់កាប់និងបុកដីដាំដំណាំ ។ នៅទ្វីបអាស៊ី គេប្រើកម្លាំងគោ ក្របីសម្រាប់អូសរទេះ នង្គ័ល រនាស់ ហើយគេប្រើលាមកសត្វសម្រាប់ធ្វើជី ។



*កសិករកម្ពុជាកំពុងភ្ជួរស្រែនិងដកស្ទូង*

## 3. បម្រែបម្រួលជីវភាពក្នុងភូមិ

កសិកម្មតាមប្រពៃណីបានផលតិច ហើយគ្រួសារមួយចំនួនធំក្នុងប្រទេសក្ដៅមានកូនច្រើន ។ ដូចនេះ កសិផលដែលទទួលបាន មិនអាចចិញ្ចឹមគ្រួសារទាំងអស់បានគ្រប់គ្រាន់ទេ ។ ពួកគេគ្មានលទ្ធភាពឱ្យកូនចៅរៀនសូត្របានជ្រៅជ្រះឡើយ ។ ពួកយុវជនចាកចេញពីភូមិទៅកាន់ទីក្រុង ដើម្បីទៅរក

ការងារធ្វើ ។ ទាំងនេះជាបញ្ហាដែលមេគ្រួសារទាំងអស់ត្រូវពិចារណា ក្នុងការកំណត់ចំនួនកូន តម្រូវតាមលទ្ធភាពសេដ្ឋកិច្ចគ្រួសារ ។ នេះក៏ជាបញ្ហាចម្បងមួយ ដែលរដ្ឋាភិបាលប្រទេសនីមួយៗត្រូវយកចិត្តទុកដាក់ដោះស្រាយ ។

ពួកកសិករត្រូវការប្រាក់ទិញរបស់របរពីផ្សារនិងបង់ពន្ធដារ ។ កសិកម្មទីផ្សារផ្ដល់កម្រៃបានច្រើន ។ ជួនកាលដីដាំធញ្ញជាតិប្រែក្លាយទៅជាចម្ការកាកាវឬកាហ្វេវិញ ។ ចំណែកនៅកម្ពុជាយើងកសិករដាំកៅស៊ូ ដំឡូងមី ក្រចៅ ថ្នាំជក់ ហើយបានទទួលប្រាក់កម្រៃជាបង្គួរ ។



*ដំណាំកៅស៊ូនៅខេត្តកំពង់ចាម*

***សន្និដ្ឋាន*** : កសិករមានច្រើនណាស់ក្នុងមជ្ឈដ្ឋានក្ដៅ មិនអាចចិញ្ចឹមគ្រួសារបានដោយងាយស្រួលទេ ព្រោះពួកគេនៅប្រើឧបករណ៍បុរាណក្នុងការបង្កបង្កើនផល ។ ផ្ទុយទៅវិញ ការអនុវត្តកសិកម្មទីផ្សារបានជួយបង្កើនកម្រិតជីវភាពកសិករ តែបញ្ហាកូនច្រើនដែលជាអ្នកតាមហូបនៅតែជាបញ្ហាចំពោះមុខដែលត្រូវដោះស្រាយ ។ ដូចនេះ ដើម្បីធានាជីវភាពបានល្អ គេត្រូវតែអនុវត្តវិធីពន្យារកំណើត ។

## មេរៀនសង្ខេប

- មនុស្សជាង 3 000 លាននាក់រស់នៅក្នុងប្រទេសក្ដៅនៃតំបន់ចន្លោះត្រូពិច ។ នៅអាស៊ីអាគ្នេយ៍ ឥណ្ឌានិងចិន មានប្រជាជនរស់នៅច្រើនជាងគេ ភាគច្រើននៃប្រជាជនទាំងនោះជាកសិករ ។
- បច្ចេកទេសដាំដុះមិនទាន់រីកចម្រើនទេ អនុវត្តតាមរបៀបបុរាណ គឺកសិកម្មប្រពៃណី ។
- បច្ចុប្បន្នកម្រិតជីវភាពមានការរីកចម្រើនជាបណ្ដើរៗ ដោយសារការអនុវត្តកសិកម្មទីផ្សារ ។

## ? សំណួរ

1. តំបន់ណាខ្លះដែលមានមនុស្សរស់នៅកុះករជាងគេក្នុងពិភពលោក ?
2. លក្ខខណ្ឌធម្មជាតិតំបន់ចន្លោះត្រូពិច មានអំណោយផលច្រើនដល់វិស័យកសិកម្ម ។ ចូរពន្យល់អំណះអំណាងនេះ ។
3. នៅតំបន់ចន្លោះត្រូពិច តើកសិករអនុវត្តកសិកម្មបែបណាខ្លះ ?
4. តើកសិកម្មប្រពៃណីតំបន់ចន្លោះត្រូពិចអាចចិញ្ចឹមគ្រួសារបានដែរឬទេ ? ចូរពន្យល់ ។
5. តើគេអាចបង្កើនកម្រិតជីវភាពប្រជាកសិករតំបន់ចន្លោះត្រូពិចបានដោយវិធីណា ?
6. ចូរកំណត់ន័យនៃពាក្យ : កសិកម្មចិញ្ចឹមពោះ កសិកម្មប្រពៃណី កសិកម្មទីផ្សារ ។
7. តើការមានកូនច្រើននាំមកនូវផលវិបាកអ្វីខ្លះ ? ចូរពន្យល់ ។
8. ចលនាចំណាកស្រុករបស់ពួកយុវជនមករកការងារធ្វើនៅទីក្រុងនាំមកនូវផលវិបាកអ្វីខ្លះ ?
9. ចូរបំពេញតារាងប្រៀបធៀបកសិកម្មប្រពៃណីនិងកសិកម្មទីផ្សារ ៖

| ចំណុចប្រៀបធៀប | កសិកម្មប្រពៃណី | កសិកម្មទីផ្សារ |
|---|---|---|
| 1. គោលបំណង | | |
| 2. របៀបដាំដុះ | | |
| 3. ឧបករណ៍ប្រើ | | |
| 4. ទិន្នផល | | |

10. ហេតុអ្វីបានជាកសិករតំបន់ចន្លោះត្រូពិច ជួបប្រទះនិងគ្រោះអត់ឃ្លាន ?
11. យើងសង្កេតឃើញកសិករកម្ពុជាបានយកលាមកគោទៅរាយក្នុងស្រែមុនពេលភ្ជួររាស់ ។ តើអ្នកយល់ដូចម្តេច ចំពោះការប្រើជីបែបនេះ ?
12. តើការរៀបចំផែនការសេដ្ឋកិច្ចគ្រួសារ ជាការចាំបាច់ដែរឬទេ ចំពោះសង្គមកម្ពុជាយើងបច្ចុប្បន្ន ?

***ពន្យល់ពាក្យ***

សិសិររដូវ : រដូវរងាខ្លាំង រដូវត្រជាក់ខ្លាំង ។

ចំណាកស្រុក : ចលនាផ្លាស់ប្តូរទីលំនៅពីកន្លែងមួយទៅកន្លែងថ្មីមួយទៀត ។

មេរៀនទី

# 3 ទីក្រុងធំៗក្នុងតំបន់ចន្លោះត្រូពិច

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីការរីកធំនៃទីក្រុង ទិដ្ឋភាពពីរផ្ទុយគ្នាក្នុងទីក្រុង និងបញ្ហាក្រុង
- ❑ កំណត់ពីមូលហេតុនៃការរីកធំរបស់ទីក្រុង
- ❑ បណ្ដុះស្មារតីរួមចំណែកថែរក្សាសោភណភាពក្រុងឬមូលដ្ឋានរស់នៅ ។

ពិតមែនហើយ នៅក្នុងមជ្ឈដ្ឋានក្ដៅមានមនុស្សចំនួនជាងពាក់កណ្ដាលរស់នៅទីជនបទ ។ ប៉ុន្តែទីក្រុងតំបន់ចន្លោះត្រូពិចរីកធំឡើងលឿនជាងកន្លែងដទៃទៀតក្នុងពិភពលោក ។ ព្រោះហេតុអ្វី ?

## 1. ទីក្រុងកាន់តែរីកធំ



*អគារថ្មីៗកំពុងសាងសង់នៅទីក្រុងភ្នំពេញ*

នៅតំបន់ក្តៅ ការរីកធំនៃទីក្រុងជាបាតុភូតថ្មីដែលទើបកើតឡើងនៅរវាងឆ្នាំ1950 ក្នុងសន្ទុះមួយខ្លាំងក្លាបំផុត ។ កសិករមួយចំនួនចាកចេញពីភូមិទៅនៅទីក្រុងដោយសង្ឃឹមថានឹងមានជីវភាពប្រសើរជាងនៅស្រុកកំណើតរបស់ខ្លួន ។ ចំណោលស្រុកស្រែរបៀបនេះ នាំឱ្យកើតមាននគរូបនីយកម្មមួយគួរជាទីចាប់អារម្មណ៍ ។ ដូចជាទីក្រុងភ្នំពេញ មានប្រជាជនប្រហែល 100 000 នាក់នៅឆ្នាំ1979 សព្វថ្ងៃកើនដល់ 1 325 681 នាក់( 2008 ស្ថិតិបណ្តោះអាសន្នរបស់ក្រសួងផែនការ) ។

ជារៀងរាល់ថ្ងៃ ទីក្រុងបានរីកធំ និងពោរពេញដោយមនុស្សមកពីជនបទ ។ ម៉ិកស៊ិកូជាទីក្រុងមួយដែលមានប្រជាជនច្រើនជាងគេក្នុងពិភពលោក ។ ជារៀងរាល់ថ្ងៃ ទីក្រុងនេះតែងមានអ្នកចំណូលថ្មីជាង 2 000 នាក់បន្ថែមទៀត ។ នៅដំណាច់សតវត្សទី 20 ទីក្រុងម៉ិកស៊ិកូនឹងមានប្រជាជនដល់ទៅ 30 លាននាក់ច្រើនជាងប្រជាជនកម្ពុជាប្រហែលពីរដង( ប្រជាជនកម្ពុជាមាន 13 388 910 នាក់នៅឆ្នាំ 2008 ស្ថិតិបណ្តោះអាសន្នរបស់ក្រសួងផែនការ) ។ នគរូបនីយកម្មនៅមជ្ឈដ្ឋានក្តៅមានសន្ទុះគ្រប់ទីកន្លែង ។ នៅឆ្នាំ2000 ទីក្រុងធំៗស្ទើរតែទាំងអស់នឹងលេចឡើងនៅក្នុងតំបន់ចន្លោះត្រូពិច ។

## 2. សង្កាត់អ្នកមាននិងសង្កាត់អ្នកក្រ

ទីក្រុងរីយ៉ូដឺសាណេរ៉ូនៃប្រទេសប្រេស៊ីល មានទិដ្ឋភាពពីរផ្ទុយគ្នា ។ ទន្ទឹមនឹងអគារទំនើបៗ គេឃើញខ្ទមតូចៗធ្វើអំពីឈើប្រក់ស័ង្កសីច្រែះស៊ីរខេករខាក ហៅថាភូមិអ្នកក្រឬសំណង់អនាធិបតេយ្យ ។

នៅកណ្តាលក្រុងគេឃើញមានសង្កាត់ស្អាតៗ ហាងទំនិញប្រណីតៗ ដែលជាតំបន់អ្នកមានទ្រព្យធនច្រើន ។



*សង្កាត់មួយនៅទីក្រុងមុមបៃ (ឥណ្ឌា)*

នៅតាមបរិវេណក្រុង អ្នកក្រខ្លះសង់ជម្រកដែលរើសពីកន្លែងចាក់សំរាមដូចជា ផ្ទាំងកំណាត់ចាស់ៗឬបំណែកកៅស៊ូ ។ តំបន់សំណង់អនាធិបតេយ្យទាំងនោះគ្មានបណ្តាញទឹកស្អាត អគ្គិសនី បង្គន់លូទឹក និងផ្លូវដើរស្រួលបួលឡើយ ។ ជនខ្លះការងារធ្វើប្រកបមុខរបរកំប៉ិកកំប៉ុកដើម្បីចិញ្ចឹមពោះ ហើយកុមារៗតែងភ្ញាក់ពីព្រលឹមទៅរើសកាកសំណល់អាហារបន្តិចបន្តួចនៅកន្លែងចាក់សំរាមសាធារណៈ ។

## 3. បញ្ហាធ្ងន់ធ្ងររបស់ទីក្រុងនៃប្រទេសកំពុងអភិវឌ្ឍ (តតិយលោក)

ការមកដល់ដ៏សន្ធឹកសន្ធាប់នៃអ្នកជនបទ បង្កការស្មុគស្មាញដល់ទីក្រុងនៃប្រទេសកំពុងអភិវឌ្ឍ ។គេមិនអាចដោះស្រាយលំនៅស្ថានជូនគ្រួសារទាំងនោះបានទេ ។ ទឹក និងខ្យល់ត្រូវរងនូវការបំពុល ។ ទីក្រុងកាន់តែរីកបន្តិចម្តងៗទៅលើដីដាំដុះ ។

ទឹកជាបញ្ហាធ្ងន់ធ្ងរមួយ ។ នៅតាមចន្លោះខ្ទមនៃតំបន់សំណង់អនាធិបតេយ្យ មានថ្លុកទឹកកខ្វក់សំរាម បង្ករោគ ជំងឺឆ្លងផ្សេងៗប៉ះពាល់ដល់សុខភាពប្រជាជន ។ កង្វះទឹកស្អាត ជាផ្នែកមួយនៃជីវភាពប្រចាំថ្ងៃដ៏លំបាកលំបិនក្នុងសំណង់អនាធិបតេយ្យ ។ លើសពីនេះទៅទៀតគេឃើញមានអំពើហិង្សាជារឿយៗ និងពេស្យាចារផងដែរនៅទីនោះ ។

***សន្និដ្ឋាន***៖ ការហូរចូលដ៏សន្ធឹកសន្ធាប់នៃកសិករមកកាន់ទីក្រុងក្នុងមជ្ឈដ្ឋានក្តៅ បង្កើតជាបញ្ហាស្មុគស្មាញចំពោះសង្គម និងនគរូបនីយកម្ម ។ ដូចនេះរដ្ឋាភិបាលត្រូវអភិវឌ្ឍតំបន់ជនបទឱ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយគម្លាតរវាងទីក្រុងនិងជនបទ ។ នេះជាមធ្យោបាយមួយដែលអាចទប់ស្កាត់ចំណោលស្រុកស្រែបាន ។ និយាយរួម បញ្ហាស្ថិតនៅត្រង់ថាធ្វើយ៉ាងណាឱ្យមនុស្សម្នាមានកន្លែងរស់នៅបានសមរម្យ ។

### មេរៀនសង្ខេប

- ក្នុងតំបន់ចន្លោះត្រូពិច មនុស្សជាងពាក់កណ្តាលរស់នៅជនបទ ។ ដោយសារកសិករមួយចំនួនបានចាកចេញពីភូមិមកនៅទីក្រុង នាំឱ្យកើតមាននគរូបនីយកម្មចាប់ពីឆ្នាំ1950 មក ។ ឧទាហរណ៍ ទីក្រុងភ្នំពេញមានប្រជាជនប្រហែល 100 000 នាក់ (1979) បច្ចុប្បន្នកើនដល់ 1 325 681 នាក់(2008) ។
- វិជ្ជភាពផ្ទុយគ្នានៃលំនៅស្ថាន រវាងសង្កាត់អ្នកមាននិងសង្កាត់អ្នកក្រចោទជាខ្លាំងដល់បរិស្ថានទីក្រុង ។

## ? សំណួរ

1. ទីក្រុងម៉ិកស៊ិកូទទួលបានការរីកចម្រើនយ៉ាងដូចម្តេច ?
2. ទិដ្ឋភាពផ្ទុយគ្នានៅក្នុងទីក្រុងរីយ៉ូដឺសានេរ៉ូមានអ្វីខ្លះ?
3. ហេតុអ្វីបានជាមានសំណង់អនាធិបតេយ្យនៅក្នុងទីក្រុងនៃប្រទេសកំពុងអភិវឌ្ឍ ?
4. តើប្រជាជនតំបន់សំណង់អនាធិបតេយ្យមានជីវភាពដូចម្តេច ?
5. តើទីក្រុងទាំងឡាយនៃប្រទេសកំពុងអភិវឌ្ឍជួបនិងបញ្ហាអ្វីខ្លះ ?
6. ហេតុអ្វីបានជាកើតមានបាតុភូតចំណោលស្រុកស្រែ ? តើបាតុភូតនេះនាំមកនូវបញ្ហាអ្វីខ្លះ?
7. ចូរបង្ហាញពីភាពផ្ទុយគ្នារវាងសង្កាត់អ្នកមាននិងសង្កាត់អ្នកក្រ ។
8. ហេតុអ្វីបានជាគេនិយាយថា ទឹកជាបញ្ហាធ្ងន់ធ្ងរមួយរបស់ទីក្រុងនៃប្រទេសកំពុងអភិវឌ្ឍ ?
9. តើគេអាចទប់ស្កាត់ចំណោលស្រុកស្រែបានយ៉ាងដូចម្តេច ?
10. ចូររាប់ចំនួនប្រជាជនក្នុងភូមិអ្នក ដែលចាកចោលស្រុកកំណើតទៅរស់នៅទីក្រុង ។
11. ចូរបំពេញតារាងប្រៀបធៀបតាមចំណុចសំខាន់ៗដូចខាងក្រោម ៖

| ចំណុចសំខាន់ៗ | សង្កាត់អ្នកមាន | សង្កាត់អ្នកក្រ |
|---|---|---|
| លំនៅស្ថាន | | |
| បណ្តាញទឹក ភ្លើង លូ . . . | | |
| ចំណីអាហារ | | |
| ទិដ្ឋភាពទូទៅ | | |

***ពន្យល់ពាក្យ***

ចំណោលស្រុកស្រែ : ចលនាបំលាស់លំនៅនៃប្រជាជនមកកាន់ទីក្រុង ទីប្រជុំជនដោយមិនវិលត្រឡប់វិញ ។

នគរូបនីយកម្ម : ការរៀបចំ និងពង្រីកក្រុង ដើម្បីតម្រូវតាមភាពចាំបាច់នៃដំណើរការរីកចម្រើនផ្នែកសង្គម សេដ្ឋកិច្ច ។

តតិយលោក : លោកទីបី ប្រើសម្រាប់សម្គាល់ក្រុមប្រទេសដែលជាអតីតទឹកដីអាណានិគម ដែលបានទទួលឯករាជ្យ ក្រោយសង្គ្រាមលោកលើកទី2 ហើយបច្ចុប្បន្ននៅមានខ្សឿនសេដ្ឋកិច្ចអន់ថយនៅឡើយ ។

មេរៀនទី

# 4 ប្រជាជនកាប់គាស់រានព្រៃអេក្វាទ័រ

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ការប្រើប្រាស់ដីនៅតំបន់ចន្លោះត្រូពិច
- បង្ហាញពីសកម្មភាពរបស់ប្រជាជនក្នុងតំបន់ចន្លោះត្រូពិច
- កំណត់នូវផលវិបាកដែលបណ្តាលមកពីការបាត់បង់ព្រៃឈើ ។

អគ្គិភ័យធំៗបានចាប់ផ្តើមខម្ទះព្រៃអេក្វាទ័រនៅទ្វីបអាហ្វ្រិច ជាពិសេសនៅអាម៉ាសូនី ប្រទេសប្រេស៊ីល ។ ហេតុអ្វីបានជាគេដុតព្រៃនៅប្រទេសក្តៅ ? តើព្រៃអេក្វាទ័រត្រូវរងនូវការគំរាមកំហែងដែរឬទេ ?

## 1. ការគាស់រានដីតាមបែបប្រពៃណី

ប្រជាជនតំបន់ព្រៃអេក្វាទ័រដុតព្រៃដើម្បីរានទីតាំងលំនៅ និងសម្រាប់ដាំដំណាំក្នុងមជ្ឈដ្ឋានមួយដ៏លំបាក ។ ដីព្រៃដុតក្លាយទៅជាចម្ការនៅជុំវិញភូមិដែលមានឯណោះមួយ ឯណោះមួយ ។ ផេះផ្តល់ជីជាតិដល់ដីដែលគេដាំដំណាំយកមើម ( ដំឡូង ត្រាវ . . . )ធញ្ញជាតិ(ពោត សណ្តែក ស្រូវ. . . ) ។



ភូមិប្រជាជននៅតំបន់អេក្វាទ័រ

ពីរបីឆ្នាំក្រោយមកដីរេចរិលខ្សោះជីជាតិ កសិករក៏បោះបង់ដីចាស់ រើភូមិឋានទៅរស់នៅលើដីព្រៃថ្មីទៀត ដោយប្រើវិធីដុតដដែល ។ ប្រព័ន្ធដាំដុះបែបនេះហៅថាកសិកម្មព្រៃដុត ឬកសិកម្មពនេចរដែលមិនអាចចិញ្ចឹមប្រជាជនបានច្រើនឡើយ តែអាចទុកឱកាសឱ្យព្រៃដុះឡើងវិញបានលើដីចម្ការដែលបោះបង់ ។

## 2. ការដ្ឋានកាប់ព្រៃផ្តល់ភ្លើបារម្ភ

សហគ្រាសធំៗ កាប់ព្រៃយកឈើទៅលក់ឱ្យរោងចក្រ ដោយកាប់តែឈើប្រភេទខ្លះនៅក្នុងព្រៃស្តុក ដូចជា អាកាស៊ូជាឈើដ៏រឹង អូគូមេ ឈើសម្រាប់ធ្វើក្តារបន្ទះ ។ នៅទ្វីបអាហ្វ្រិចអាជីវកម្មឈើប្រព្រឹត្តទៅដោយមានការប្រុងប្រយ័ត្ន ។ គេកាប់ឈើតែពីរឬបីដើមប៉ុណ្ណោះក្នុងមួយហិកតា។ ប៉ុន្តែនៅអាស៊ីអាគ្នេយ៍ ព្រៃឈើត្រូវកាប់បំផ្លាញក្នុងទ្រង់ទ្រាយធំ ដែលឆ្ពោះទៅរកការវិនាសហិនហោចក្នុងអនាគតដ៏ខ្លី ។



*ការកាប់ព្រៃឈើនៅខេត្តរតនគិរី*

## 3. ការគាស់រានដីតាមបែបធំនើប

សព្វថ្ងៃ ការស្ថាបនាផ្លូវគមនាគមន៍ថ្មីបង្កលក្ខណៈងាយស្រួលដល់មនុស្សក្នុងការចូលទៅរុករានព្រៃឈើ ។ ថ្មីៗនេះ គេកាប់បំផ្លាញព្រៃឈើអស់ជាច្រើនលានហិកតា ។ នៅអាម៉ាសូនី កសិករដែលគ្មានដីដាំដុះបានដុតព្រៃនៅអមសងខាងផ្លូវ ដើម្បីរានយកដីដាំដំណាំនិងចិញ្ចឹមសត្វ ។ សំណង់វារីអគ្គិសនី និងអាជីវកម្មរ៉ែ ធ្វើឱ្យព្រៃឈើវិនាសបន្តិចម្តងៗជាបន្តបន្ទាប់ ។

ការកាប់បំផ្លាញព្រៃឈើបែបនេះ ធ្វើឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំង ។ ផលកម្រៃដែលទទួលបានពីអាជីវកម្មនេះមានតិចតួចណាស់ បើធៀបទៅនឹងគ្រោះមហន្តរាយ ដែលកើតមានសព្វថ្ងៃនេះ ។ កាលណាអស់ព្រៃ ដីគ្មានគម្របត្រូវទឹកភ្លៀងហូរច្រោះ ដីបាត់បង់ជីជាតិ កសិករធ្លាក់ក្នុងក្តីអស់សង្ឃឹម ។

ការថយចុះនៃទំហំព្រៃឈើ អាចពិនិត្យលើរូបថត ដែលផ្តល់ដោយផ្កាយរណប ។ ភ្លើងឆេះព្រៃបានបំពុលបរិយាកាសយ៉ាងធ្ងន់ធ្ងរ ។ ការបាត់បង់ព្រៃឈើ គឺបាត់បង់ភ្នាក់ងារសំអាតបរិយាកាស និងបាត់បង់ភ្នាក់ងារផលិតអុកស៊ីសែនសម្រាប់ទ្រទ្រង់ជីវិតមនុស្ស សត្វ នៅលើភពផែនដី ។



*ការកាប់ព្រៃនៅអាម៉ាសូនី (ប្រេស៊ីល)*

***សន្និដ្ឋាន*** : ក្តីព្រួយបារម្ភមានធំធេងណាស់ ខ្សែក្រវាត់បៃតងអេក្វាទ័រកំពុងត្រូវរងការគំរាមកំហែង ។ ព្រៃស្តុកជាមជ្ឈដ្ឋានមួយសម្រាប់ទ្រទ្រង់បរិស្ថានពិភពលោក កសិករក្រីក្រគាស់រានព្រៃដើម្បីរស់តែប៉ុណ្ណោះ ចំណែកនាយទុនធំៗ គាស់រានព្រៃដើម្បីក្លាយខ្លួនជាមហាសេដ្ឋី ។ ព្រៃស្តុកនឹងក្លាយទៅជាវាលរហោឋាននាពេលអនាគតដ៏ខ្លីខាងមុខនេះជាក់ជាមិនខាន បើប្រទេសទាំងអស់ក្នុងលោកមិនបានសហការគ្នាស្រោចស្រង់ផងទេនោះ ។

## មេរៀនសង្ខេប

- នៅតំបន់អេក្វាទ័រ កសិករកាប់គាស់ព្រៃដើម្បីតាំងលំនៅនិងដាំដំណាំផ្សេងៗ ។ នៅទ្វីបអាហ្វ្រិក អាជីវកម្មឈើមានការប្រុងប្រយ័ត្ន ចំណែកនៅអាស៊ីអាគ្នេយ៍ ព្រៃឈើត្រូវគេកាប់បំផ្លាញក្នុងទ្រង់ទ្រាយធំ ។
- កាលណាអស់ព្រៃ ដីគ្មានគម្រប ភ្លៀងហូរច្រោះដីខ្សោះជីជាតិ កសិករនឹងធ្លាក់ក្នុងក្តីអស់សង្ឃឹម ។

## ? សំណួរ

1. តើគេដុតព្រៃអេក្វាទ័រធ្វើអ្វី ? ចូររៀបរាប់ពីទង្វើទាំងនេះ ។
2. តើមានកត្តាសំខាន់ៗអ្វីខ្លះ ដែលនាំឱ្យព្រៃឈើបាត់បង់យ៉ាងឆាប់បែបនេះ ?
3. តើការបាត់បង់ព្រៃឈើនាំមកនូវផលវិបាកអ្វីខ្លះ ?
4. តើទង្វើបែបណាខ្លះ ដែលអាចចាត់ទុកថាជាការគាស់រានដីតាមបែបទំនើប ?
5. តើគេប្រើប្រាស់ដីដោយរបៀបណាខ្លះ នៅតំបន់ចន្លោះត្រូពិច ?
6. កសិកម្មព្រៃដុតមានឈ្មោះម្យ៉ាងទៀតថាកសិកម្មពនេចរ ។ ហេតុអ្វីបានជាមានឈ្មោះពីរដូចនេះ ? ចូរពន្យល់ ។
7. នៅកម្ពុជាគេឃើញមានកសិកម្មព្រៃដុតនេះនៅទីណា ? ចូរបញ្ជាក់ ។
8. "ព្រៃស្ដុកជាមជ្ឈដ្ឋានសំខាន់មួយសម្រាប់ទ្រទ្រង់បរិស្ថានពិភពលោក" ចូរពន្យល់អំណះអំណាងនេះ ។
9. ចូរបំពេញតារាងខាងក្រោម ទៅតាមចំណុចដែលត្រូវបង្ហាញ ៖

| ចំណុចត្រូវលើក | កសិកម្មព្រៃដុត | អាជីវកម្មឈើបែបជំនួញ |
|---|---|---|
| អត្ថប្រយោជន៍ | | |
| អត្ថទោស | | |

***ពន្យល់ពាក្យ***

កសិកម្មព្រៃដុត : វិធីដាំដុះតាមបែបប្រពៃណីម្យ៉ាង ដោយដុតព្រៃយកដីដាំដំណាំ ។ ហៅម្យ៉ាងទៀតថា កសិកម្មពនេចរ ព្រោះកសិកម្មនេះត្រូវប្ដូរទីតាំងជានិច្ចពេលដីខ្សោះជីជាតិ (រយៈពេលប្រហែលបីឆ្នាំ) ។

កសិកម្មពនេចរ : ជាកសិកម្មដែលផ្លាស់ប្ដូរទីតាំងនៅពេលដីខ្សោះជីជាតិក្នុងរយៈពេលពី3ទៅ4ឆ្នាំ ដែលអនុវត្តដោយប្រជាជនតំបន់ព្រៃស្ដុកឬព្រៃរបោះ ។

អាម៉ាសូនី : ឈ្មោះតំបន់មួយនៅអាមេរិកខាងត្បូងដែលគ្របដណ្ដប់ដោយព្រៃស្ដុក (ព្រៃអេក្វាទ័រ) ។ ជាមហាវាលទំនាបមួយនៅទ្វីបអាមេរិកខាងត្បូង លាតសន្ធឹងទៅលើប្រទេសជាច្រើន ជាពិសេសនៅលើប្រទេសប្រេស៊ីល ។

អាម៉ាសូន : ឈ្មោះទន្លេមួយនៅតំបន់អាម៉ាសូនី ។

មេរៀនទី

# 5 កសិករនៅអាស៊ីមូសុង

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីសកម្មភាពការងាររបស់កសិករអាស៊ីមូសុង
- ❑ បង្ហាញពីសារៈសំខាន់ការងារស្រែចម្ការនៅអាស៊ីមូសុង
- ❑ កំណត់ពីបម្រែបម្រួលជីវភាពរបស់កសិករ ។

ជនបទអាស៊ីមូសុង មានដង់ស៊ីតេប្រជាជនដល់ 1 000 នាក់ /km$^2$ ។ មនុស្សប្រមូលផ្តុំគ្នារស់នៅយ៉ាងកុះករក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ចំណែកនៅតំបន់ចន្លោះត្រូពិចផ្សេងៗទៀតមានមនុស្សរស់នៅតិច ហើយកន្លែងខ្លះទៀតជាវាលលំហ ។ ហេតុអ្វីបានជាអាស៊ីមូសុងមានដង់ស៊ីតេប្រជាជនខ្ពស់ ?

## 1. ភ្លៀងមូសុងអនុគ្រោះដល់ជីវភាព

រដូវប្រាំងមួយដ៏វែងបានកន្លងផុតទៅ ភ្លៀងក៏ចាប់ធ្លាក់ស្រោចស្រពមកលើអាស៊ីអាគ្នេយ៍ចាប់ពីខែឧសភាដល់ខែតុលា គឺភ្លៀងមូសុងវស្សា ។ ខ្យល់ពីនិរតីបក់មកពីមហាសមុទ្រឥណ្ឌា ផ្ទុកដោយចំហាយទឹកច្រើននាំមកនូវទឹកភ្លៀងដ៏សន្សឹកសន្សាប់ អនុគ្រោះខ្លាំងដល់ដំណាំស្រូវ ។



*កសិករកម្ពុជាកំពុងស្ទូងស្រូវ*

## 2. ការធ្វើស្រែចម្ការដ៏លំបាកលំបិន



*ស្រែថ្នាក់ៗនៅឥណ្ឌូណេស៊ី*

នៅចុងរដូវប្រាំង កសិកររៀបចំដីថ្មី ។ ភ្លៀងដំបូងចាប់ផ្ដើមធ្លាក់ ពូជស្រូវដែលសាបព្រោះក៏ចេញពន្លក ។ កសិករភ្ជួររាស់ដី សំអាតដីជាបណ្ដើរៗ ។ ពេលមានភ្លៀងធ្លាក់ទឹកដក់ក្នុងស្រែ កសិករដកសំណាបយកទៅស្ទូង ។

ស្រូវត្រូវការទឹកជាប្រចាំរហូតដល់ទុំ ។ ដូចនេះ ដើម្បីរក្សាទឹកទុកតាមតម្រូវការ កសិករត្រូវធ្វើដីស្រែឱ្យរាបស្មើ ធ្វើភ្លឺឱ្យជិតល្អ ហើយមាំ ។ នៅតំបន់វាលរាប ស្រែមានរាងជាក្រឡាចត្រង្គ ។ ស្រែមានពណ៌បៃតង រួចប្រែទៅជាកម្រាលពណ៌មាស( ស្រូវទុំ) ។ ពេលស្រូវទុំ កសិករនាំគ្នាច្រូតកាត់ដោយកណ្ដៀវ ចងជាកណ្ដាប់ រួចនាំយកទៅបោកឬបញ្ជាន់ ។ នៅតំបន់ភ្នំ កសិកររៀបចំដីធ្លី តាមជម្រាលជាថ្នាក់ៗ ហៅថាស្រែថ្នាក់ ។

ដំណាំស្រូវផ្ដល់ផលច្រើន កាលណាមានការថែទាំល្អនិងការប្រើប្រាស់ជីបានត្រឹមត្រូវ ។ ដំណាំស្រូវតាមបែបប្រពៃណីដូចគ្នានិងដំណាំច្បារដែរ ។ កសិករមានពេលទំនេរតិចណាស់ ពិសេសក្នុងតំបន់ដែលមានបំណាចបញ្ចូលទឹក អាចឱ្យគេធ្វើស្រែបានពីរឬបីដងក្នុងមួយឆ្នាំ ។

## ៣. ស្រូវចិញ្ចឹមប្រជាជនបានមួយភាគបីនៅលើផែនដី

ស្រូវជាដំណាំស្បៀងចាំបាច់នៅអាស៊ីមូសុង ។ ប្រជាជនជាង 2 000 លាននាក់យកស្រូវធ្វើជាអាហារប្រចាំថ្ងៃរបស់គេ ។

កាលពីមុនប្រជាជនអាស៊ីមូសុង ជួបប្រទះនិងការបរិភោគមិនគ្រប់គ្រាន់ ។ បច្ចុប្បន្ននេះ ពួកគេលែងជួបនិងគ្រោះទុរ្ភិក្សទៀតហើយ ព្រោះផលិតផលស្រូវកើនឡើងដោយសារការជ្រើសរើសពូជស្រូវដែលផ្ដល់ទិន្នផលខ្ពស់ ការប្រើប្រាស់ជី និងចេះធ្វើប្រព័ន្ធធារាសាស្ត្រ ។ ទោះបីឆ្នាំខ្លះ មានភ្លៀងធ្លាក់មិនគ្រប់គ្រាន់ឬធ្លាក់យឺតពេលក៏ដោយ ក៏ពួកគេនៅមានស្រូវបម្រុងទុកក្នុងជង្រុកដែរ ។

*សន្និដ្ឋាន*

ភាពសម្បូរភ្លៀងមូសុងអាចឱ្យដំណាំស្រូវទទួលបានផលច្រើន និងអាចចិញ្ចឹមប្រជាជនបានសន្ធឹកសន្ធាប់ ។ សព្វថ្ងៃដំណាំស្រូវមានការរីកចម្រើន តែការរីកចម្រើននេះមិនបានស្មើគ្នាគ្រប់តំបន់ទេ ។ ប្រជាជនមួយចំនួននៅខ្វះខាតស្បៀងនៅឡើយ ។ តាមបទពិសោធបង្ហាញថា មានតែការដាំដុះដំណាំស្រូវតាមបែបអតិផលទេ ទើបអាចចិញ្ចឹមប្រជាពលរដ្ឋបានគ្រប់គ្រាន់ ។

**មេរៀនសង្ខេប**

- ជនបទអាស៊ីមូសុងមានដង់ស៊ីតេប្រជាជនខ្ពស់ ។ អាស៊ីអាគ្នេយ៍មានប្រជាជនរស់នៅប្រជ្រៀតគ្នា ព្រោះជាតំបន់ដែលអនុគ្រោះដល់វិស័យកសិកម្ម ។
- កសិករអាស៊ីមូសុងបានបំពេញការងារធ្វើស្រែយ៉ាងហ្មត់ចត់ ព្រោះស្រូវជាស្បៀងអាហារចាំបាច់របស់ពួកគេ ។
- ភ្លៀងមូសុងវស្សាធ្វើឱ្យស្រូវដុះលូតលាស់ល្អ ដែលអាចចិញ្ចឹមប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់បាន ។ ដំណាំស្រូវផ្ដល់ផលច្រើនដោយសារមានការថែទាំល្អ ការប្រើប្រាស់ជី និងការជ្រើសរើសពូជស្រូវបានត្រឹមត្រូវ ។
- កសិករមានពេលទំនេរតិចណាស់ ពិសេសក្នុងតំបន់ដែលមានបំណាចបញ្ចូលទឹក ដែលឱ្យគេធ្វើស្រែបានពីរឬបីដងក្នុងមួយឆ្នាំ ។

## ? សំណួរ

1. អ្វីទៅដែលហៅថាមូសុងវស្សា ? តើមូសុងវស្សាមានសារៈសំខាន់អ្វីខ្លះ ?
2. នៅតំបន់វាលរាប ស្រែមានរាងដូចម្ដេច ? ចំណែកនៅតំបន់ភ្នំ ស្រែមានរាងបែបណាដែរ ?
3. ដើម្បីទទួលបានផលស្រូវច្រើន តើកសិករអាស៊ីមូសុងបានធ្វើអ្វីខ្លះ ? ចូរបញ្ជាក់ ។
4. បច្ចុប្បន្ន តើប្រជាជនអាស៊ីមូសុងជួបនឹងគ្រោះទុរ្ភិក្សដែរឬទេ ? ព្រោះអ្វី ?
5. " ភ្លៀងមូសុងអនុគ្រោះដល់ជីវភាព" ។ ចូរពន្យល់អំណះអំណាងនេះ ។
6. នៅអាស៊ីមូសុងការងារស្រែចម្ការជាការងារលំបាកលំបិន ។ ចូរពន្យល់ ។ តើគេអាចកាត់បន្ថយភាពលំបាកនេះបានដោយវិធីណា ?
7. ចូរនិយាយពីសារៈសំខាន់នៃដំណាំស្រូវនៅអាស៊ីមូសុង ។
8. ចូររៀបពាក្យខាងក្រោមឱ្យទៅជាល្បះដែលមានន័យគ្រប់គ្រាន់ ។
   - ក. ប្រជាជន ចាំបាច់ ស្រូវ របស់ ដំណាំ យើង អាហារ ជា ។
   - ខ. ទឹក ដំណាំ ច្រើន ត្រូវការ ជា ស្រូវ ។
   - គ. ចិញ្ចឹម ស្រូវ បាន ប្រជាជន សន្ធឹកសន្ធាប់ ច្រើន ។
9. នៅប្រទេសកម្ពុជាយើង គេពុំប្រទះឃើញមានស្រែថ្នាក់ដូចនៅឥណ្ឌូណេស៊ីឬហ្វីលីពីនឡើយ ។ ព្រោះអ្វី ?
10. ចូរសរសេរពីរបៀបធ្វើស្រែនៅមូលដ្ឋានអ្នក ( ដប់បន្ទាត់យ៉ាងច្រើន) ។

***ពន្យល់ពាក្យ***

ដំណាំច្បារ : ដំណាំដែលគេដាំក្នុងសួនជុំវិញផ្ទះ មានការថែទាំយ៉ាងហ្មត់ចត់ ។

អាស៊ីមូសុង : ជាតំបន់មួយក្នុងពិភពលោកដែលទទួលឥទ្ធិពលខ្យល់មូសុង រួមមានអាស៊ីទក្សិណ អាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា ។

មូសុងវស្សា : ខ្យល់រដូវបក់មកពីមហាសមុទ្រឥណ្ឌា ពីខែឧសភាទៅខែតុលា ជាខ្យល់សមុទ្រផ្ទុកដោយចំហាយទឹកច្រើន នាំមកនូវទឹកភ្លៀងដ៏ច្រើនសន្ធឹកសន្ធាប់ ។

ក្រឡាចត្រង្គ : ក្រឡាបួនៗជ្រុង ដូចក្រឡាវែកឬក្រឡាអុក ។

ស្រែថ្នាក់ : រាងធរណីមាត្រនៃដីស្រែចម្ការនៅតាមជម្រាលភ្នំ មានសណ្ឋានដូចកាំជណ្ដើរជាថ្នាក់ៗ ។

ទុរ្ភិក្ស : ដំណើរអត់បាយឬអត់ឃ្លាន ។

# 6 ការដាំដុះនិងការចិញ្ចឹមសត្វនៅតំបន់វាលស្មៅ

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីជីវភាពរស់នៅរបស់ប្រជាជនតំបន់វាលស្មៅ
- ❑ កំណត់ពីបញ្ហាដែលប្រជាជនប្រឈមនិងគ្រោះថ្នាក់
- ❑ ចេះដោះស្រាយបញ្ហាជីវភាពប្រចាំថ្ងៃបានសមស្រប ។

ជាច្រើនសតវត្សមកហើយ កសិករតំបន់វាលស្មៅនៃទ្វីបអាហ្វ្រិច បានរស់នៅដោយមានទំនាក់ទំនងល្អជាមួយមជ្ឈដ្ឋានរបស់ខ្លួន ទោះជានៅរដូវប្រាំងក៏ដោយ ។ សព្វថ្ងៃ គ្រោះមហន្តរាយធ្វើឱ្យជីវិតមនុស្សស្ថិតក្នុងគ្រោះថ្នាក់ ។ ព្រោះអ្វី ?

## 1. ប្រពៃណីតំបន់វាលស្មៅទ្វីបអាហ្វ្រិច

កសិករនិយមដាំដំណាំលើដីព្រៃដុត ។ ការដុតព្រៃផ្តល់ផលចំណេញពីរយ៉ាងគឺ បានដីដាំដំណាំ និងបានស្មៅខ្ចីសម្រាប់ចិញ្ចឹមសត្វផង ។



*ភូមិមួយនៅតំបន់វាលស្មៅ*

ពហុវប្បកម្មបង្កើតបានជាទេសភាពប្លែកៗ រាងដូចរង្វង់រស្មីនៅជុំវិញភូមិ ។ នៅក្នុងសួនជុំវិញផ្ទះ ស្រីៗដាំបន្លែ និងឈើហូបផ្លែចម្រុះគ្នា ។ នៅឯនាយ ប្រុសៗដាំធញ្ញជាតិ ដូចជា–មីល មីយេ និងស័រគូ សម្រាប់ចិញ្ចឹមជីវិត ។ ដីខ្លះទុកទំនេរ ដើម្បីបង្កើនគុណភាពឡើងវិញ ។ នៅកណ្តាលភូមិមាន

ផង្រុកធញ្ញជាតិជាច្រើន ។ កាលណាគេមិនទៅបរបាញ់ឬមិនទៅចម្ការទេ ពួកប្រុសៗតែងជជែកគ្នាលេងក្រោមដើមឈើចំណែកស្រីៗរៀបចំម្ហូបអាហារ ទៅរកទឹក និងអុស ។

អ្នកចិញ្ចឹមសត្វមានមោទនភាពនឹងហ្វូងសត្វរបស់គេណាស់ ។ ពួកគេឃ្វាលសត្វដោយផ្លាស់ទី ពីវាលស្មៅមួយទៅវាលស្មៅមួយទៀត ដែលមានពណ៌បៃតង ដោយសារការដុតព្រៃ និងទឹកភ្លៀង ។



*ចរកជនចិញ្ចឹមសត្វនៅសាហារ៉ា ( ប្រទេសនីហ្សេ)*

## 2. មនុស្សនិងវាលស្មៅស្ថិតក្នុងគ្រោះថ្នាក់

ពីរបីទសវត្សរ៍កន្លងមកនេះ ប្រជាជននៅតំបន់វាលស្មៅមានការកើនឡើងឥតឈប់ឈរ ។ ដើម្បីចិញ្ចឹមមនុស្សដ៏ច្រើននេះ កសិករត្រូវខិតខំដាំដំណាំឲ្យឡើងលើដីទំនេរ ។ ដោយមិនប្រើជី ដីក៏ខ្វះគុណភាព ការប្រមូលផលក៏ថយចុះដែរ ។ អាជីវកម្មហួសហេតុបែបនេះ ធ្វើឱ្យខូចមជ្ឈដ្ឋានយ៉ាងឆាប់រហ័ស ។



*ហ្វូងសត្វស្លាប់នៅសាហែលជាយខាងត្បូងសាហារ៉ា (1973)*

ដើមឈើដែលរងគ្រោះដោយសារភ្លើង និងការកាប់យកអុសចម្អិនអាហារបានបាត់បង់បន្តិចម្តងៗពីវាលស្មោង ។ ដីគ្មានគម្របធម្មជាតិឡើងរឹងក្តាំងផ្តល់ឱកាសឱ្យវាលលំហាទន្ទ្រានទៅលើវាលស្មោងកាន់តែខ្លាំង ។ កសិករបោះបង់ចោលភូមិ ចលនានេះហៅថា ចំណោលស្រុកស្រែ ។ គ្មានទឹកគ្មានស្មៅសត្វស្លាប់ជារៀងរាល់ថ្ងៃ កសិករដាច់ចិត្តចាកចោលទីកន្លែងដែលធ្លាប់រស់នៅជាបន្តបន្ទាប់ដោយក្តីអស់សង្ឃឹម ។

## ៣. អ្នកវាលស្មោងប្រយុទ្ធដើម្បីស្រោចស្រង់មជ្ឈដ្ឋានរស់នៅ

ដើម្បីទប់ទល់នឹងការទន្ទ្រាននៃវាលលំហ អ្នកវាលស្មោងសាកល្បងការពារមជ្ឈដ្ឋានរស់នៅរបស់គេ ដោយការដាំដើមឈើឡើងវិញ ។ គេបានដោះស្រាយបញ្ហាទឹក ដោយជីកអណ្តូង ប្រឡាយ ឬបូមទឹកពីស្ទឹងនិងព្រែកជិតៗ ដើម្បីបង្កើនផលិតផលកសិកម្ម ។



*ការបូមទឹកនៅប្រទេសសេណេហ្គាល់*

### *សន្និដ្ឋាន*

ពហុវប្បកម្មប្រពៃណីរបស់អ្នកវាលស្មោងនៅទ្វីបអាហ្វ្រិក មិនអាចធានាចិញ្ចឹមប្រជាជនដែលចេះតែកើនឡើងឥតឈប់ឈរបានទេ ។ ការធ្វើអាជីកម្មហួសហេតុ ធ្វើឱ្យមានគ្រោះថ្នាក់ដល់មជ្ឈដ្ឋានដីងាយប្រេះស្រាំនេះ ។ សព្វថ្ងៃក្រុមកសិករខ្លះ បានសាកល្បងប្រយុទ្ធប្រឆាំងនិងការទន្ទ្រាននៃវាលលំហាមកលើវាលស្មោងដោយការដាំដើមឈើនិងការពារសំណឹកដីដោយយកដុំថ្មមករៀបជាជួរ ។

ទោះបីធ្វើអាជីវកម្មបែបណាក៏ដោយ យើងជាពលរដ្ឋត្រូវគិតពីផលប៉ះពាល់ដល់មជ្ឈដ្ឋានធម្មជាតិផងដែរ ។

## មេរៀនសង្ខេប

- ពហុវប្បកម្មប្រពៃណីរបស់កសិករវាលស្មៅងទ្វីបអាហ្វ្រិកមិនអាចបានចិញ្ចឹមប្រជាជនដែលកើនឥតឈប់ឈរបានទេ ។
- ការធ្វើអាជីវកម្មហួសហេតុ ដីអស់តម្របចម្មជាតិ បណ្ដាលឱ្យវាលលំហាទន្ទ្រានកាន់តែខ្លាំងមកលើវាលស្មៅង ។
- សព្វថ្ងៃកសិករសាកល្បងការពារមជ្ឈដ្ឋានរស់នៅរបស់ខ្លួនដោយដាំដើមឈើឡើងវិញ ។ គេជីកអណ្ដូងប្រឡាយ បូមទឹកពីស្ទឹង និងព្រែកដែលនៅជិតៗ ដើម្បីបង្កើនផលិតផលកសិកម្ម ។

## សំណួរ

1. តើការដុតព្រៃ នៅតំបន់វាលស្មៅងផ្ដល់អត្ថប្រយោជន៍អ្វីខ្លះ ?
2. ចូររៀបរាប់ពីពហុវប្បកម្មនៅតំបន់វាលស្មៅងនៃទ្វីបអាហ្វ្រិក ។
3. ហេតុអ្វីបានជាប្រជាជនតំបន់វាលស្មៅងត្រូវប្រឈមនឹងគ្រោះថ្នាក់ ?
4. ដើម្បីការពារមជ្ឈដ្ឋានរស់នៅ តើអ្នកវាលស្មៅងបានធ្វើអ្វីខ្លះ ?
5. តើការរស់នៅតាមបែបប្រពៃណីរបស់អ្នកវាលស្មៅងទ្វីបអាហ្វ្រិកមានលក្ខណៈដូចម្ដេច ?
6. តើការដុតព្រៃ ដើម្បីយកដីធ្វើអាជីវកម្មរបស់អ្នកវាលស្មៅងនាំមកនូវផលវិបាកអ្វីខ្លះ ?
7. ហេតុអ្វីបានជាវាលលំហអាចទន្ទ្រានទៅលើតំបន់វាលស្មៅង ?
8. ចូររៀបពាក្យខាងក្រោមឱ្យទៅជាល្បះមួយមានន័យត្រឹមត្រូវ ៖

   ទេ កាលណា សត្វ ទឹក ចិញ្ចឹម គ្មាន គេ បាន ស្មៅ មិន គ្មាន អាច និង ។
9. នៅប្រទេសកម្ពុជាយើង ក៏មានការដុតព្រៃយកដីដាំដុះដែរ ។ តើកសិកម្មប្រភេទនេះមានឈ្មោះដូចម្ដេច ? ផ្ដល់ផលវិបាកអ្វីខ្លះ ?

***ពន្យល់ពាក្យ***

ពហុវប្បកម្ម : វិធីដាំដុះដំណាំច្រើនមុខនៅលើដីតែមួយ ។

វង់រស្មី : វង់ពន្លឺដូចជា ឆព្វណ្ណរង្សីជាដើម ។ ក្នុងន័យនេះបានដល់ទេសភាពចម្ការដំណាំ ដែលសណ្ដូកជាខ្សែៗនៅជុំវិញភូមិមើលទៅឃើញដូចវង់នៃខ្សែកាំរស្មីដែរ ។

ការងារបញ្ចូលទឹក : ការនាំទឹកទៅស្រោចស្រពដំណាំ មានតាំងពីការជីកអណ្ដូង ស្រះ ប្រឡាយ លើកភ្លឺសាងសង់ទំនប់ទឹក អាងទឹក រហូតដល់ប្រើប្រាស់ឧបករណ៍បំណាច (រហាត់ទឹក ម៉ាស៊ីនបូមទឹក...) ។

## ? សំណួរជំពូក1

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវតែមួយគត់ ៖**

1 តំបន់ដែលមានស្មៅដុះខ្ពស់ៗ ហើយមានដើមឈើឯណោះមួយ ឯណោះមួយហៅថា ៖

☐ក. អូស៊ីស ☐ខ. វាលស្ពិប

☐គ. សែរ៉ែក ☐ឃ. វាលស្មៅ

2. រីយ៉ូដឺសានេរ៉ូជាទីក្រុងមួយរបស់ប្រទេស ៖

☐ក. អាហ្សង់ទីន ☐ខ. ប្រេស៊ីល ☐គ. អេហ្ស៊ីប ☐ឃ. អាល់ហ្សេរី

**II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ :**

1. សិសិររដូវគ្មានវត្តមាននៅក្នុង .......... ទេ។

2. សហគ្រាសធំៗកាប់ព្រៃឈើក្នុងបំណង .......... ។

**III ចូរផ្គូផ្គងផ្នែកA និងB រួចសរសេរចម្លើយក្នុងផ្នែកC ឱ្យបានត្រឹមត្រូវ ៖**

| A( តំបន់អាកាសធាតុ) | B( ដំណាំនិងរុក្ខជាតិ) | C( ចម្លើយ) |
|---|---|---|
| 1. តំបន់អេក្វាទ័រ | ក. ដំណាំស្រូវ | 1. ⟶ ...... |
| 2. តំបន់ត្រូពិចមូសុង | ខ. ដំណាំស្រូវសាលី | 2. ⟶ ..... |
| 3. តំបន់ត្រូពិចស្ងួត | គ. ព្រៃស្ពុក | 3. ⟶ ..... |
| | ឃ. ដំណាំមីល មីយេ និងស័រគូ | |

**IV ចូរឆ្លើយសំណួរខាងក្រោម ៖**

1. យោលទៅតាមលក្ខណៈអាកាសធាតុ តើមជ្ឈដ្ឋានក្តៅអាចចែកចេញជាប៉ុន្មានផ្នែក ? អ្វីខ្លះ ? ចូរនិយាយដោយសង្ខេបអំពីលក្ខណៈទូទៅនៃផ្នែកនីមួយៗ ។

2. ចូរកំណត់ន័យនៃពាក្យចំណោលស្រុកស្រែ ។ ហេតុអ្វីបានជាកើតមានបាតុភូតចំណោលស្រុកស្រែ ? តើគេអាចទប់ស្កាត់បាតុភូតនេះបានដោយមធ្យោបាយណា ?

3. តើអាម៉ាសូនីជាអ្វី ? តើអាម៉ាសូនីកំពុងត្រូវរងនូវការគំរាមកំហែងដូចម្តេចខ្លះ ? នាពេលអនាគត តើអាម៉ាសូនីនឹងក្លាយទៅជាយ៉ាងណា ?

# ជំពូកទី 2 មនុស្សតិចតួចរស់នៅមជ្ឈដ្ឋានតាបសង្កត់ពីធម្មជាតិ

*ផែនទីបង្ហាញពីតំបន់ប៉ូលនិងតំបន់វាលលំហ*




ជាបន្តទៅនេះ អ្នកនឹងបានសិក្សាមេរៀនមួយចំនួនទៀត ស្ដីពីគំនាបសង្កត់នៃមជ្ឈដ្ឋានធម្មជាតិមកលើការរស់នៅរបស់មនុស្ស ដើម្បីបង្ហាញឱ្យដឹងថា ៖

តើពួកគេរស់នៅក្នុងពិភពមួយខ្វះទឹកនិងពិភពមួយទៀតដែលសុទ្ធតែទឹកកក បានដោយរបៀបណា ?

តើលក្ខខណ្ឌជីវភាពរបស់ពួកគេបានទទួលកំណែប្រែដែរឬទេ ?

# 1 ប្រជាជនក្នុងតំបន់វាលលំហក្តៅ

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីលក្ខណធម្មជាតិតំបន់វាលលំហក្តៅ
- រៀបរាប់ពីជីវភាពរស់នៅរបស់ប្រជាជនតំបន់វាលលំហក្តៅ
- បង្ហាញពីបំលាស់ប្តូរជីវភាពចរកជន ។

កាលណាគ្មានទឹកគេមិនអាចដាំដំណាំឬចិញ្ចឹមសត្វបានទេ ។ ប៉ុន្តែតំបន់វាលលំហាមិនមែនសុទ្ធតែគ្មានមនុស្សរស់នៅនោះឡើយ ។ តើគេអាចរស់នៅក្នុងពិភពមួយស្ងួតហួតហែងនិងក្តៅខ្លាំងបានដោយរបៀបណា ?

## 1. លក្ខណធម្មជាតិ និងជីវភាពប្រជាជន




*ផែនទីវាលលំហពិភពលោក*

តំបន់វាលលំហក្តៅ ជាមណ្ឌលអាកាសធាតុពិសេសមួយនៃភពផែនដី ដែលមានទីតាំងនៅតាមបណ្តោយខ្សែត្រូពិច ។ សាហារ៉ា ជាវាលលំហធំជាងគេនៅទ្វីបអាហ្វ្រិក និងនៅក្នុងពិភពលោក ។ វាលលំហកាឡាហារី និងណាមីបស្ថិតនៅភាគខាងត្បូងនៃទ្វីបអាហ្វ្រិក ។ ចំណែកទ្វីបអាស៊ី មានវាលលំហជាច្រើន ដូចជាវាលលំហអារ៉ាប៊ី វាលលំហអ៊ីរ៉ង់ វាលលំហថារ វាលលំហតួគីស្ថាន និងវាលលំហកូប៊ី ។ ក្រៅពីនេះមាន វាលលំហម៉ូចេវនៅភាគនិរតីសហរដ្ឋអាមេរិក វាលលំហអាតាកាម៉ា នៅភាគខាងជើងប្រទេសស៊ីលី និងវាលលំហអូស្ត្រាលី ។

តំបន់វាលលំហទាំងនោះ មានភ្លៀងធ្លាក់តិចតួចណាស់ ( តិចជាង 250mm ក្នុងមួយឆ្នាំ ) ហើយនៅកន្លែងខ្លះពុំមានភ្លៀងធ្លាក់សោះអស់ពេលជាច្រើនឆ្នាំជាប់ៗគ្នា ។ ពេលថ្ងៃ ក្តៅស្ទើរឆេះ ( 50°C នៅក្នុងជម្រក និង 70°C ទៅ 80°C នៅកណ្តាលវាល) ។ ពេលយប់ត្រជាក់ដូចទឹកកក ( 0°C ) ។ បម្រែបម្រួលសីតុណ្ហភាពឆាប់រហ័សបែបនេះ នាំឱ្យសិលាងាយប្រេះស្រាំបាក់បែកជាដុំថ្ម កម្ទេចកម្ទីថ្មក្រួសនិងខ្សាច់ ហៅថា រ៉ិច ( Reg ) ។ ខ្យល់បោកបក់មកលើរ៉ិចនាំយកខ្សាច់ទៅជាមួយ បង្កើតបានជាផ្នូកខ្សាច់ធំៗដូចរលកទឹកសមុទ្រ ហៅថា អ៊ែក ( Erg ) ។ ភ្លៀងព្យុះកើតមានម្តងម្កាលក្នុងរយៈពេលខ្លី ធ្វើឱ្យ វើត(oued ផ្លូវទឹក) ទាំងឡាយជោរជន់ប្រកបដោយគ្រោះថ្នាក់ ។ ទឹកភ្លៀងហួតយ៉ាងរហ័សមិនបង្កលក្ខណៈឱ្យមនុស្សប្រើប្រាស់បានឡើយ ។ ទឹកសេសសល់បន្តិចបន្តួចក៏ជ្រាបចូលក្នុងដី បង្កើតបានជាប្រភពទឹកក្រោមដី ។ ខ្យល់ព្យុះនៅវាលលំហក៏កាចសាហាវណាស់ដែរ បានបោកបក់កួចខ្សាច់ទៅលើអាកាស បាំងបាត់ពន្លឺព្រះអាទិត្យ អាចប្រល័យជីវិតមនុស្ស និងសត្វបើគ្មានជម្រកត្រឹមត្រូវទេ ។ វាលលំហគ្មានរុក្ខជាតិសោះឡើយ ។



*រ៉ិចមួយនៅសាហារ៉ា*



*អ៊ែកមួយនៅសាហារ៉ា*

## 2. មនុស្សផ្សាំខ្លួនទៅនឹងភាពស្ងួតហែង

ដើម្បីការពារកម្តៅថ្ងៃ និងរក្សាធាតុទឹកក្នុងខ្លួន ពួកចរកជនតំបន់វាលលំហស្លៀកពាក់ទូលាយៗជាច្រើនជាន់ និងរុំក្បាលបិទមុខថែមទៀត ។

សម្លៀកបំពាក់បែបនេះ ជួយការពារធូលី និងខ្សាច់ដែលបក់ផាត់ដោយខ្យល់ស៊ីរ៉ូកូ (Sirocco) ម្យ៉ាងទៀតជួយទប់ទល់និងភាពត្រជាក់នារាត្រីកាលផងដែរ ។ ចន្លោះកម្តៅរវាងពេល ថ្ងៃនិងយប់ខ្ពស់ណាស់ គឺលើសពី 50°C ។ ផ្ទៃមេឃស្រឡះ ខៀវស្រងាត់ បញ្ជាក់យ៉ាងច្បាស់ថា កម្តៅពេលថ្ងៃតែងជះត្រឡប់ទៅក្នុងបរិយាកាសវិញ ដែលជាហេតុនាំឱ្យសីតុណ្ហភាពចុះមកនៅក្រោម 0°C ជាញឹកញាប់នៅពេលយប់ ។

## ៣. បំលាស់ប្តូរជីវភាពចរកជន

នៅតំបន់វាលលំហាចរកជនអ្នកចិញ្ចឹមសត្វ បានផ្សាំការរស់នៅរបស់ខ្លួនទៅនឹងមជ្ឈដ្ឋាន ។ ពួកគេផ្លាស់ប្តូរកន្លែងញឹកញាប់ ដើម្បីរកទឹកនិងវាលស្មៅសម្រាប់ចិញ្ចឹមសត្វ ។

ចរកជនខ្លះរស់នៅដោយបរបាញ់សត្វ ដូចមនុស្សសម័យបុរេប្រវត្តិនៅឡើយ ដូចជាពួកជនជាតិដើមនៅទ្វីបអាហ្វ្រិកភាគខាងត្បូងនិងនៅអូស្ត្រាលី ។ អរិយធម៌ទាំងពីរនេះកំពុងតែសាបសូន្យទៅហើយ ។



*កាមុំងជំនួសដោយសត្វអូដ្ឋ*



*ចរកជនដឹកជញ្ជូនអំបិល (ប្រទេសនីហ្សេ)*

ចរកជនខ្លះទៀត រស់នៅក្រោមសំពត់តង់ មានរបរជាអ្នកដឹកជញ្ជូនអំបិលតាមខ្នងសត្វអូដ្ឋកាត់វាលលំហ ។ ពួកគេមានមោទនភាពនិងជីវភាពធូរធារបង្គួររបស់ខ្លួន ព្រោះជា"លោកម្ចាស់នៃវាលលំហ" ។ សព្វថ្ងៃជាអកុសលមុខរបររបស់ពួកគេត្រូវរងនូវការប្រកួតប្រជែងពីដំណើកដជញ្ជូនតាមរថយន្ត រថភ្លើង និងយន្តហោះកាត់វាលលំហសាហារ៉ា ។

*សន្និដ្ឋាន*

ចរកជនបានផ្សាំខ្លួនទៅនឹងលក្ខខណ្ឌរស់នៅដីលំបាកលំបិន ក្នុងវាលលំហ ។ តែសព្វថ្ងៃវឌ្ឍនភាពក្នុងវិស័យដឹកជញ្ជូន បានកែប្រែរបៀបរស់នៅតាមបែបប្រពៃណីរបស់ពួកគេ ។

## មេរៀនសង្ខេប

តំបន់វាលលំហក្តៅ ជាតំបន់ដែលខ្សត់ទឹក ហើយមានសីតុណ្ហភាពខុសគ្នាយ៉ាងខ្លាំងរវាងពេលយប់ និងពេលថ្ងៃ ។ ដើម្បីទប់ទល់នឹងសីតុណ្ហភាពនៅទីនោះ ពួកគេបានប្រើសម្លៀកបំពាក់ទូលាយៗច្រើនជាន់ ។ ការរស់នៅរបស់ពួកគេត្រូវផ្លាស់ប្តូរទីកន្លែងជាញឹកញាប់ ដើម្បីរកទឹក និងវាលស្មៅចិញ្ចឹមសត្វ ។ សព្វថ្ងៃជីវភាពចរកជនកំពុងត្រូវបានផ្លាស់ប្តូរច្រើនហើយ ។

## ? សំណួរ

1. ចូររាប់ឈ្មោះ និងទីតាំងវាលលំហធំៗ ក្នុងពិភពលោកឱ្យបានបីយ៉ាងតិច ។
2. តើនៅតំបន់វាលលំហ គេសង្កេតឃើញមានទេសភាពឬបាតុភូតធម្មជាតិអ្វីខ្លះ? ចូររាប់ឱ្យបានបួនយ៉ាងតិច ។
3. តើអ្នករស់នៅតំបន់វាលលំហក្តៅផ្សាំខ្លួនទៅនឹងអាកាសធាតុស្ងួតហួតហែងដោយវិធីណា ?
4. តើអ្នករស់នៅតំបន់វាលលំហក្តៅ ប្រកបរបរអ្វីខ្លះ ?
5. តើលក្ខខណ្ឌជីវិត នៅតំបន់វាលលំហមានដូចម្តេចខ្លះ ?
6. ហេតុអ្វីបានជានៅតំបន់វាលលំហពេលថ្ងៃក្តៅស្ទើរឆេះ យប់មិនទាន់ ភាពត្រជាក់ក៏មកដល់មួយរំពេច ?
7. តើបាតុភូតធម្មជាតិណាមួយនៅតំបន់វាលលំហ ដែលអ្នកចាប់អារម្មណ៍ជាងគេ ? ចូរពន្យល់ ។
8. ចូរបំពេញតារាងខាងក្រោម ទៅតាមចំណុចនីមួយៗឱ្យបានត្រឹមត្រូវ ៖

| លក្ខខណ្ឌធម្មជាតិ | វាលលំហសាហារ៉ា | ប្រទេសកម្ពុជា |
|---|---|---|
| ចន្លោះកម្តៅ | | |
| កំពស់ទឹកភ្លៀង | | |
| រុក្ខជាតិ | | |
| ការរស់នៅ | | |

***ពន្យល់ពាក្យ***

ចរកជន ៖ ជនដែលរស់នៅ ដោយផ្លាស់ប្តូរទីកន្លែង ។

មេរៀនទី

# 2 ជីវភាពក្នុងអូាស៊ីស

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីជីវភាពប្រជាជនអូាស៊ីស
- ❑ បង្ហាញពីបច្ចេកទេសបុរាណក្នុងការទាញយកទឹកក្នុងអូាស៊ីស
- ❑ ពណ៌នាពីផលល្អ និងផលអាក្រក់ក្នុងការបញ្ចូលទឹកតាមបែបទំនើប ។

អូាស៊ីស ជាកញ្ចុំបៃតងកណ្តាលសមុទ្រខ្សាច់ ជាទីដែលមនុស្សអាចរស់នៅ និងដាំដុះបាន ។ តើមនុស្សដោះស្រាយបញ្ហាទឹក ក្នុងមជ្ឈដ្ឋានមួយដែលស្ទើរតែគ្មានភ្លៀងសោះបានយ៉ាងដូចម្តេច ?

## 1. តាពម្ចាស់ការលើទឹកបង្កើតអូាស៊ីស (Oasis)

អូាស៊ីសបង្កើតបានជាបណ្តុំជីវភាព និងជាកម្រាលបៃតងកណ្តាលវាលលំហ ។ និសិន្នជនអូាស៊ីស អនុវត្តការដាំដុះដំណាំច្បារ ដោយបញ្ចូលទឹកយ៉ាងប៉ិនប្រសប់ ។ ពួកគេរៀបចំចែកចាយទឹកបានយ៉ាងប្រសើរដល់ដីតូចៗ ដោយប្រើសន្ទះសម្រាប់បិទបើកបង្ហូរទឹកតាមវេនម្តងម្នាក់ ។

នៅវាលលំហគ្មានទឹកដក់លើផ្ទៃដីទេ ដូចនេះពួកកសិករត្រូវជីកអណ្តូងជាជួរចេញពីជើងភ្នំរហូតដល់ភូមិតាមបច្ចេកទេសបុរាណ និងប្រើសម្ភារៈសាមញ្ញ ដើម្បីទាញយកទឹកពីស្រទាប់ក្រោមដី ។ នៅសាហារ៉ា ពួកកសិករបានជីកផុកការ៉ា(រូងក្រោមដី) ដើម្បីនាំទឹក ពីជើងភ្នំទៅកាន់អូាស៊ីស ។



*ជួរអណ្តូង*




*រំនុះកាត់ផុកការ៉ាមួយ*

ជាភ័ព្វសំណាងចំពោះតំបន់សោះកក្រោះខ្លះ ដែលមានទន្លេហូរកាត់ ដូចជាទន្លេនីល (អេហ្ស៊ីប) ទន្លេទិច និងអឺប្រាត( អ៊ីរ៉ាក់) ទន្លេឥណ្ឌុស ( ប៉ាគីស្ថាន) ជាដើម ។ អាស៊ីសនៅក្បែរទន្លេទាំងនោះរីកចម្រើនខ្លាំងបង្កើតបានជាអរិយធម៌ដ៏ត្រចះត្រចង់ជាច្រើនពាន់ឆ្នាំមកហើយ ដូចជាអរិយធម៌អេហ្ស៊ីបសម័យព្រះចៅ ផារ៉ាអុង ជាឧទាហរណ៍ស្រាប់ ។



ដើមល្មើ

នៅតាមអូាស៊ីស ឈើហូបផ្លែសំខាន់ជាងគេ គឺដើមល្មើ។ ក្រោមដើមល្មើ គេអាចដាំបន្លែទៀតផង ។ ល្មើផ្តល់ផ្លែសម្រាប់ហូប ស្លឹក និងដើមសម្រាប់សង់លំនៅស្ថាន ។ ទីក្រុងមួយចំនួននៃតំបន់វាលលំហរីកធំឡើងក្បែរចម្ការល្មើនេះឯង ។

## 2. ការបញ្ចូលទឹកតាមបែបទំនើបបានកែប្រែអូាស៊ីស







ការបញ្ចូលទឹកតាមបែបទំនើប

តាំងពីជិត 50 ឆ្នាំមកហើយ ការដ្ឋានបញ្ចូលទឹកធំៗ បានកែប្រែមុខមាត់វាលលំហ ។ ប៉ុន្តែផលល្អ និងផលអាក្រក់កើតមានទន្ទឹមគ្នាពីការងារនេះ ។

ក្នុងការរុករកប្រេងកាត មនុស្សបានរកឃើញកំណាប់ទឹកក្រោមដីសំខាន់ៗជាច្រើន ។ ទំនប់អាងទឹកធំៗត្រូវបានគេសាងសង់កាត់ស្ទឹង ទន្លេ ដើម្បីផ្គត់ផ្គង់ទឹកទៅឱ្យបណ្តាញព្រែកជីកតាមដងទន្លេឥណ្ឌុសឬទន្លេនីល ។ អាស្រ័យហេតុនេះហើយ ទើបគេមានទឹកគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការនៃប្រព័ន្ធបញ្ចូលទឹកតាមបែបទំនើប ដែលអាចផ្តល់ទឹកដល់ការងារកសិកម្មខួបប្រាំងខួបវស្សា ។

ប៉ុន្តែការបញ្ចូលទឹកមិនមែនសុទ្ធតែផ្តល់ផលល្អទាំងអស់នោះទេ ៖

- សំណង់ប្រព័ន្ធបញ្ចូលទឹកមានតម្លៃខ្ពស់ ។
- ទឹកក្នុងអាងទាំងនោះ អនុគ្រោះខ្លាំងដល់កំណើនសត្វមូស ដែលជាភ្នាក់ងារចម្លងមេរោគ ។

នៅលើទីដីបញ្ចូលទឹក កម្តៅ ( រំហួត) បាននាំធាតុទឹកទៅក្នុងអាកាស ដោយបន្សល់ទុកនូវសារធាតុអំបិលលើផ្ទៃដី នាំឱ្យប៉ះពាល់ដល់គុណភាពដីរាប់ពាន់ម៉ឺនហិកតា ដែលដណ្តើមបានពីវាលលំហ និងប្រើអស់សោហ៊ុយយ៉ាងច្រើន ។

***សន្និដ្ឋាន***

អស់រយៈពេលជាច្រើនពាន់ឆ្នាំមកហើយ និសិន្នជនអាស៊ីសបានសម្រេចជោគជ័យក្នុងការដាំដុះចិញ្ចឹមជីវិត ដោយប្រើប្រភពទឹកក្រោមដី ។ ភាពម្ចាស់ការលើទឹក ដោយការប្រើបច្ចេកទេសថ្មីៗ បានធ្វើឱ្យទេសភាព និងជីវភាពប្រជាកសិករតំបន់វាលលំហមានកំណែប្រែ ។

**មេរៀនសង្ខេប**

- នៅតំបន់វាលលំហគ្មានទឹកដក់នៅលើផ្ទៃដីទេ គេប្រើប្រាស់ទឹក ដោយជីកអណ្តូងជាជួរចេញពីជើងភ្នំរហូតដល់ភូមិ ដើម្បីប្រមូលទឹកពីស្រទាប់ក្រោមដី ។
- នៅតាមអាស៊ីស ឈើហូបផ្លែសំខាន់ជាងគេគឺដើមល្មើ ។
- អាស៊ីសនៅក្បែរប្រភពទឹកមានការរីកចម្រើនខ្លាំង ។
- ការបញ្ចូលទឹកតាមបែបទំនើប បានធ្វើឱ្យជីវភាពប្រជាជនមានកំណែប្រែ ។ ទន្ទឹមនឹងនេះការបញ្ចូលទឹកតាមបែបទំនើបមានតម្លៃខ្ពស់ កំណើនសត្វមូសដែលជាភ្នាក់ងារចម្លងរោគនិងសំណល់សារធាតុអំបិលលើផ្ទៃដីនាំឱ្យប៉ះពាល់ដល់គុណភាពដី ។

## ? សំណួរ

1. តើនិសិទ្ទជនអាស៊ីស ប្រើប្រាស់ទឹកដីកម្រយ៉ាងដូចម្ដេច ?
2. ចូរនិយាយពីវិធីទាញយកទឹកក្រោមដីតាមបែបបុរាណរបស់កសិករអាស៊ីស ។
3. " អាស៊ីសក្បែរទន្លេទទួលបានការរីកចម្រើនខ្ពស់" ចូរពន្យល់អំណះអំណាងនេះ ។
4. តើចម្ការល្មើផ្ដល់នូវអត្ថប្រយោជន៍អ្វីខ្លះ ?
5. ការបញ្ចូលទឹកតាមបែបទំនើប នាំមកនូវផលវិបាកអ្វីខ្លះ ?
6. " អាស៊ីសបង្កើតបានអរិយធម៌ត្រចះត្រចង់តាំងពីរាប់ពាន់ឆ្នាំមកហើយ" ចូរពន្យល់ ។
7. តើអ្នកយល់ដឹងអ្វីខ្លះពីទន្លេនីល និងទន្លេមេគង្គ ? ចូរបង្ហាញ ។
8. តើអរិយធម៌អាស៊ីស និងអរិយធម៌អាស៊ីមូសុងមានលក្ខណៈដូចគ្នាដែរឬទេ?
9. " អាស៊ីសអាចរីកលូតលាស់បានដោយសារវត្តមានទឹក" ។ ចូរពន្យល់អំណះអំណាងនេះ ។
10. តើការបញ្ចូលទឹកតាមបែបទំនើបបានកែប្រែមុខមាត់អាស៊ីសដូចម្ដេច?
11. ចូរបង្ហាញភាពខុសគ្នារវាងអាស៊ីសប្រពៃណី និងអាស៊ីសទំនើប ។
12. តើបាតុភូតធម្មជាតិសំខាន់ៗនៃតំបន់វាលលំហាមានអ្វីខ្លះ? ចូរបង្ហាញ ។

*ពន្យល់ពាក្យ*

និសិទ្ទជន : អ្នកមានទីលំនៅនឹងមួយកន្លែងមិនផ្លាស់ប្ដូរទីកន្លែង ។

អាស៊ីស : លំហាមួយដែលមានមនុស្សរស់នៅ និងដាំដំណាំបាន ដោយសារវត្តមាននៃទឹក ។

ផុកការ៉ា : ពាក្យអារ៉ាប់មានន័យថា រូងក្រោមដីដើម្បីនាំទឹកទៅកាន់អាស៊ីស និងចៀសវាងរំហួតខ្លាំងផងដែរ ។

ផារ៉ាអុង : ពាក្យមកពីអេហ្ស៊ីប មានន័យថា គេហដ្ឋានធំ ជាគោរម្យងារស្ដេចអេហ្ស៊ីប ។

នីល : ទន្លេមួយនៃទ្វីបអាហ្វ្រិកមានប្រភពនៅបឹងវិចថូរា ហូរកាត់ទីក្រុងគែរប្រទេសអេហ្ស៊ីបចាក់ទៅក្នុងសមុទ្រមេឌីទែរ៉ាណេ ប្រវែង 6 500km ។

ទីចនិងអឺប្រាត : ទន្លេសំខាន់ពីរនៅមជ្ឈិមបូព៌ា ហូរកាត់ប្រទេសអ៊ីរ៉ាក់ ។ ទន្លេទីចមានប្រវែង 1 950km និងទន្លេអឺប្រាតមានប្រវែង 2 780km ។

ឥណ្ឌុស : ទន្លេមួយនៃទ្វីបអាស៊ីមានប្រភពនៅភ្នំទីបេ ហូរចាក់ទៅក្នុងសមុទ្រអូម៉ង់កាត់រដ្ឋកាស្មៀនិងប្រទេសប៉ាគីស្ថានប្រវែង 3 040Km ។

# 3 អាជីវកម្មធនធានធម្មជាតិតំបន់វាលលំហ

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីសារៈសំខាន់នៃធនធានធម្មជាតិនៅតំបន់វាលលំហ
- បង្ហាញពីការផ្លាស់ប្តូរមុខមាត់ថ្មី នៃតំបន់វាលលំហក្តៅ ។

ពីមុនគេពុំបានដឹងថា តំបន់វាលលំហជាទីសម្បូរទៅដោយធនធានរ៉ែនោះទេ ។ តែសព្វថ្ងៃដោយសារបច្ចេកទេសទំនើបទើបគេអាចរកឃើញរ៉ែសន្និកសន្ធាប់នៅទីនោះ ។

## 1. វាលលំហជាឃ្លាំងស្តុកធនធានរ៉ែ

វាលលំហជាច្រើនមានប្រភពថាមពលនៅក្នុងដី ។ ដើម្បីរុករកអ៊ីដ្រូកាបួ ក្រុមហ៊ុនប្រេងកាតបានតម្លើងជើងខ្វងខ្ពស់ៗ ដែលអាចជីកអណ្តូងបានយ៉ាងជ្រៅ ។ វាលលំហក្តៅផ្តល់ប្រេងកាត និងឧស្ម័នធម្មជាតិមួយភាគធំនៃពិភពលោក ។ ការលក់"មាសខ្មៅ"នេះធ្វើឱ្យប្រទេសមួយចំនួន ទទួលបាននូវភាពសម្បូរសប្បាយ ។ ចរកជនតំបន់វាលលំហអារ៉ាប៊ីក្លាយទៅជាអ្នកមានបំផុតក្នុងពិភពលោក ។

ទីក្រុងថ្មីៗជាច្រើន បានកើតឡើងត្រង់អណ្តូងរ៉ែ ដែលជាកន្លែងស្នាក់នៅនៃអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនប្រេងកាត ដូចជាទីក្រុងហាស់ស៊ីម៉េស្សាអ៊ូត នៅកណ្តាលវាលលំហសាហារ៉ា ជាដើម ។

រាជធានីរីយ៉ាដនៃប្រទេសអារ៉ាប៊ីសាអូឌីត ពីដើមជាអូាស៊ីសមួយមានប្រជាជន 100 000នាក់ នៅក្នុងឆ្នាំ1950 បច្ចុប្បន្ននេះ មានប្រហែល 5 100 000 នាក់ (ឆ្នាំ 2008) ។ សង្កាត់ថ្មីៗជាច្រើនទៀតត្រូវបានបង្កើតឡើងសម្រាប់ទទួលអ្នកធ្វើការជាជនបរទេស ។

សហគ្រាសនៃបណ្តាប្រទេសឧស្សាហកម្ម ដូចជាបារាំងនិងសហរដ្ឋអាមេរិកកំពុងធ្វើអាជីវកម្មដោយកាយយករ៉ែលោហៈកណ្តាលវាលតែម្តង ។ កំណាប់រ៉ែផូស្វាត ដែលជាជីមួយប្រភេទដ៏ប្រសើរក៏ត្រូវបានធ្វើអាជីវកម្មដែរ ។ ប្រទេសទុយនីស៊ីបាននាំចេញរ៉ែផូស្វាតរបស់ខ្លួនពាសពេញពិភពលោក ។

## 2. តើតំបន់វាលលំហនឹងស្ថិតនៅឯកោទៀតឬ ?

ពួកកងទ័ពរបស់មហាអំណាចខ្លះ បានសាងសង់មជ្ឈមណ្ឌលសាកល្បងមួយចំនួននៅក្នុងវាលលំហដើម្បីរក្សាការសម្ងាត់នៃការស្រាវជ្រាវរបស់ខ្លួន ។ ហេតុដូចនេះ ហើយបានជាកងទ័ពបារាំងស្ថាបនាមូលដ្ឋានសាកល្បងនុយក្លេអ៊ែនៅរ៉ិចកាន (Reggane)នាកណ្តាលវាលលំហសាហារ៉ា ។

អាជីវកម្មរ៉ែតម្រូវឱ្យមានមធ្យោបាយដឹកជញ្ជូនទំនើប ដើម្បីនាំផលិតផលទៅកាន់កំពង់ផែ ។ រថភ្លើងដឹកជញ្ជូនរ៉ែធ្ងន់ៗដូចជារ៉ែដែកឬរ៉ែទង់ដែង ។ បំពង់បង្ហូរប្រេងឬបំពង់បង្ហូរឧស្ម័ន នាំប្រេងកាត និងឧស្ម័នធម្មជាតិពីអណ្តូងរ៉ែទៅកាន់កំពង់ផែ ។

សព្វថ្ងៃ តំបន់វាលលំហានៅតែជាតំបន់ពិបាកចេញចូល ។ ផ្លូវលំដែលមានគុណភាពអន់ ទើបតែត្រូវបានជំនួសជាបណ្តើរៗ ដោយផ្លូវចាក់កៅស៊ូ ។ គេប្រើរថយន្តក្នុងការធ្វើដំណើរជិតៗ ហើយប្រើយន្តហោះសម្រាប់ដំណើរផ្លូវឆ្ងាយ ។

ភ្នាក់ងារទេសចរណ៍ ចាប់ផ្តើមលក់សំបុត្រជូនភ្ញៀវ ដែលត្រូវធ្វើដំណើរកម្សាន្តកាត់វាលលំហា ។ សោភណភាពនៃទេសភាព និងចំណូលចិត្តដំណើរផ្សងព្រេងក្នុងមជ្ឈដ្ឋានមួយដែលពិបាករស់នៅបំផុតលើភពផែនដីបង្កើតបានជាចំណូលថវិកាថ្មីសម្រាប់បណ្តាប្រទេសក្នុងតំបន់វាលលំហា ។ ទេសចរណ៍ប្រភេទនេះ មានឈ្មោះថា **ទេសចរណ៍វាលខ្សាច់** ។

***សន្និដ្ឋាន*** : ថ្វីបើមានសកម្មភាពទាញយករ៉ែនិងការទាក់ទាញថ្មីៗ ផ្នែកទេសចរណ៍ក្តី ក៏តំបន់វាលលំហានៅតែមានមនុស្សរស់នៅតិចដដែល ។ ប៉ុន្តែមធ្យោបាយគមនាគមន៍ទំនើបបានធ្វើឱ្យប្រជាជនវាលលំហាឃ្លាតឆ្ងាយបន្តិចម្តងៗពីប្រពៃណីរស់នៅឯកោរបស់ខ្លួន ។

**មេរៀនសង្ខេប**

- តំបន់វាលលំហាជាច្រើនមានប្រភពថាមពលនៅក្នុងដី ។ ចរកជនតំបន់វាលលំហាក្លាយទៅជាអ្នកមានក្នុងលោក ។ សហគ្រាសនៃបណ្តាប្រទេសឧស្សាហកម្មកំពុងធ្វើអាជីវកម្មទាញយករ៉ែក្នុងតំបន់វាលលំហា ។ ប៉ុន្តែ តំបន់វាលលំហានៅតែមានមនុស្សរស់នៅតិចដដែល ។ សោភណភាពនៃតំបន់វាលលំហាបង្កើតបានជាចំណូលថវិកាសម្រាប់បណ្តាប្រទេសក្នុងតំបន់ ។

## ? សំណួរ

1. តើតំបន់វាលលំហាក្តៅសម្បូរធនធានអ្វីខ្លះ ?
2. ក្រៅពីអាជីវកម្មរ៉ែ តើគេបានធ្វើអ្វីខ្លះទៀតនៅតំបន់វាលលំហា ?
3. តើគេដឹកជញ្ជូនប្រេងកាត និងឧស្ម័នធម្មជាតិតាមមធ្យោបាយណានៅតំបន់វាលលំហា ?
4. តើមានអ្វីកើតឡើងនៅត្រង់អណ្តូងរ៉ែនៃតំបន់វាលលំហា ? ចូរបង្ហាញ និងបញ្ជាក់ដោយឧទាហរណ៍ ។
5. ហេតុអ្វីបានជាសម័យមុន គេមិនអាចដឹងបានថា តំបន់វាលលំហាមានកំណប់រ៉ែ ?
6. ហេតុអ្វីបានជាទីក្រុងថ្មីៗកកើតឡើងនៅតំបន់វាលលំហា ?
7. តើបច្ចុប្បន្ននេះ តំបន់វាលលំហាបន្តស្ថិតនៅឯកោទៀតឬយ៉ាងណា ? ចូរពន្យល់ ។
8. តើហាស់ស៊ីម៉េស្សាអ៊ូតជាអ្វី ? ស្ថិតនៅទីណា ?

# 4 មនុស្សក្នុងមជ្ឈដ្ឋានប៉ូល

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ស្ថានភាពភូមិសាស្ត្រក្នុងតំបន់ប៉ូល
- បង្ហាញពីជីវភាពរស់នៅរបស់ប្រជាជនតំបន់ប៉ូល
- កំណត់ពីភាពផ្ទុយគ្នាខ្លួនទៅនិងរាត្រីប៉ូល ។

តំបន់ប៉ូលទាំងពីរជាមហាលំហទឹកកក ប្រកបដោយទេសភាពធម្មជាតិប្លែកៗ គួរជាទីចាប់អារម្មណ៍ ដូចជាសីតុណ្ហភាពត្រជាក់ខ្លាំងហួសហេតុ អាយស៊្បែ បង់គីស វាលទុនដ្រា រាត្រីប៉ូល ព្រះអាទិត្យកណ្ដាលអធ្រាត្រជាដើម ។ នៅតំបន់ទាំងនោះ មានមនុស្សរស់នៅតិចតួចណាស់ ។

## 1. ស្ថានភាពភូមិសាស្ត្រ

### 1.1. អាកទិច

តំបន់ប៉ូលខាងជើង ជាទីតាំងនៃមហាសមុទ្រទឹកកកអាកទិច ស្ថិតនៅជាប់ឆ្នេរខាងជើងនៃទ្វីបអឺរ៉ាស៊ីនិងទ្វីបអាមេរិកភ្ជាប់មកមហាសមុទ្រប៉ាស៊ីហ្វិកដោយច្រកបេរិញនិងបើកចំហយ៉ាងទូលាយមករកមហាសមុទ្រអាត្លង់ទិច ។ មហាសមុទ្រនេះមានផ្ទៃ 13 000 000km$^2$ តូចជាងមហាសមុទ្រដទៃទៀត ។

### 1.2. អង់តាកទិច

ទ្វីបអង់តាកទិចជាមហាលំហទឹកកកមួយដែលស្ថិតនៅជុំវិញប៉ូលខាងត្បូង ។ ទ្វីបនេះស្ថិតនៅជាប់មហាសមុទ្រប៉ាស៊ីហ្វិក មហាសមុទ្រអាត្លង់ទិច និងមហាសមុទ្រឥណ្ឌាមានផ្ទៃដីប្រហែលគ្នានិងទ្វីបអឺរ៉ុប 14 000 000 km$^2$ ។ ផ្ទៃទ្វីបគ្របដណ្ដប់ស្ទើរតែទាំងស្រុងដោយទឹកកកនិងមានកាតិបទឹកកកធំជាងគេបង្អស់ ។ ទ្វីបអង់តាកទិចមានឈ្មោះម្យ៉ាងទៀតថា **ទ្វីបពណ៌ស** ។




## 2. ពិភពរស់ជាក់

### 2.1. ពិភពមួយខ្សត់មនុស្ស

តំបន់ប៉ូលទាំងពីរមានមនុស្សរស់នៅតិចជាង7 លាននាក់ ។ នៅតំបន់អាកទិច មានពួកអេស្គីម៉ូចំនួន 380 000 នាក់នៅភាគឧត្តរបំផុតនៃប្រទេសកាណាដា និងលើកោះក្រូអិនឡិន ពួកឡាប៉ុងចំនួន 35 000 នាក់ រស់នៅតំបន់ស្កង់ឌីណាវ ពួកសាម៉ូយ៉ែតនិងយ៉ាគូតចំនួន 5 លាននាក់រស់នៅតំបន់អាកទិចរុស្ស៊ី ។ នៅលើទ្វីបអង់តាកទិចគ្មានមនុស្សរស់នៅជាអចិន្ត្រៃយ៍ទេ គឺមានតែពួកអ្នកវិទ្យាសាស្ត្រប៉ុន្មានពាន់នាក់ប៉ុណ្ណោះកំពុងស្រាវជ្រាវតាមមូលដ្ឋានវិទ្យាសាស្ត្រនានាដោយប្តូរវេនគ្នា ។

## 2.2. លក្ខណៈធម្មជាតិ

ទ្វីបអង់តាកទិចនិងកោះគ្រូអិនឡិនមានទឹកកកកម្រាស់ 4 000m ។ ប្រសិនបើវារលាយនឹងទឹកសមុទ្រនឹងឡើងលើស 10m ។ ផ្ទាំងទឹកកកសាបធំប៉ុនៗភ្នំ ដាច់ចេញពីផែនទឹកកកទ្វីបអណ្តែតក្នុងមហាសមុទ្រហៅថា**អាយស៊ែប្ល** បង្កគ្រោះថ្នាក់ធ្ងន់ធ្ងរណាស់ដល់នាវា ។ ចំណែកបង់គីស ដែលជាផ្ទាំងទឹកកកប្រៃអណ្តែតលើផ្ទៃមហាសមុទ្រមានកម្រាស់តែប៉ុន្មានម៉ែត្រប៉ុណ្ណោះរារាំងដល់ការចូលចតនៃនាវានៅតាមឆ្នេរទ្វីប ។


*អាយស៊ែប្លមួយក្នុងមហាសមុទ្រទឹកកកអាកទិច*

នៅខែត្រជាក់បំផុត ផ្ទៃមហាសមុទ្រគ្របដណ្តប់ដោយ**បង់គីស** ។ ពួកអេស្គីម៉ូតែងចោះផ្ទាំងបង់គីសដើម្បីស្ទូចត្រី ។ ពេលបង់គីសរលាយអស់ ទឹកសមុទ្រសម្បូរប្លង់តុងដែលជាចំណីដ៏ប្រសើរសម្រាប់សត្វសមុទ្រ ។

នៅតាមឆ្នេរអាកទិច ចាប់ពីខែមិថុនាដល់ខែកញ្ញាមានរុក្ខជាតិតូចៗ ដុះតិចតួចលើវាលទុនដ្រាសម្រាប់ចិញ្ចឹមសត្វរ៉ែននៅតំបន់ស្កង់ឌីណាវ និងស៊ីបេរី ហើយសត្វការីប៊ូនៅកាណាដា ។ តំបន់ប៉ូលគ្មានរដូវក្តៅទេ ។ សីតុណ្ហភាពខ្ពស់បំផុត +10°C ។ នៅទ្វីបអង់តាកទិចសីតុណ្ហភាពទាបបំផុតចុះដល់ –88°C ។ នៅតំបន់អាកទិចសីតុណ្ហភាពមធ្យមប្រចាំខែមករាចុះដល់ –40°C ។ រីឯព្យុះទឹកកកច្រើនកើតមានជាយូរខែនៅលើមហាលំហទឹកកកទាំងនោះ ។ ព្យុះអាចមានល្បឿនដល់ជាង 300km/h ។

## 2.3. រាត្រីប៉ូលនិងព្រះអាទិត្យកណ្តាលអធ្រាត្រ

មនុស្សតំបន់ប៉ូលត្រូវផ្សាំខ្លួនទៅនឹង**រាត្រីប៉ូល**ដែលជាបាតុភូតកើតឡើងនាសិសិររដូវ ដោយសារព្រះអាទិត្យមិនបានរះជាច្រើនសប្តាហ៍ ។ ពេលនោះសកម្មភាពមនុស្សក៏ថយចុះដែរ ។ ផ្ទុយទៅវិញនៅវស្សានរដូវព្រះអាទិត្យរះរហូតដោយវិលវល់នៅឯជើងមេឃ គឺជាបាតុភូត **ព្រះអាទិត្យកណ្តាលអធ្រាត្រ** ។ ក្នុងពេលនោះ សកម្មភាពមនុស្សក៏កើនឡើងវិញ ហើយក៏ជារយៈកាលនៃការរុករកធំ ៗ នៅតំបន់ប៉ូលផងដែរ ។

***សន្និដ្ឋាន*** : នៅមជ្ឈដ្ឋានប៉ូលមានមនុស្សរស់នៅតិចតួចណាស់ ដោយហេតុថា ភាពត្រជាក់កើតមានជាអចិន្ត្រៃយ៍នៅទីនោះ ហើយរាត្រីប៉ូលនាំឱ្យគេរស់នៅក្នុងភាពងងឹតអស់រយៈពេលជាច្រើនខែ ។

## មេរៀនសង្ខេប

- តំបន់ប៉ូលទាំងពីរមានមនុស្សរស់តិចតួច ដោយសារអាកាសធាតុត្រជាក់ហួសហេតុជាអចិន្ត្រៃយ៍ តែប្រជាជនតំបន់ប៉ូលចេះផ្សាំខ្លួនទៅនឹងភាពត្រជាក់នេះ ។
- ជនជាតិដែលរស់នៅតំបន់ប៉ូល មានជនជាតិ អេស្គីម៉ូ ជនជាតិឡាប៉ុង ពួកសាម៉ូយ៉ែត និង ពួកយ៉ាគូត និងមានពួកអ្នកស្រាវជ្រាវមួយចំនួនតូចប៉ុណ្ណោះ ។

## ? សំណួរ

1. ចូររៀបរាប់ពីស្ថានភាពភូមិសាស្ត្រតំបន់អាកទិច និងអង់តាកទិច ។
2. តើនៅតំបន់អាកទិចមានក្រុមជនជាតិណាខ្លះរស់នៅ ?
3. តើនៅតំបន់អង់តាកទិចមានមនុស្សរស់នៅដូចតំបន់អាកទិចដែរឬទេ ?
4. តើតំបន់ត្រជាក់ទាំងនោះមានលក្ខណសម្បត្តិធម្មជាតិដូចម្តេចខ្លះ ?
5. ហេតុអ្វីបានជាមានមនុស្សរស់នៅតិចតួចក្នុងមជ្ឈដ្ឋានប៉ូល ?
6. ហេតុអ្វីបានជាអ្នកវិទ្យាសាស្ត្រ មិនអាចតាំងទីរស់នៅជាអចិន្ត្រៃយ៍ក្នុងតំបន់អង់តាកទិច ?
7. ចូរកំណត់ន័យនៃពាក្យ អាកទិច អង់តាកទិច អាយស៊ែ្ប និងបង់គីស ។
8. តើរាត្រីប៉ូល និងព្រះអាទិត្យកណ្តាលអធ្រាត្រ មានឥទ្ធិពលទៅលើសកម្មភាពមនុស្សដូចម្តេចខ្លះ ?
9. ចូរប្អូនស្រាវជ្រាវរកឯកសារផ្សេងៗ នៅផ្ទះអ្នក សាលារៀន ឬបណ្ណាល័យនានា រួចបំពេញតារាងខាងក្រោម ។

តារាង ( ក )

| អាកាសធាតុកម្ពុជា | អាកាសធាតុប៉ូល |
|---|---|
| | |

តារាង ( ខ )

| ទីកន្លែង | សីតុណ្ហភាពទាបបំផុត | សីតុណ្ហភាពខ្ពស់បំផុត |
|---|---|---|
| កម្ពុជា | | |
| តំបន់ប៉ូល | | |

*ពន្យល់ពាក្យ*

បង់គីស : ផ្ទាំងទឹកកកដែលកើតនៅក្នុងមហាសមុទ្រ មានកម្រាស់ ពីរទៅបីម៉ែត្រ ។

អាយស៊ែ្ប : ផ្ទាំងទឹកកកទីបធំៗប៉ុនភ្នំ ដែលដាច់ធ្លាក់ចេញពីទីបអណ្តែតក្នុងមហាសមុទ្រ ។

កាតិបទឹកកក : គម្របទឹកកកលើដីតំបន់ប៉ូលមានកម្រាស់ជាច្រើនពាន់ម៉ែត្រ ។

វាលទុនដ្រា : វាលក្បែរប៉ូលឬនៅលើភ្នំខ្ពស់ៗគ្របដណ្តប់ដោយស្មៅ និងរុក្ខជាតិតូចៗ (លីកែន ស្លែ ប៊ូឡូ សូល ) ។

វស្សានរដូវ : រដូវក្តៅបំផុតនៅតំបន់ប៉ូល ។

មេរៀនទី

# 5 ជីវភាពបច្ចុប្បន្នក្នុងតំបន់ប៉ូល

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីជីវភាពរស់នៅរបស់ប្រជាជនតំបន់ប៉ូល
- បង្ហាញពីការធ្វើសញ្ជ័យទៅលើតំបន់ប៉ូល
- បង្ហាញពីអត្ថប្រយោជន៍នៃមជ្ឈដ្ឋានប៉ូល ។

ទោះបីមានភាពត្រជាក់ពិបាកទ្រាំយ៉ាងណាក៏ដោយ ក៏មានមនុស្សមួយចំនួនតូចរស់នៅតាមបណ្ដោយឆ្នេរនៃមហាសមុទ្រអាកទិចឬតាមមូលដ្ឋាននានានៃតំបន់អង់តាកទិចដែរ ។ តើពួកគេរៀនផ្សាំខ្លួនទៅនឹងមជ្ឈដ្ឋានប្រកបដោយអរិភាពបែបនេះបានយ៉ាងដូចម្ដេច ? តើអ្វីខ្លះដែលជាកត្តាកែប្រែរបៀបរបបរស់នៅរបស់ពួកគេទាំងនោះ ?

## 1. ពួកអ៊ីនុ្វី (Inuits) តិចតួចរស់នៅដោយប្រមាញ់និងនេសាទ

ជនជាតិអ៊ីនុ្វីបធ្វើសញ្ជ័យទៅលើតំបន់ប៉ូល តាំងពីដើមសតវត្សទី20មកម្ល៉េះ ដោយនាំមកនូវកាំភ្លើងគ្រឿងយន្ត និងរបៀបរបបចិញ្ចឹមជីវិតមួយផ្សេងទៀតទៅជាមួយផង ។



*របៀបនេសាទតាមបែបបុរាណ*



*របៀបនេសាទតាមបែបទំនើប*

ពេលរាត្រីប៉ូល គេមិនសូវឃើញមានសកម្មភាពអ្វីទេដោយសារអាកាសធាតុត្រជាក់ខ្លាំងពេក ។ មានគ្រួសារពួកអ៊ីនុីតិចតួចណាស់ដែលបន្តប្រពៃណីរស់នៅក្នុងអ៊ីក្លូ (Igloo) លំនៅដែលមានដំបូលរាងជាដោមធ្វើពីផ្ទាំងទឹកកកសំឡី ។ ពួកគេទប់ទល់និងអាកាសធាតុត្រជាក់ដោយស្លៀកពាក់ខោអាវក្រាស់ៗ មិនជ្រាបទឹកនិងបរិភោគសាច់សម្បូរខ្លាញ់ ។ ដើម្បីធ្វើប្រមាញ់សត្វផូកឬការីបូ ពួកអ៊ីនុីប្រើម៉ូតូបើកលើទឹកកកសំឡីជំនួសការប្រើកាណូតម៉ាស៊ីនប្រដាប់ដោយកាំភ្លើង ។



ការប្រពៃណីអូសដោយម៉ូតូ

សព្វថ្ងៃពួកអ៊ីនុីភាគច្រើនលែងជាចរកជនទៀតហើយ ដោយទទួលយករបៀបរស់នៅតាមបែបទំនើប គេក៏ក្លាយជានិសិន្នជនវិញ ។ ពួកប្រុសៗទៅធ្វើការនៅអណ្តូងរ៉ែ ខ្លះទៀតទៅនេសាទតាមនាវា ឯស្រីៗទៅធ្វើការតាមរោងចក្រ ។ ចំណែកកុមារទៅសាលារៀន មិនទៅនេសាទដូចមុនទៀតទេ ។ អរិយធម៌ពួកអ៊ីនុីកំពុងតែបាត់បង់ទៅហើយ ។

## 2. ការធ្វើសញ្ជ័យទៅលើតំបន់ភាគមហាឧត្តរនៃអឺរ៉ាស៊ី

នៅលើវាលទុនដ្រាភាគខាងជើងឧបទ្វីបស្កង់ឌីណាវ ពួកឡាប៉ុងនៅតែបន្តចិញ្ចឹមសត្វរ៉េន ។ ដើម្បីឱ្យពួកចរកជនយ៉ាគូតរស់នៅនិងមួយកន្លែង រដ្ឋាភិបាលសហភាពសូវៀតបានបង្កើតមជ្ឈមណ្ឌលចិញ្ចឹមសត្វរ៉េនជាច្រើនកន្លែងធំៗ ហើយទំនើបនៅស៊ីបេរី ។

ដើម្បីធ្វើអាជីវកម្មរ៉ែនៅភាគខាងជើងស៊ីបេរី ពួកសូវៀតបានបង្កើតទីក្រុងថ្មីៗចំនួនជាង80 ដែលភ្ជាប់គ្នាពីមួយទៅមួយដោយយន្តហោះ នាវា ផ្លូវដែក ឬផ្លូវថ្នល់ ។

## ៣. មូលដ្ឋានវិទ្យាសាស្ត្រលើទ្វីបអង់តាកទិច



*ស្ថានីយវិទ្យាសាស្ត្រមួយនៅទ្វីបអង់តាកទិច*

មុនជនជាតិអឺរ៉ុបទៅដល់ ទ្វីបអង់តាកទិចគ្មានមនុស្សរស់នៅទេ ។ គេឃើញមានតែពពួកសត្វម៉ង់សួ និងសត្វផូកប៉ុណ្ណោះ ។

ក្រោយឆ្នាំ1945ប្រទេសមួយចំនួននាំគ្នាបែងចែកទ្វីបនេះ ។ ពួកគេបានសាងសង់មូលដ្ឋានវិទ្យាសាស្ត្រជាច្រើនកន្លែង ប៉ុន្តែមូលដ្ឋានយោធាត្រូវហាមឃាត់ ។ សព្វថ្ងៃ ទ្វីបអង់តាកទិចស្ថិតនៅជាទ្វីបសន្តិភាព និងជាបេតិកភណ្ឌរបស់មនុស្សជាតិ ។

***សន្និដ្ឋាន*** : ប្រជាជនតំបន់ប៉ូលចេះផ្សាំខ្លួនទៅនឹងភាពត្រជាក់ ។ របៀបរបបរស់នៅរបស់ពួកគេបានផ្លាស់ប្តូរទាំងស្រុង តាំងពីការមកដល់នៃជនជាតិអឺរ៉ុប ។ អរិយធម៌របស់ពួកអ៊ីនុយ្វីកំពុងរលាយទៅ ហើយទីក្រុងទំនើបៗកកើតឡើងនៅភូមិភាគមហាឧត្តរ ។ អង់តាកទិចជាទ្វីបមួយសម្រាប់ស្រាវជ្រាវនិងប្រកបទៅដោយសន្តិភាព ។

### មេរៀនសង្ខេប

- សព្វថ្ងៃពួកអ៊ីនុយ្វីភាគច្រើនលែងជាចរកជនទៀតហើយ ដោយទទួលយករបៀបរស់នៅតាមបែបទំនើប ក្លាយជានិសិន្នជនវិញ ។
- ទីក្រុងថ្មីៗកើតឡើងព្រោងព្រាតនៅមហាភូមិភាគឧត្តរ ។
- ទ្វីបអង់តាកទិច (ទ្វីបពណ៌ស ) ជាទ្វីបមួយសម្រាប់ស្រាវជ្រាវនិងជាទ្វីបសន្តិភាព ។

## ? សំណួរ

1. តើជនជាតិណាធ្វើសញ្ជ័យទៅលើតំបន់ប៉ូល ? តើមានផលប្រយោជន៍អ្វីខ្លះ ?
2. តើពួកអ៊ីនុីតំបន់នោះ បានកែប្រែជីវភាពរស់នៅយ៉ាងដូចម្ដេចខ្លះ ? ចូរបង្ហាញ ។
3. ក្រោយឆ្នាំ1945 តើគេបានធ្វើអ្វីខ្លះ នៅទ្វីបអង់តាកទិច ?
4. តើរបៀបរស់នៅតាមបែបប្រពៃណី និងតាមបែបទំនើបរបស់ពួកអ៊ីនុីមានដូចម្ដេចខ្លះ ?
5. ការផ្លាស់ប្ដូររបៀបរបបរស់នៅរបស់ពួកអ៊ីនុីកើតឡើងដោយសារអ្វី ?
6. តើគេធ្វើសញ្ជ័យទៅលើភូមិភាគមហាឧត្ដរនៃអឺរ៉ាស៊ី ដោយមធ្យោបាយណាខ្លះ ?
7. ហេតុអ្វីបានជាពោលថា "អរិយធម៌របស់ពួកអ៊ីនុីកំពុងតែត្រូវវិនាសសាបសូន្យ "?
8. តើការធ្វើសញ្ជ័យទៅលើភូមិភាគមហាឧត្ដរនៃអឺរ៉ាស៊ី ផ្ដល់នូវអត្ថប្រយោជន៍អ្វីខ្លះ ?
9. ហេតុអ្វីបានគេហៅ ទ្វីបអង់តាកទិចថា"ទ្វីបពណ៌ស " និង "ទ្វីបសន្តិភាព"?

*ពន្យល់ពាក្យ*

អរិភាព : ភាពជាខ្មាំងសត្រូវនិងគ្នា ។

សញ្ជ័យ : ការវាយដណ្ដើម ។

និសិទ្ទជន : ជនដែលរស់នៅនឹង មិនផ្លាស់ប្ដូរទីកន្លែង ។

មហាឧត្ដរ : ប៉ែកខាងជើងបំផុតនៃទ្វីប អឺរ៉ាស៊ី និងកាណាដា ។

អឺរ៉ាស៊ី : ផ្ទាំងទ្វីបដ៏ធំមួយ ដែលនៅក្នុងនោះមានទ្វីបអឺរ៉ុប និងអាស៊ី ។

អ៊ីនុី : មានន័យថា ជាតិជាមនុស្ស ពាក្យប្រើសម្គាល់អ្នកស្រុកពិភពទឹកកកមានពួកអេស្គីម៉ូ ឡាប៉ុង សាម៉ូយ៉ែត យ៉ាគូតជាដើម ។

ដោម : រាងធរណីមាត្រម្យ៉ាងមូលៗដូចផ្សិត ។

សត្វផូក : ថនិកសត្វម្យ៉ាងរស់នៅតំបន់ប៉ូលស្រដៀងសត្វផ្សោត ។

សត្វម៉ងសូ : បក្សីម្យ៉ាងមានស្លាបខ្លីៗ ជើងដូចសត្វទារស់នៅតំបន់ប៉ូលខាងត្បូង ។

សត្វការីប៊ូ : ជាសត្វរ៉ែននៅភាគខាងជើងប្រទេសកាណាដា ។

សត្វរ៉ែន : ថនិកសត្វស៊ីស្មៅស្រដៀងសត្វក្ដាន់នៅប្រទេសយើង មាននៅភាគខាងជើងអឺរ៉ាស៊ី និងខាងជើងកាណាដាចិញ្ចឹមជីវិតដោយស៊ីលីកែន ជាកម្មវត្ថុនៃការចិញ្ចឹមសត្វបែបយថាផលរបស់ពួកអ៊ីនុីសម្រាប់ជាកម្លាំងអូសទាញ យកទឹកដោះ ស្បែក និងឈើ (សាច់ឈើដុះនៅជាប់ស្នែងសព្វថ្ងៃ ) ។

# 6 ប៉ូលទាំងពីរជាកន្លែងផ្សងព្រេង

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាពីបរិស្ថានធម្មជាតិនៃតំបន់ប៉ូលទាំងពីរ
- ❑ បង្ហាញពីការបែងចែកទ្វីបអង់តាកទិច
- ❑ បង្ហាញពីសារៈសំខាន់នៃពិភពអាកទិច និងអង់តាកទិច ។

ទោះបីលក្ខខណ្ឌ នៃការរស់នៅលំបាកយ៉ាងណាក៏ដោយ ក៏ពួកមហាអំណាចចាប់ចិត្តយ៉ាងខ្លាំងទៅលើតំបន់ប៉ូលទាំងនេះ ។ ហេតុអ្វីបានជាពួកគេចង់បានវាលលំហទឹកកកមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ។

## 1. អាកទិច លំហមួយដែលគេចោមរោម

សហភាពសូវៀត និងសហរដ្ឋអាមេរិកឡោមយកឆ្នេរមហាសមុទ្រទឹកកកអាកទិចម្ខាងម្នាក់ ។ មហាប្រទេសជាគូបដិបក្ខទាំងពីរនេះ បានស្ថាបនាមូលដ្ឋានយោធាមួយចំនួនតាមបណ្តោយឆ្នេរ ។ ក្រោមផ្ទាំងបង់គីស នាវាមុជទឹកនុយក្លេអ៊ែ បើកបរយាមល្បាតចុះឡើង ។ ចំណែកនៅពីលើតំបន់ប៉ូលយន្តហោះ និងបណ្តាញរ៉ាដាប្រទេសទាំងពីរកំពុងត្រួតពិនិត្យលំហអាកាសជាអចិន្ត្រៃយ៍ ។ អាកទិចបានក្លាយទៅជាកន្លែងប្រឈមមុខដាក់គ្នា ។ តើហេតុអ្វី ?



*អាជីវកម្មប្រេងកាតនៅអាឡាស្កា*

អាកទិចជាកន្លែងសម្បូរធនធានធម្មជាតិណាស់មានកំណប់រ៉ែធំៗ ដូចជា ដែក ប្រេងកាត មាស ធ្យូងជាដើម ។ ចំណែកសមុទ្រក៏សម្បូរត្រីណាស់ដែរ ។

អណ្តូងរ៉ែជាច្រើនកំពុងធ្វើសកម្មភាព ។ ធនធានទាំងនោះត្រូវបាននាំទៅកាន់បណ្តាប្រទេសឧស្សាហកម្មរីកចម្រើន ។

ជួនកាលក្នុងការធ្វើអាជីវកម្មរ៉ែប្រេងកាត គ្រោះថ្នាក់តែងកើតមានឡើង នាំឱ្យមានការបំពុលសមុទ្រនិងគំរាមកំហែងដល់បរិស្ថានសមុទ្រដែលធ្វើឱ្យប៉ះពាល់ដល់ជីវិតសត្វក្នុងទឹក និងសត្វស្លាប ។

នៅលើកោះនានាដែលគ្របដណ្តប់ដោយទឹកកកកម្រាស់ 30m គេបានសាងសង់ភូមិឋាននិងស្ថានីយសម្រាប់ផ្តល់ព័ត៌មានវិទ្យាសាស្ត្រសំខាន់ៗ ។

## 2. ពិភពអាកទិចមិនឯកោទេ

សព្វថ្ងៃគេអាចធ្វើនាវាចរណ៍ឆ្លងកាត់មហាសមុទ្រទឹកកកអាកទិច ។ ពួកសូវៀតបានស្ថាបនានាវាបំបែកទឹកកកប្រើថាមពល នុយក្លេអ៊ែ ។ នាវាមួយឈ្មោះ អាទីកា (Artica) សម្រេចបានជោគជ័យក្នុងការធ្វើដំណើរទៅប៉ូលអាកទិចកាលពីថ្ងៃទី 17 ខែសីហា ឆ្នាំ1977 ។ ពីខែ មិថុនាដល់ខែតុលា ពួកសូវៀតបានបើកផ្លូវសមុទ្រពីមួកម៉ាន់ (Mourmann) ទៅវ្លាឌីវ៉ូស្តុក (Vladivostock) ដោយទម្លុះផ្ទាំងបង់គីស ។



*នាវាបំបែកទឹកកកប្រើថាមពលនុយក្លេអ៊ែ*

ផ្លូវអាកាសអាកទិចមមាញឹកណាស់ ។ គេហោះហើរលើតំបន់អាកទិច ដើម្បីធ្វើដំណើរពីប្រទេសជប៉ុនទៅសហរដ្ឋអាមេរិក ។ ម្យ៉ាងវិញទៀតទីក្រុងប៉ូលទាំងឡាយតែងភ្ជាប់ទំនាក់ទំនងទៅនឹងទីក្រុងធំៗនៃពិភពត្រជាក់បង្គួរតាមជើងយន្តហោះ ។

ការខិតខំរៀបចំភ្ជាប់ទំនាក់ទំនងរវាងអ្នករស់នៅតំបន់អាកទិច ធ្វើឱ្យគេចេញផុតពីបរិពន្ធភាពបាន ។ សញ្ជ័យនេះ ប្រព្រឹត្តទៅអស់ពេលជិតមួយសតវត្ស ។ ចំណែកអ្នកទេសចរក៏ផ្ដើមចាប់ចិត្តទៅលើវាលលំហទឹកកកនេះ កាន់តែច្រើនជាលំដាប់ ។

## 3. បញ្ហាបែងចែកទ្វីបអង់តាកទិច

ប្រទេសមួយចំនួន បាននាំគ្នាបែងចែកទ្វីបអង់តាកទិច តាំងពីឆ្នាំ1908មកម្ល៉េះ ។ សព្វថ្ងៃបណ្ដាប្រទេសនៅអឌ្ឍគោលខាងត្បូងមិនយល់ព្រមចំពោះទង្វើនេះទេ ។ តាមពិតគេសន្មតថា នៅក្រោមកាតិបទឹកកកដ៏ធំសម្បើមនេះមានកំណប់រ៉ែច្រើនសន្ធឹកសន្ធាប់ ។ ម្យ៉ាងទៀត គេអាចត្រួតពិនិត្យមហាសមុទ្រទាំងបីពីលើទ្វីបអង់តាកទិច និងនេសាទក្នុងដែនទឹកដ៏សម្បូរត្រីទៀតផង ។

*ទ្វីបអង់តាកទិចថតពីផ្កាយរណប*



*ការបែងចែកទ្វីបអង់តាកទិច*




- ការទាមទារទឹកដីពីដើម
- ការទាមទារទឹកដីពីសំណាក់ប្រទេសស៊ីលីនិងអាហ្សង់ទីន (1948)
- ▲ កំពូលភ្នំ
- ● ស្ថានីយសង្កេតរបស់រុស្ស៊ី
- ○ ស្ថានីយសង្កេតរបស់អាមេរិក
- ● ស្ថានីយសង្កេតរបស់បារាំង
- ● ស្ថានីយសង្កេតផ្សេងៗទៀត (រ.រ អាល្លឺម៉ង់ អាហ្វ្រិកខាងត្បូង ឥណ្ឌា ជប៉ុន អូស្ត្រាលី ចិន...)

1 រាជាណាចក្ររួម( រ.រ. )
2. ន័រវែស
3 អូស្ត្រាលី
4 សេឡង់ថ្មី( ញូសេឡែន )
5. អូស្ត្រាលី
6. បារាំង
7 អាហ្សង់ទីន
8. ឈីលី

អ៊ិនឡិនស៊ិស | បង់គីស វស្សានរដូវ | បង់គីស សិសិររដូវ | ទឹកកកអណ្ដែត

***សន្និដ្ឋាន*** : តំបន់ប៉ូល ជាលំហធំចេងចុងក្រោយ ដែលត្រូវធ្វើការរុករក ។ មហាវាលលំហទឹកកកកំពុងត្រូវបានចាប់ផ្ដើមធ្វើអាជីវកម្ម ហើយក៏ជាកម្មវត្ថុនៃការប៉ងចង់បានរបស់ប្រទេសធំៗផងដែរ ។

## មេរៀនសង្ខេប

- អាកទិចជាកន្លែងសម្បូរធនធានធម្មជាតិណាស់ ។ សព្វថ្ងៃគេអាចធ្វើនាវាចរណ៍ឆ្លងកាត់មហាសមុទ្រទឹកកកអាកទិចបានដោយជោគជ័យ ។ នៅតំបន់នេះសកម្មភាពអាជីវកម្មមានជំនឹកយករ៉ែ នាវាចរណ៍ អាកាសចរណ៍ នេសាទ និងទេសចរណ៍ផងដែរ ។
- ប្រទេសមួយចំនួនបាននាំគ្នាបែងចែកទ្វីបអង់តាកទិច ដោយគេសន្មតថាទ្វីបនេះមានកំណប់រ៉ែច្រើនសន្ធឹកសន្ធាប់ ។

## សំណួរ

1. តើសហភាពសូវៀតនិងសហរដ្ឋអាមេរិកបានធ្វើសកម្មភាពអ្វីខ្លះនៅតំបន់អាកទិច ?
2. តើតំបន់អាកទិចសម្បូរធនធានអ្វីខ្លះ ? ចូរនិយាយពីការធ្វើអាជីវកម្មរ៉ែនៅតំបន់អាកទិច ។
3. តើគេអាចធ្វើនាវាចរណ៍ឆ្លងកាត់មហាសមុទ្រអាកទិចបានដោយវិធីណា ?
4. តើផ្លូវអាកាសអាកទិចមានសកម្មភាពដូចម្ដេចដែរ ?
5. សព្វថ្ងៃអ្នករស់នៅតំបន់អាកទិចលែងស្ថិតនៅក្នុងភាពឯកោទៀតហើយ ។ មូលហេតុអ្វី ?
6. តំបន់អាកទិចមានអ្នកទេសចរចេញចូលទៅកម្សាន្តដែរឬទេ ? ព្រោះអ្វី ?
7. តើប្រទេសមហាអំណាចណាខ្លះ ដែលដណ្ដើមកាន់កាប់ទឹកដីទ្វីបអង់តាកទិច ? តើប្រទេសណាខ្លះដែលមិនយល់ព្រមទៅនឹងទង្វើនេះ ?
8. តើការនាំគ្នាបែងចែកទឹកដីទ្វីបអង់តាកទិច ជាទង្វើមួយត្រឹមត្រូវដែរឬទេ ? ព្រោះអ្វី ?
9. អាកទិចក្លាយជាកន្លែងប្រឈមមុខដាក់គ្នា ព្រោះអ្វី ?
10. តើអាជីវកម្មរ៉ែប្រេងកាតនាំមកនូវផលប៉ះពាល់អ្វីខ្លះ ?
11. តើផ្លូវអាកាសអាកទិចមានសកម្មភាពមមាញឹកដែរឬទេ ? ចូរពន្យល់ ។
12. អ្នកទេសចរផ្ដើមចាប់ចិត្តទៅលើវាលលំហទឹកកក ព្រោះហេតុអ្វី ?
13. "ពិភពអាកទិចមិនឯកោទេ"តើដូច្នេះមែនឬទេ ? ចូរពន្យល់ ។
14. ហេតុអ្វីបានជាប្រទេសធំៗ ប៉ងកាន់កាប់ទឹកដីនៃទ្វីបអង់តាកទិចគ្រប់ៗគ្នា ?
15. ប្រទេសធំៗ នាំគ្នាបែងចែកទឹកដីទ្វីបអង់តាកទិច ។ ទង្វើបែបនេះអាចនាំឆ្ពោះទៅរកអរិភាពនឹងគ្នា ។ តើទ្វីបអង់តាកទិចអាចជា "ទ្វីបសន្តិភាព" បានដែរឬទេ ? ចូរបញ្ជាក់ ។
16. ចូរប្រៀបធៀបលក្ខខណ្ឌធម្មជាតិតំបន់ប៉ូលទៅនឹងលក្ខខណ្ឌធម្មជាតិកម្ពុជា ។

*ពន្យល់ពាក្យ*

នុយក្លេអ៊ែ ៖ ថាមពលដែលមាននៅក្នុងអាតូម ។

បរិពន្ធភាព ៖ ភាពបិទជិតមិនអាចមានទំនាក់ទំនងទៅទីដទៃទៀតបានដោយងាយស្រួលឡើយ ។

## ? សំណួរជំពូក 2

**I ចូរគូសសញ្ញា ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវតែមួយគត់៖**

1. ផ្នូកខ្សាច់ធំៗនៃតំបន់វាលលំហហៅថា ៖

☐ក. រ៉ុច ☐ខ. អ៊ែក ☐គ. អូាស៊ីស ☐ឃ. រើត ។

2. ផ្ទាំងទឹកកកដែលកើតនៅក្នុងមហាសមុទ្រមានកម្រាស់ពី 2 ទៅ 3 m ហៅថា ៖

☐ក. ផ្កាទឹកកក ☐ខ. បង់គីស ☐គ. អាយស៊ើរ ☐ឃ. កាតិបទឹកកក ។

**II ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖**

1. ប្រេងកាតមានឈ្មោះម្យ៉ាងទៀតហៅថា .............. ។

2. ទ្វីបអង់តាកទិចមានឈ្មោះម្យ៉ាងទៀតហៅថា .............. ។

**III ចូរផ្គូផ្គងផ្នែក A និង B រួចសរសេរចម្លើយក្នុងផ្នែក C ឱ្យបានត្រឹមត្រូវ ៖**

| A | B | C ( ចម្លើយ) |
|---|---|---|
| 1. តំបន់ប៉ូល | ក. ភ្លៀងធ្លាក់ស្ទើររាល់ថ្ងៃ | 1 ⟶ |
| 2. តំបន់ត្រូពិចស្ងួត | ខ. ព្រះអាទិត្យកណ្ដាលអធ្រាត្រ | 2 ⟶ |
| 3. តំបន់ត្រូពិចសើម | គ. វាលស្មៅ វាលស្តិប និងវាលលំហ | 3 ⟶ |
| | ឃ. រដូវប្រាំងមួយ និងរដូវវស្សាមួយក្នុងមួយឆ្នាំ | |

**IV ចូរឆ្លើយសំណួរខាងក្រោម ៖**

1. " វាលលំហជាឃ្លាំងស្តុកធនធានរ៉ែដ៏ច្រើន" តើធនធានរ៉ែនៅទីនោះមានសារៈសំខាន់សេដ្ឋកិច្ចអ្វីខ្លះ ?

2. ការបញ្ចូលទឹកតាមបែបទំនើបបានកែប្រែអូាស៊ីសពិតមែនហើយ ។ តើបច្ចេកទេសកសិកម្មបែបនេះផ្តល់នូវអត្ថទោសអ្វីខ្លះ ?

3. ប្រទេសមួយចំនួននាំគ្នាដណ្តើមកាន់កាប់ទឹកដីនៃទ្វីបអង់តាកទិច ។ តើទង្វើនេះត្រឹមត្រូវដែរឬទេ ? ព្រោះអ្វី ? ចូរពន្យល់ ។

# ជំពូកទី 3 មណ្ឌលអាកាសធាតុកំណត់ដំណុះប្រជាជន

*ផែនទីបង្ហាញពីតំបន់ប៉ូល តំបន់ត្រជាក់បង្គួរ និងតំបន់ក្តៅ*




ក្នុងជំពូកមេរៀនមុនៗ យើងបានសិក្សារួចមកហើយអំពីមជ្ឈដ្ឋានក្តៅ តំបន់វាលលំហ និងតំបន់ប៉ូល ។ ដូចនេះជាបន្តទៀត យើងនឹងលើកយកជំពូកមួយទៀតមកសិក្សាអំពីមណ្ឌលអាកាសធាតុកំណត់ដំណុះប្រជាជន ។

តើអាកាសធាតុ អាចពន្យល់ពីរបាយប្រជាជនលើភពផែនដីបានដែរឬទេ?

ហេតុអ្វីបានជាតំបន់មួយចំនួន ដែលមានអាកាសធាតុដូចគ្នាបេះបិទ តែមានប្រជាជនរស់នៅខ្លះច្រើន ខ្លះតិចបែបនេះទៅវិញ ?

មេរៀនទី

# 1 មនុស្សនិងមណ្ឌលអាកាសធាតុ

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីមណ្ឌលអាកាសធាតុទាំងប្រាំនៃភពផែនដី
- រៀបរាប់ពីឥទ្ធិពលនៃមណ្ឌលអាកាសធាតុទាំងនោះលើដំណុះប្រជាជន
- កំណត់ពីកត្តាដំណុះប្រជាជនកម្ពុជាយើង ។

កន្លងមក យើងបានសិក្សា និងយល់ដឹងពីឥទ្ធិពលអាកាសធាតុទៅលើជីវភាពរស់នៅរបស់ប្រជាជនក្នុងមជ្ឈដ្ឋានមួយចំនួន ។ តទៅនេះយើងនឹងសិក្សាស្វែងយល់ពីរបាយមណ្ឌលអាកាសធាតុ និងរបាយប្រជាជនមិនស្មើគ្នាលើភពផែនដី ។ តើមណ្ឌលអាកាសធាតុ ជាកត្តាកំណត់តែមួយគត់គ្មានពីរនៃរបាយប្រជាជនមិនស្មើគ្នាបែបនេះឬទេ ?

## 1. មណ្ឌលអាកាសធាតុទាំងប្រាំ

មណ្ឌលក្តៅស្ថិតនៅតំបន់ក្បែរៗចន្លោះត្រូពិចទាំងពីរ ។ ក្នុងតំបន់ទាំងនោះ គ្មានសិសិររដូវទេ ដោយហេតុថា សីតុណ្ហភាពមធ្យមនៃខែត្រជាក់បំផុត ស្ថិតនៅខ្ពស់ជាង + 18°C ជានិច្ច ពោលគឺមានរដូវពីរ គឺរដូវវស្សា និងរដូវប្រាំងដែលកើតឡើងបន្តបន្ទាប់គ្នាក្នុងមួយឆ្នាំ ។




*មណ្ឌលអាកាសធាតុទាំងប្រាំ*

នៅមណ្ឌលអាកាសធាតុប៉ូលទាំងពីរគ្មានរដូវក្តៅទេ ។ សីតុណ្ហភាពមធ្យមប្រចាំខែស្ថិតនៅក្រោម +10°C ជានិច្ច ។ តំបន់ទាំងនោះស្ថិតនៅក្នុងភាពងងឹតនៃរាត្រីប៉ូលអស់ពេលជាច្រើនខែ និងមានព្រះអាទិត្យរះជានិច្ចនាបណ្តាខែដែលមិនសូវត្រជាក់ ។ រយៈពេលវែងនៃថ្ងៃនិងយប់កំណត់បានរដូវពីរ គឺវស្សានរដូវ ( ព្រះអាទិត្យកណ្តាលអធ្រាត្រ) និងសិសិរដូវ ( រាត្រីប៉ូល ) ។

នៅចន្លោះមណ្ឌលអាកាសធាតុក្តៅ និងត្រជាក់ គឺជាមណ្ឌលអាកាសធាតុត្រជាក់បង្គួរ ។ បន្ទាប់ពីសិសិររដូវត្រជាក់ខ្លាំង ដែលមានយប់យូរ គឺជាវស្សានរដូវក្តៅខ្លាំង ដែលមានថ្ងៃយូរវិញម្តង ។ មណ្ឌលនេះមានរដូវបួន យ៉ាងទៀងទាត់ គឺសិសិររដូវ និទាឃរដូវ វស្សានរដូវ និងសរទរដូវ ។

ផ្ទាំងទេសភាពមួយទៀតបានមកផ្តាច់របាយមណ្ឌលអាកាសធាតុដ៏ល្អខាងលើនេះ គឺតំបន់វាលលំហ ។ ពីសាហារ៉ាដែលស្ថិតតាមបណ្តោយខ្សែត្រូពិចខាងជើង រហូតដល់ប្រទេសម៉ុងហ្គោលីនៃរយៈទទឹងត្រជាក់បង្គួរ ភាពស្ងួតហែងបង្កើតបានជាទេសភាពប្លែកៗនៅទីនោះ ។

## 2. ព្រះអាទិត្យកម្តៅផែនដីមិនស្មើ

នៅតំបន់ប៉ូល ព្រះអាទិត្យរះនៅងជើងមេឃជានិច្ច ។ ផ្ទុយទៅវិញនៅតំបន់ត្រូពិច ព្រះអាទិត្យរះខ្ពស់នៅលើមេឃ ហើយធ្វើដំណើរមកនៅចំពីលើក្បាលយើងពីរដងក្នុងមួយឆ្នាំ ។

នៅតំបន់ត្រជាក់បង្គួរព្រះអាទិត្យមិនដែលរះចំពីលើក្បាលមនុស្សលោកម្តងណាឡើយ ទោះបីជានៅរដូវណាក៏ដោយ ។ នៅសិសិររដូវថ្ងៃមានរយៈពេលខ្លី តែក៏គ្មានរាត្រីប៉ូលដែរ ។



ថ្ងៃត្រង់ក្រោមខ្សែត្រូពិច



ថ្ងៃត្រង់នៅប៉ូលខាងជើង

## 3. មណ្ឌលអាកាសធាតុ និងដំណុះប្រជាជន

តំនាបសង្កត់ពិចម្មជាតិ មានភាពត្រជាក់ហួសហេតុ និងកង្វះទឹកពន្យល់បានពីភាពខ្សត់មនុស្ស នៅមជ្ឈដ្ឋានប៉ូល និងមជ្ឈដ្ឋានស្ងួតហែង ។ ការរស់នៅរបស់មនុស្សក្នុងតំបន់ភ្នំក៏ជួបការលំបាកដែរ ។ គេសង្កេតឃើញជួរភ្នំធំៗនៅតែមានមនុស្សរស់នៅតិចជាងទីទំនាបជុំវិញនោះ ។

ម្យ៉ាងទៀត នៅតំបន់ត្រជាក់បង្គួរ និងតំបន់ក្តៅ មជ្ឈដ្ឋានខ្លះមានលក្ខណៈអាកាសធាតុដូចៗគ្នា តែមានដំណុះប្រជាជនមិនដូចគ្នាទេ ។ ដូចនេះ អាកាសធាតុមិនអាចពន្យល់ពីភាពខុសគ្នានៃដំណុះប្រជាជនក្នុងមជ្ឈដ្ឋានទាំងនោះបានឡើយ ។ យើងតែងតែឆ្ងល់ខ្លួនឯងថា ម្តេចក៏នៅតំបន់អាកាសធាតុប្រភេទដូចគ្នា កន្លែងខ្លះមានមនុស្សរស់នៅកុះករ ហើយកន្លែងខ្លះទៀតស្ទើរតែគ្មានមនុស្សរស់នៅ ។

***សន្និដ្ឋាន :*** ព្រះអាទិត្យកម្តៅផែនដីមិនបានស្មើគ្នាទេ ដោយសារភពនេះមានរាងមូល ។ តំបន់ក្តៅ និងត្រជាក់បង្គួរមានដង់ស៊ីតេប្រជាជនខ្ពស់បំផុត លើកលែងតែតំបន់វាលលំហាចេញ ។ តំនាបសង្កត់ពិចម្មជាតិ ដើរតួនាទីយ៉ាងសំខាន់ក្នុងរបាយប្រជាជនលើផ្ទៃផែនដីមែនហើយ តែក៏មិនអាចពន្យល់អ្វីឱ្យបានគ្រប់គ្រាន់ឡើយ ។

**មេរៀនសង្ខេប**

- មណ្ឌលក្តៅស្ថិតនៅតំបន់ក្បែរចន្លោះត្រូពិចទាំងពីរគ្មានសិសិររដូវទេ ។ ចំណែកមណ្ឌលប៉ូលគឺមានតែរដូវមួយគឺសិសិររដូវ ។ ឯមណ្ឌលត្រជាក់បង្គួរមានបួនរដូវ គឺសិសិររដូវ និទាឃរដូវ វស្សានរដូវ និងសរទរដូវ ។
- ម្យ៉ាងទៀត មជ្ឈដ្ឋានខ្លះមានលក្ខណៈអាកាសធាតុដូចៗគ្នា តែដំណុះប្រជាជនមិនដូចគ្នាទេ ។ ដូចនេះ អាកាសធាតុមិនអាចកំណត់ពីភាពខុសគ្នានៃដំណុះប្រជាជនក្នុងមជ្ឈដ្ឋានទាំងនេះបានឡើយ ។

**? សំណួរ**

1. តើអាកាសធាតុនៅលើផែនដី ចែកចេញជាប៉ុន្មានមណ្ឌល ? អ្វីខ្លះ ?
2. តើមជ្ឈដ្ឋានក្តៅមានលក្ខណៈអាកាសធាតុដូចម្តេច ?
3. តើមជ្ឈដ្ឋានត្រជាក់បង្គួរមានលក្ខណៈអាកាសធាតុដូចម្តេច ?
4. តើមជ្ឈដ្ឋានប៉ូលមានលក្ខណៈអាកាសធាតុដូចម្តេច ?
5. ក្រៅពីនេះ តើមានមណ្ឌលអាកាសធាតុណាផ្សេងទៀតទេ ?

6. តើមណ្ឌលអាកាសធាតុទាំងនោះ អាចពន្យល់ពីដំណុះប្រជាជនបានដែរឬទេ ?
7. ហេតុអ្វីបានជាតំបន់ចន្លោះត្រូពិចគ្មានសិសិររដូវ ? តើតំបន់នេះមានរដូវអ្វីខ្លះ ?
8. ហេតុអ្វីបានជាតំបន់ប៉ូលទាំងពីរគ្មានរដូវក្តៅ ? តើនៅតំបន់ប៉ូលមានបាតុភូតគួរជាទីចាប់អារម្មណ៍អ្វីខ្លះ ?
9. តើមណ្ឌលអាកាសធាតុត្រជាក់បង្គួរស្ថិតនៅត្រង់ណា ? មានរដូវអ្វីខ្លះ ?
10. តើអ្នកយល់ដឹងអ្វីខ្លះពីតំបន់វាលលំហ ? ចូរបង្ហាញពីចំណុចពិសេសៗឱ្យបានច្រាំយ៉ាងតិច ។
11. មណ្ឌលអាកាសធាតុកំណត់ដំណុះប្រជាជនក៏ពិតមែនហើយ តែគេឃើញតំបន់ខ្លះមានលក្ខណៈអាកាសធាតុដូចគ្នា តែមានដំណុះប្រជាជនមិនស្មើគ្នាទេ ។ ចូរបង្ហាញ និងបញ្ជាក់ដោយលើកឧទាហរណ៍ ។

***ពន្យល់ពាក្យ***

និទាឃរដូវ : " រដូវក្តៅ" មាន 3 ខែ រាប់ពីថ្ងៃទី 21 ខែ មីនា ដល់ថ្ងៃទី 21 ខែ មិថុនា មាន 93 ថ្ងៃ ។

វស្សានរដូវ : " រដូវភ្លៀង" មាន 3 ខែ រាប់ពីថ្ងៃទី 22 មិថុនា ដល់ថ្ងៃទី 22 ខែ កញ្ញា មាន 93 ថ្ងៃ ។

សរទរដូវ : " រដូវចុះអ័ព្ទ ឬរដូវមានខ្យល់ ភ្លៀង ទឹកសន្សើមខ្លះ រដូវរំហើយ" មាន 3 ខែ រាប់ពីថ្ងៃទី 23 ខែ កញ្ញា ដល់ថ្ងៃទី 21 ខែ ធ្នូ មាន 90 ថ្ងៃ ។ ។

សិសិររដូវ : " រដូវរងាខ្លាំង" មាន 3 ខែ រាប់ពីថ្ងៃទី 22 ខែ ធ្នូ ដល់ថ្ងៃទី 20 ខែ មីនា មាន 89 ថ្ងៃ ឬជួនកាល 90 ថ្ងៃ ។

# 2 មនុស្សរៀបចំដែនដីទៅតាមអរិយធម៌របស់ខ្លួន

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីការរៀបចំដែនដីនៅតំបន់អាម៉ាសូនី និងនៅកោះជ្វា ដែលមានលក្ខណៈអាកាសធាតុដូចគ្នា
- ❑ កំណត់ច្បាស់អំពីការរៀបចំដែនដីនៃមាតុភូមិរបស់ខ្លួន ។

ក្រោមអាកាសធាតុក្តៅសើមនៃតំបន់អេក្វាទ័រ អាម៉ាសូនី និងកោះជ្វា មានដំណុះប្រជាជន និងការរៀបចំដែនដីតាមរបៀបផ្សេងពីគ្នា ។ ព្រោះអ្វី ?

## 1. អាម៉ាសូនី : ទំនាបមួយក្តៅសើមតែខ្សត់មនុស្ស

អាម៉ាសូនីឬ" នរកបៃតង" ជាព្រៃស្តុកនៅទ្វីបអាមេរិកខាងត្បូង លាតសន្ធឹងលើប្រទេសជាច្រើន ពិសេសលើប្រទេសប្រេស៊ីលមានផ្ទៃប្រហែល 7លាន $km^2$ ( ធំជាងប្រទេសកម្ពុជាជាង 38 ដង) រស់នៅដោយកុលសម្ព័ន្ធឥណ្ឌា តាំងពីយូរលង់ណាស់មកហើយ ។ ពួកឥណ្ឌាទាំងនោះមានតិចតួចណាស់ ហើយ ចំនួននេះបានចុះថយជាលំដាប់នាអំឡុងសតវត្សទី 20 គឺពីមួយលាននាក់នៅឆ្នាំ1900 មកនៅត្រឹម 220 000 នាក់ នៅឆ្នាំ1957 ។ មូលហេតុសំខាន់គឺជំងឺរាតត្បាតដ៏សាហាវៗនិងឥទ្ធិពលនៃកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច តំបន់អាម៉ាសូនីរបស់រដ្ឋាភិបាលប្រេស៊ីលផងដែរ ។ ពួកជនឥណ្ឌាទាំងនោះរស់នៅដោយពឹងផ្អែកលើព្រៃឈើ ប្រកបរបរបេះផ្លែឈើ បរបាញ់សត្វ នេសាទ និងដំណាំពនេចរ ។



*ពួកឥណ្ឌានេសាទត្រីនៅតាមទន្លេអាម៉ាសូន*

រហូតមកដល់បណ្តាឆ្នាំ1960 ព្រៃអាម៉ាសូនីមិនទាន់ត្រូវបានប៉ះពាល់ទេ ។ អាជីវកម្មរបស់ពួកកុលសម្ព័ន្ធឥណ្ឌាទាំងនោះ ជះឥទ្ធិពលតិចតួចណាស់ទៅលើអត្ថិភាពព្រៃឈើ ។ ចាប់ពីឆ្នាំ 1970 មក កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចបានធ្វើឱ្យបាត់បង់ព្រៃឈើក្នុងល្បឿនមួយគួរជាទីចាប់អារម្មណ៍ គឺជាង 30 000 $km^2$ ក្នុងមួយឆ្នាំ ។ មកទល់បច្ចុប្បន្ននេះ គេបានប៉ាន់ស្មានថា ព្រៃអាម៉ាសូនីត្រូវបានបំផ្លិចបំផ្លាញអស់ពី 300 000 ទៅ 400 000 $km^2$ ។ កម្មវិធីនិគមកម្ម សំណង់ផ្លូវថ្នល់កាត់ព្រៃអាម៉ាសូនី អាជីវកម្មឈើ និងរ៉ែ ការបង្កើតកសិដ្ឋានចិញ្ចឹមគោធំៗនិងការមកដល់ទាំងក្រុមៗនៃប្រជាជនប្រេស៊ីលពីតំបន់ផ្សេងៗ ពិសេសពីភាគឦសាន និងភាគខាងត្បូងមករស់នៅតាមបណ្តោយផ្លូវថ្នល់ទាំងនោះ ធ្វើឱ្យចំនួនមនុស្ស និងទេសភាពធម្មជាតិប្រែប្រួលយ៉ាងខ្លាំង ។ ប្រជាជនតំបន់អាម៉ាសូនីបានកើនឡើងបីដងក្នុងរយៈពេល 30ឆ្នាំ គឺពី 5.6 លាននាក់នៅឆ្នាំ1960 និងប្រហែល 17 លាននាក់នៅឆ្នាំ1991 ។

បច្ចុប្បន្ននេះ មានប្រហែលជាង 20 លាននាក់ ។ ទន្ទឹមនឹងនោះ គេឃើញពួកជនជាតិឥណ្ឌាមួយចំនួនត្រូវបានបណ្តេញចេញពីទឹកដីដែលធ្លាប់រស់នៅតាំងពីដូនតាមកម្លេះ ។



*ការដ្ឋានសំណង់ផ្លូវថ្នល់ក្នុងព្រៃអាម៉ាសូនី*

## 2. កោះជ្វា : បណ្តុំប្រជាជនដ៏កុះករមួយនៅលើភ្នំ

កោះជ្វា ជាកោះភ្នំភ្លើងមួយរបស់ប្រទេសឥណ្ឌូណេស៊ីមានផ្ទៃដី 126 700 $km^2$ ( ស្មើពីរភាគបីនៃផ្ទៃដីកម្ពុជា) មានប្រជាជនដល់ទៅ 130 លាននាក់ ( ឆ្នាំ2006) គិតជាដង់ស៊ីតេមាន 1026 នាក់ /$km^2$ ។ តើប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះ អាចរស់នៅទីនោះបានដោយរបៀបណា ?

ដើម្បីចិញ្ចឹមប្រជាជនដ៏ច្រើន ក្នុងមជ្ឈដ្ឋានមួយដ៏លំបាក ពួកគេបានរៀបចំចំណោតភ្នំជាស្រែថ្នាក់ ហើយបានគាស់រានព្រៃអេក្វាទ័រត្រង់ទីទំនាបសម្រាប់ធ្វើស្រែ ។ ភាគច្រើននៃកម្មសិទ្ធិដីធ្លីមានទំហំតូចជាងមួយហិកតា តែអាចផលិតស្រូវបំពេញតម្រូវការហូបចុកក្នុងគ្រួសារបានគ្រប់គ្រាន់ ។

តើគេអាចអនុវត្តប្រព័ន្ធកសិកម្មអតិផលដូចគ្នានឹងដំណាំច្បារបានយ៉ាងដូចម្ដេច ?




*ប្រព័ន្ធកសិកម្មទំនើបនៅកោះជ្វា*

សង្គមកសិករកោះជ្វាសម្រេចបានការកសាងប្រព័ន្ធបញ្ចូលទឹក ដែលគេអាចដាំដុះបានពេញមួយឆ្នាំ ។ប្រជាជនដ៏ច្រើនទទួលបានការគ្រប់គ្រងល្អ និងមានវិន័យត្រឹមត្រូវបានសាងសង់ទំនប់និងប្រឡាយដែលអាចនាំទឹកទៅកាន់ស្រែចម្ការច្បារដំណាំនីមួយៗ បានថែរក្សាស្រែថ្នាក់និងភ្លឺស្រែយ៉ាងហ្មត់ចត់ទៀតផង ។ សង្គមជ្វាបានធ្វើអាជីវកម្មក្នុងមជ្ឈដ្ឋានមួយដ៏លំបាក ប្រកបដោយជោគជ័យព្រោះពួកគេយល់ច្បាស់ពីបច្ចេកទេសបញ្ចូលទឹក និងចេះធ្វើការងារសុវុឌ្ឍិកម្មធំៗសម្រេចឡើងបាន ។

***សន្និដ្ឋាន*** : ពេលដែលសង្គមមនុស្សមានចំណេះដឹងខាងបច្ចេកទេស និងទទួលបានការគ្រប់គ្រងល្អផងនោះ ពួកគេក៏សម្រេចបានជោគជ័យក្នុងការរៀបចំដែនដីរបស់ខ្លួន ដើម្បីទាញយកអស់លទ្ធភាពពីធនធានដែលមាន ។ ផ្ទុយទៅវិញ ពេលសង្គមមនុស្សមានមធ្យោបាយបច្ចេកទេសខ្សោយឬក៏គ្មានបំណងប្រាថ្នាចង់ផ្លាស់ប្ដូររបៀបរបបរស់នៅផងទេនោះ ធនធានដែលមាននៅលើទឹកដីក៏មិនត្រូវបានធ្វើអាជីវកម្មទាំងអស់ដែរ ។ តែគេឃើញសង្គមមនុស្សផ្សេងៗទៀត ដែលមានបច្ចេកទេសខ្ពស់បានចូលមកធ្វើអាជីវកម្មទាញយកផលចំណេញពីធនធានទាំងនោះទៅវិញ ដូចជាករណី អាម៉ាសូនីនេះឯងជាឧទាហរណ៍ស្រាប់ ។

## មេរៀនសង្ខេប

- អាម៉ាសូនីជាព្រៃស្តុកនៃទ្វីបអាមេរិកខាងត្បូង មានផ្ទៃដីប្រហែល 7 លាន $km^2$ ។ តាំងពីយូរមក ហើយមានកុលសម្ព័ន្ធឥណ្ឌារស់នៅប្រកបរបរបេះផ្លែឈើ បរបាញ់សត្វ នេសាទ... ។ ក្រោយមកមានប្រជាជនប្រេស៊ីលទាំងក្រុមៗពីតំបន់ផ្សេងៗចូលមករស់នៅធ្វើឱ្យចំនួនមនុស្ស និងទេសភាពមានការប្រែប្រួលយ៉ាងខ្លាំង ។
- កោះជ្វាមានប្រជាជន 130 លាននាក់រស់នៅ ។ ដើម្បីចិញ្ចឹមជីវិតពួកគេបានរៀបចំចំណោតភ្នំធ្វើជាស្រែថ្នាក់ ហើយគាស់រានព្រៃត្រង់ទីទំនាបសម្រាប់ធ្វើស្រែចម្ការ ។ សង្គមកសិករកោះជ្វាបានសម្រេចជោគជ័យក្នុងការកសាងប្រព័ន្ធបញ្ចូលទឹកដែលគេអាចដាំដុះបានពេញមួយឆ្នាំ ។

## សំណួរ

1. ហេតុអ្វីបានជាព្រៃអាម៉ាសូនីមានឈ្មោះម្យ៉ាងទៀតថា " នរកបៃតង " ?
2. តើក្នុងព្រៃស្តុកនេះ មានមនុស្សរស់នៅដែរឬទេ ? ចូរពន្យល់ ។
3. តើព្រៃអាម៉ាសូនីត្រូវគេបំផ្លាញខ្លាំងចាប់ពីពេលណាមក ? ហើយនាំមកនូវផលវិបាកអ្វីខ្លះ ?
4. កោះជ្វាជាកោះភ្នំភ្លើងមានផ្ទៃដីតូច តែប្រជាជនច្រើន ។ តើពួកគេរស់នៅក្នុងមជ្ឈដ្ឋានមួយដ៏លំបាកបែបនេះ ដោយរបៀបណា ?
5. តើពួកកុលសម្ព័ន្ធនៃព្រៃអាម៉ាសូនីប្រកបរបរអ្វីខ្លះ ? តើទង្វើរបស់ពួកគេបានធ្វើឱ្យប៉ះពាល់ដល់អត្ថិភាពព្រៃអាម៉ាសូនីយ៉ាងណាដែរ ?
6. តើចំនួនមនុស្សតំបន់អាម៉ាសូនីប្រេស៊ីល និងទេសភាពធម្មជាតិមានបម្រែបម្រួលខ្លាំងដោយសារមូលហេតុអ្វីខ្លះ ?
7. ចូរនិយាយអំពីប្រព័ន្ធកសិកម្មអតិផលរបស់កសិករកោះជ្វា ។
8. តើដំណុះប្រជាជននៅលើកោះជ្វាអាស្រ័យនឹងកត្តាអ្វីខ្លះ ?
9. តើដំណុះប្រជាជនតំបន់អាម៉ាសូនីមានដំណើរវិវត្តដូចម្តេច ? តើមានទំនាក់ទំនងទៅនឹងកត្តាអ្វីខ្លះដែរ ?

*ពន្យល់ពាក្យ*

នរកបៃតង : ពាក្យប្រើសម្រាប់សម្គាល់ព្រៃស្តុកអាម៉ាសូនី ព្រោះជាព្រៃគ្រាស់ពិបាកចេញចូល ប្រកបដោយសត្វសាហាវៗ និងមានលក្ខណៈងងឹតឈ្លប់ ប្រៀបបាននិងឋាននរក ។

និគមកម្ម :ការទៅតាំងទីបង្កបង្កើនផលនៅលើដីថ្មី ។

សុវត្ថិកម្ម : ការធ្វើឱ្យមានការរីកចម្រើនល្អ ។

មេរៀនទី

# 3 ប្រៀបធៀបជីវភាពប្រជាជនក្នុងតំបន់ទាំងបី

**ចប់មេរៀននេះ សិស្សអាច**

- ប្រៀបធៀបជីវភាពប្រជាជនតំបន់ក្ដៅ តំបន់វាលលំហ និងតំបន់ប៉ូល
- កំណត់បានពីកត្តាដែលមានភាពប្រហាក់ប្រហែលគ្នាឬខុសគ្នា និងកត្តានៃបម្រែបម្រួលជីវភាព ។

អាកាសធាតុ ជាកត្តាកំណត់ការរស់នៅរបស់ប្រជាជន និងក៏ជាកត្តាបង្កើតឱ្យមានអរិយធម៌ប្រចាំតំបន់នីមួយៗដែរ ។ តាមការសិក្សាកន្លងមក យើងឃើញថា ក្រោមឥទ្ធិពលអាកាសធាតុផ្សេងគ្នា របៀបរបបរស់នៅរបស់ប្រជាជនក៏ខុសប្លែកគ្នាដែរ ។ ផ្ទុយទៅវិញ ក្រោមឥទ្ធិពលអាកាសធាតុដូចគ្នា របៀបរបបរស់នៅរបស់ប្រជាជន ក៏មិនមែនសុទ្ធតែដូចគ្នាទាំងអស់នោះទេ ។ ទន្ទឹមនឹងនេះ យើងក៏សង្កេតឃើញផងដែរថា សង្គមមនុស្សមានការវិវត្តជានិច្ច គ្រាន់តែតិចឬច្រើន យឺតឬលឿនតែប៉ុណ្ណោះ ។ តើមូលហេតុអ្វីខ្លះទៅ ?

## 1. ជីវភាពប្រជាជនតំបន់អេក្វាទ័រ




*ការរៀបចំតំបន់អាម៉ាសូនី*

កោះជ្វានិងអាម៉ាសូនី ជាតំបន់ពីរ ស្ថិតក្រោមឥទ្ធិពលអាកាសធាតុអេក្វាទ័រដូចគ្នា៖

កោះជ្វាមានដំណុះប្រជាជនខ្ពស់។ អ្នកស្រុកកោះជ្វាចេះរៀបចំដីធ្លីបង្កបង្កើនផល ដោយអនុវត្តដំណាំអតិផល ដែលអាចបំពេញតម្រូវការហូបចុករបស់ប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់បានគ្រប់គ្រាន់។ នៅលើកោះនេះ មានទីក្រុងសំខាន់ៗដូចជា រដ្ឋធានីចាកាតានិងទីក្រុងសូរ៉ាបាយ៉ាជាដើម។

ផ្ទុយទៅវិញ អាម៉ាសូនីមានដំណុះប្រជាជនខ្សោយ។ អ្នកស្រុកដើមអាម៉ាសូនីរស់នៅយ៉ាងលំបាកលំបិនក្នុង" នរកបៃតង " ដោយបេះផ្លែឈើ បរបាញ់សត្វ នេសាទ និងធ្វើចម្ការព្រៃដុត។ ការអនុវត្តកម្មវិធីនិគមកម្មតំបន់អាម៉ាសូនីរបស់រដ្ឋាភិបាលប្រេស៊ីល នាំឱ្យពួកឥណ្ឌាមួយចំនួនបាត់បង់ដីធ្លី និងនាំឱ្យមានចលនាបំលាស់ទីលំនៅក្នុងស្រុកថ្មីៗយ៉ាងច្រើនសន្ធឹកសន្ធាប់មករស់នៅតាមដងផ្លូវនានាកាត់អាម៉ាសូនី ដែលជាកត្តាសំខាន់នៃកំណើនប្រជាជននិងកំណើននគរូបនីយកម្មនៅតំបន់នោះ។

## 2. ជីវភាពប្រជាជនអាស៊ីមូសុង និងតំបន់សាហែល

តំបន់ទាំងពីរនេះមានរដូវពីរ គឺពេលដែលរដូវប្រាំងមួយបានកន្លងផុតទៅ រដូវវស្សាមួយក៏មកដល់។ កសិករតែងរង់ចាំភ្លៀងដំបូង ដោយក្ដីអន្ទះសា ដើម្បីចាប់ផ្ដើមការងារបង្កបង្កើនផល។

កសិករអាស៊ីមូសុង អនុវត្តវិធីដាំដុះច្រើនបែបយ៉ាង មានដំណាំព្រៃដុត ដំណាំយថាផល និងដំណាំអតិផល។ ការបញ្ចូលបច្ចេកទេសកសិកម្ម( បម្រើបម្រាស់ដី ពូជ ការបញ្ចូលទឹក...) ទៅក្នុងផលិតកម្ម នាំឱ្យដំណាំស្រូវផ្ដល់ផលច្រើន ហើយគ្រោះទុរ្ភិក្សលែងកើតមានដូចពេលមុនៗទៀតហើយ។ ដំណាំស្រូវនៅអាស៊ីមូសុងបង្កើតឱ្យមានអរិយធម៌មួយហៅថា " អរិយធម៌ស្រូវ" ដូចគ្នានិងស្រូវសាលីដែរដែលបង្កើតឱ្យមាន" អរិយធម៌ស្រូវសាលី "។



*កសិករអាហ្វ្រិកកំពុងដាក់ជីដំណាំពោត*

កសិករវាលស្មោង អនុវត្តពហុវប្បកម្មប្រពៃណី ។ ស្រីៗមានការងារច្រើន ដូចជា ដំណាំច្បារជុំវិញផ្ទះ ( បន្លែ និងឈើហូបផ្លែ) ដាំចញ្ចាតិ ( មីយេ ស័រកូ ) ចម្អិនអាហារ រកទឹកនិងអុស ។ ប្រុសៗបើមិនទៅចម្ការឬបរបាញ់ទេ តែងជជែកគ្នាលេងក្រោមដើមឈើ ។ គេក៏ជាចរកជនចិញ្ចឹមសត្វដែរ ។ គេប្រើចបក្នុងការដាំដុះ ។ កសិកម្មបែបនេះ មិនអាចចិញ្ចឹមប្រជាជនដ៏ច្រើនបានទេ ។ ដូចនេះស្បៀងនៅតែជាបញ្ហាចំពោះមុខដែលត្រូវដោះស្រាយ ។

## ១. ជីវភាពប្រជាជនតំបន់វាលលំហក្តៅ និងតំបន់ប៉ូល

ពិភពទាំងពីរ មានលក្ខណៈអាកាសធាតុដូចគ្នាស្រឡះ មានមនុស្សរស់នៅតិចតួចដូចគ្នា មានរបៀបរបបរស់នៅខុសគ្នា និងទទួលបានកំណែប្រែជីវភាពផ្សេងៗគ្នា ។

អ្នកស្រុកពិភពគ្មានទឹក ជាចរកជនចិញ្ចឹមសត្វ ជាចរកជនដឹកជញ្ជូនអីវ៉ាន់តាមសត្វអូដ្ឋ និងជាកសិករក្នុងអូអាស៊ីស ។ ការដឹកជញ្ជូនដោយសត្វអូដ្ឋត្រូវជំនួសដោយរថយន្ត រថភ្លើង និងយន្តហោះ ។ ការបញ្ចូលទឹកតាមបែបទំនើបបានធ្វើឱ្យអូអាស៊ីសមានការរីកចម្រើនខ្លាំង ។ សកម្មភាពផ្សេងៗទៀតមានអាជីវកម្មរ៉ែនិងទេសចរណ៍វាលខ្សាច់ ។ តំបន់វាលលំហក្តៅមាន ទីក្រុងសំខាន់ជាច្រើន ខ្លះជាទីក្រុងអូអាស៊ីស ខ្លះទៀតជាទីក្រុងរ៉ែ ។

ពីដើមអ្នកស្រុកពិភពទឹកកក រស់នៅដោយរបរនេសាទនិងប្រមាញ់តាមបែបប្រពៃណីនិងជាចរកជនចិញ្ចឹមសត្វផងដែរ ។ ក្រោយការមកដល់នៃពួកអឺរ៉ុប របៀបរស់នៅរបស់ពួកអ៊ីនុីត្រូវបានផ្លាស់ប្តូរទាំងស្រុង ។ ភាគច្រើននៃពួកអ៊ីនុីរស់នៅតាមបែបទំនើបជានិសិន្នជន ។ ទីក្រុងថ្មីៗ ជាច្រើនត្រូវបានបង្កើតឡើង ហើយទាក់ទងគ្នាដោយជើងយន្តហោះ រថភ្លើង និងរថយន្ត ។

***សន្និដ្ឋាន*** : អាកាសធាតុត្រូពិចមូសុងបង្កលក្ខណៈងាយស្រួលក្នុងការផលិតស្បៀងអាហារចិញ្ចឹមប្រជាជនជាងតំបន់ផ្សេងៗទៀត ។ អាស្រ័យហេតុដូច្នេះហើយ បានជា អាស៊ីមូសុងក្លាយទៅជាបណ្តុំប្រជាជនមួយដ៏ធំបំផុតក្នុងលោក ។ អាកាសធាតុតំបន់អាម៉ាសូនី តំបន់វាលលំហខ្សាច់ និងតំបន់ប៉ូលមិនសូវអនុគ្រោះដល់ការរស់នៅរបស់ប្រជាជនទេ ។ តំបន់អាម៉ាសូនី ប្រេស៊ីល មានមនុស្សចូលទៅរស់នៅកាន់តែច្រើនឡើងៗ ដោយសារផែនការអភិវឌ្ឍសេដ្ឋកិច្ច ដែលជាហេតុនាំឱ្យព្រៃឈើបាត់បង់ទៅយ៉ាងឆាប់រហ័ស ។ ចំណែកជីវភាពប្រជាជន តំបន់វាលលំហត្រជាក់ត្រូវបានកែប្រែដោយសារឥទ្ធិពលវប្បធម៌អឺរ៉ុបនិងគោលនយោបាយរបស់ពួកសូវៀត ។ រីឯនៅវាលលំហក្តៅវិញ ជីវភាពប្រជាជនត្រូវបានកែលម្អ ក៏ដោយសារការអភិវឌ្ឍសេដ្ឋកិច្ច ដូចជាផ្នែកគមនាគមន៍ ( រថយន្ត រថភ្លើង យន្តហោះ) ផ្នែកអាជីវកម្មរ៉ែ(អ៊ីដ្រូកាបួ ផូស្វាត ...) ផ្នែកកសិកម្ម(ការបញ្ចូលទឹកដោយប្រើសម្ពាធ) ។

## មេរៀនសង្ខេប

- កោះជ្វានិងអាម៉ាសូនី ជាតំបន់ស្ថិតនៅក្រោមឥទ្ធិពលអាកាសធាតុអេក្វាទ័រដូចគ្នា ។ អ្នកស្រុកកោះជ្វាអនុវត្តដំណាំអតិផល ដែលអាចបំពេញតម្រូវការរបស់ប្រជាជនបានគ្រប់គ្រាន់ ។ ចំណែកប្រជាជននៅអាម៉ាសូនីរស់នៅលំបាក បេះផ្លែឈើ បរបាញ់សត្វ នេសាទ និងធ្វើចម្ការព្រៃដុត ។
- ចំណែកកសិករអាស៊ីមូសុងអនុវត្តវិធីដាំដុះ មានដំណាំយថាផលនិងដំណាំអតិផល ហើយគ្រោះទុរ្ភិក្សលែងកើតមានទៀតហើយ ។ កសិករវាលស្មោងអនុវត្តពហុវប្បកម្មប្រពៃណី កសិកម្មបែបនេះ មិនអាចចិញ្ចឹមប្រជាជនដ៏ច្រើនបានទេ ។ រីឯអ្នកស្រុកពិភពគ្មានទឹក ជានិសិទ្ធជនចិញ្ចឹមសត្វ និងជាចរកជនក្នុងអាស៊ីស ។ ឯអ្នកស្រុកពិភពទឹកកក រស់នៅដោយរបរនេសាទនិងប្រមាញ់ ។ក្រោយមករបៀបរបបនេះត្រូវផ្លាស់ប្តូរទាំងស្រុង ។

## ? សំណួរ

1. កោះជ្វា និងអាម៉ាសូនីស្ថិតក្នុងតំបន់អាកាសធាតុណា ?
2. តើអ្នកស្រុកកោះជ្វា អ្នកស្រុកអាម៉ាសូនីមានរបៀបរបបរស់នៅដូចម្តេច ?
3. អាស៊ីមូសុង និងវាលស្មោង ស្ថិតក្នុងតំបន់អាកាសធាតុណា ?
4. តើកសិករអាស៊ីមូសុងមានជីវភាពរស់នៅដូចម្តេច ? ចុះអ្នកវាលស្មោងវិញ ?
5. តើតំបន់វាលលំហក្តៅ និងតំបន់វាលលំហត្រជាក់មានមនុស្សរស់នៅច្រើនដែរឬទេ ? ហើយពួកគេរស់នៅដោយរបៀបណា ?
6. តើជីវភាពប្រជាជនក្នុងតំបន់នីមួយៗបានទទួលការផ្លាស់ប្តូរដែរឬទេ ? ចូរពន្យល់ ។
7. ចូររៀបពាក្យខាងក្រោមឱ្យទៅជាល្បះមួយមានន័យត្រឹមត្រូវ ៖

   កំណើន ទម្ងះ មូលហេតុ ព្រៃអាម៉ាសូនី ប្រជាជន ផ្លូវ ជា ការបើក នៃ មួយ ។

*ពន្យល់ពាក្យ*

ពិភពគ្មានទឹក : ពាក្យប្រើសម្គាល់តំបន់វាលលំហខ្សាច់ ។

ពិភពទឹកកក : ពាក្យប្រើសម្គាល់តំបន់ប៉ូលទាំងពីរ ។

អរិយធម៌ស្រូវ : ពាក្យប្រើសម្គាល់អរិយធម៌តំបន់អាស៊ីអាគ្នេយ៍ ដែលជាតំបន់អនុគ្រោះខ្លាំងដល់ដំណាំស្រូវ ( អាហារចាំបាច់អាចចិញ្ចឹមប្រជាជនបានជាងពីរពាន់លាននាក់)

## ? សំណួរជំពូក3

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវតែមួយគត់ ៖

1. តំបន់ដែលគ្មានសិសិររដូវគឺ

☐ក. តំបន់អាកទិច ☐ខ. តំបន់អង់តាកទិច

☐គ. តំបន់ត្រជាក់បង្គួរ ☐ឃ. តំបន់ត្រូពិច

2. តំបន់ដែលមានដំណុះប្រជាជនខ្ពស់គឺ :

☐ក. អាស៊ីមូសុង ☐ខ. វាលស្មៅង ☐គ. អាម៉ាសូនី ☐ឃ. អ្វាស៊ីស ។

II ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

1. អ្នកស្រុកកោះជ្វាភាគច្រើនមានដីស្រែទំហំតូចជាងមួយហិកតា តែអាចផលិតស្រូវសម្រាប់ . . . បានគ្រប់គ្រាន់ ។

2. ជីវភាពប្រជាជនពិភពគ្មានទឹកនិងពិភពទឹកកក មានកំណែប្រែច្រើនដោយសារ . . . . . . . នៃបច្ចេកទេសនិងបច្ចេកវិទ្យាទំនើប ។

III. ចូរផ្គូផ្គងផ្នែក A និងB រួចសរសេរចម្លើយក្នុងផ្នែកC ឱ្យបានត្រឹមត្រូវ ៖

| A ( តំបន់) | B ( បាតុភូតធម្មជាតិ) | C ( ចម្លើយ) |
|---|---|---|
| 1. តំបន់អេក្វាទ័រ<br>2. តំបន់អាស៊ីមូសុង<br>3. តំបន់អ្វាស៊ីស | ក. មានភ្លៀងធ្លាក់តិចជាង 150មម ។<br>ខ. មានភ្លៀងធ្លាក់ស្ទើររាល់ថ្ងៃ ។<br>គ. មានព្រះអាទិត្យរះនៅឯជើងមេឃជាច្រើនខែ ។<br>ឃ. មានរដូវពីរ គឺប្រាំងនិងវស្សា ។ | 1. ⟶<br>2. ⟶<br>3. ⟶ |

IV ចូរឆ្លើយសំណួរខាងក្រោម ៖

1. តើប្រទេសកម្ពុជាស្ថិតក្នុងមណ្ឌលអាកាសធាតុណា ? តើមណ្ឌលអាកាសធាតុនោះមានឥទ្ធិពលយ៉ាងណាខ្លះ មកលើជីវភាពប្រជាជនយើង ?

2. តើការអនុវត្តកម្មវិធីនិគមកម្មតំបន់អាម៉ាសូនីរបស់រដ្ឋាភិបាលប្រេស៊ីលនាំមកនូវផលវិបាកអ្វីខ្លះ ? ចូរពន្យល់ ។

3. ចូរនិយាយពីជីវភាពទំនើបរបស់ប្រជាជនតំបន់អាកទិច ។

# ជំពូកទី 4 តើមនុស្សលើភពផែនដីរស់នៅទីណាខ្លះ

*ប្រជាជនតាមវិថីមួយនៃទីក្រុងតូក្យូ ( ជប៉ុន )*




បច្ចុប្បន្ននេះ(ឆ្នាំ2008) ភពផែនដីយើងមានមនុស្សរស់នៅចំនួន 6 708 700 100 នាក់ ។ តើមនុស្សទាំងនោះរស់នៅទីណាខ្លះ ? ហេតុអ្វី ?

តទៅនេះ យើងនឹងលើកយកបញ្ហាកំណើនប្រជាជន របាយប្រជាជន និងវិសមភាពនៃរបាយប្រជាជនមកសិក្សា ។

មេរៀនទី

# 1 ប្រជាជនពិភពលោក

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់បានពីកំណើនប្រជាជនពិភពលោក
- ❑ ពន្យល់ពីបញ្ហាកំណើននេះ និងបញ្ហាកំណើនប្រជាជនកម្ពុជាផងដែរ ។

ប្រជាជនពិភពលោកកើនឡើងយ៉ាងឆាប់រហ័ស ។ តើកំណើននេះមានរបាយស្មើគ្នាដែរឬទេ ?

## 1. កំណើនប្រជាជនពិភពលោក

រហូតមកដល់សតវត្សទី 18 ប្រជាជនពិភពលោកមានកំណើនតិចនៅឡើយ : មរណភាពខ្ពស់បានកំណត់កំណើនមនុស្សនាអំឡុងពេលនោះ ។ នៅដើមគ្រិស្តសករាជ ប្រជាជនពិភពលោកមានប្រមាណពី 250 ទៅ 300 លាននាក់ ។ ចំនួននេះកើនដល់ 500 លាននាក់នៅឆ្នាំ 1650 និង 1 000 លាននាក់នៅឆ្នាំ 820 ។




*ក្រាបបង្ហាញចំនួនប្រជាជនពិភពលោក*

ប្រជាជនពិភពលោកកើនឡើងយ៉ាងលឿននៅសតវត្សទី 20 : 2 ពាន់លាននាក់ (1920) 3 ពាន់លាននាក់ (1960) 5.7 ពាន់លាននាក់ (1995) 6.3 ពាន់លាននាក់ (2003) និង 6.708 ពាន់លាននាក់ (2008) ។

ក្នុងមួយឆ្នាំៗ ប្រជាជនពិភពលោកកើនបានប្រមាណ 95 លាននាក់ ។ បាតុភូតនេះ នាំឱ្យមានក្ដីព្រួយបារម្ភ ចំពោះការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចពិភពលោកនាពេលបច្ចុប្បន្ននិងទៅអនាគត ដូចជាបញ្ហាស្បៀង លំនៅឋាន សុខភាព ការអប់រំ ។

## 2. នៅបណ្ដាប្រទេសលោកខាងត្បូង

នៅទ្វីបអាហ្វ្រិក និងនៅប្រទេសខ្លះនៃទ្វីបអាស៊ី និងអាមេរិកឡាទីន ចំនួនប្រជាជនកើនខ្លាំងណាស់ព្រោះអត្រាជាតិប្រមាណមានច្រើនជាងអត្រាមរណប្រមាណ ។


គ្រួសារខ្មែរមានកូនបួននាក់

លទ្ធភាពបង្កកំណើតរបស់ស្ត្រីខ្ពស់ ប្រាំនាក់ជាមធ្យមនៅទ្វីបអាហ្វ្រិក ប្រហាក់ប្រហែលគ្នានិងនៅកម្ពុជាដែរ ។ គូស្រករយល់ថា កំណើតកូនជាអំណោយពីធម្មជាតិឬព្រះជាម្ចាស់ ហើយពួកគេក៏មិនចង់ប្រឆាំងនឹងកំណើតកូនដែរ ។ កូនច្រើនជាសញ្ញានៃភាពខ្លាំងរបស់គ្រួសារ ។ កូនៗមិនមែនជាបន្ទុកថវិកាអ្វីធ្ងន់ធ្ងរទេ តែជាកម្លាំងពលកម្មជួយដល់គ្រួសារឬក៏ជាប្រភពចំណូលប្រាក់កាសដ៏សំខាន់មួយ ។ ម្យ៉ោះហើយមធ្យោបាយប្រឆាំងកំណើនជ្រាបចូលតិចតួចណាស់ ... ។ ការយល់បែបនេះធ្វើឱ្យគ្រួសារមានកូនច្រើន ដែលចោទជាបញ្ហាធ្ងន់ធ្ងរដល់សង្គម និងសេដ្ឋកិច្ចនាបច្ចុប្បន្ន និងទៅអនាគត ។

អត្រាមរណប្រមាណមានកម្រិតទាប ដោយសារកំណែលម្អផ្នែកអនាម័យ យុទ្ធនាការចាក់ថ្នាំការពារនិងគុណភាពអាហារ ។

## 3. បណ្ដាប្រទេសលោកខាងជើង

នៅទ្វីបអាមេរិកខាងជើង អឺរ៉ុប ជប៉ុន សិង្ហបុរី អូស្ត្រាលី ...កំណើនប្រជាជនមានកម្រិតទាបឬទាបណាស់ ដោយសារអត្រាជាតិប្រមាណសឹងតែស្មើនឹងអត្រាមរណប្រមាណ ។

លទ្ធភាពបង្កកំណើតរបស់ស្ត្រីមានកម្រិតទាប ។ គ្រួសារមានកូនមួយឬពីរនាក់ប៉ុណ្ណោះព្រោះស្ត្រីមានទំនោរចូលរួមច្រើនក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គម ។ គេគ្មានជំនឿថា កូនជាអំណោយរបស់ព្រះជាម្ចាស់អ្វីនោះទេ ហើយមធ្យោបាយប្រឆាំងកំណើតក៏ត្រូវទទួលយកបានដោយងាយ ។ ម្យ៉ាងទៀតគូស្វាមីភរិយា ស្ម័គ្រចិត្តទាំងអស់គ្នាកម្រិតចំនួនកូនឱ្យបានតិច ដើម្បីងាយស្រួលលើកកម្ពស់ជីវភាពគ្រួសារ ។



*គ្រួសារជប៉ុនមានកូនពីរនាក់*

អត្រាមរណប្រមាណមានកម្រិតទាបណាស់ ទាបជាងអត្រាជាតិប្រមាណបន្តិច ។ នៅក្នុងបណ្ដាប្រទេសទាំងនោះ សង្ឃឹមរស់ពីកំណើតមានដល់ទៅ 70 ឬ 80 ឆ្នាំ ។

***សន្និដ្ឋាន :*** ប្រជាជនពិភពលោកបានកើនឡើងយ៉ាងរហ័សចាប់ពីសតវត្សទី 20 មក ។ កំណើនបែបនេះ នាំមកនូវក្ដីព្រួយបារម្ភច្រើន ចំពោះអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចពិភពលោក ។ ប្រជាជនប្រទេសលោកខាងជើង ដែលមានការរីកចម្រើនខ្ពស់ ស្ម័គ្រចិត្តកម្រិតចំនួនកូន ដើម្បីងាយស្រួលលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ ។ ចំណែកនៅប្រទេសលោកខាងត្បូងវិញ ប្រការសំខាន់ គឺធ្វើយ៉ាងណាឱ្យប្រជាជនយល់ច្បាស់ពីផលលំបាកនៃការមានកូនច្រើន និងស្ម័គ្រចិត្តកម្រិតចំនួនកូន ដើម្បីលើកស្ទួយសេដ្ឋកិច្ចគ្រួសាររួមចំណែកអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិរៀងៗខ្លួន ។

| អត្រាកំណើនធម្មជាតិ = អត្រាជាតិប្រមាណ − អត្រាមរណប្រមាណ |
|---|

## មេរៀនសង្ខេប

- ប្រជាជនពិភពលោកបានកើនយ៉ាងលឿននៅសតវត្សទី 20 ។ បាតុភូតនេះ ធ្វើឱ្យមានក្ដីព្រួយបារម្ភចំពោះបញ្ហាស្បៀង លំនៅឋាន សុខភាព ការអប់រំ ... ។
- នៅបណ្ដាប្រទេសលោកខាងត្បូង ដែលមានសេដ្ឋកិច្ចអន់ថយមានអត្រាកំណើនប្រជាជនខ្ពស់ ។ ចំណែកនៅបណ្ដាប្រទេសលោកខាងជើង ដែលមានឿនសេដ្ឋកិច្ចរីកចម្រើនកំណើនប្រជាជនមានកម្រិតទាប ដែលអាចឱ្យស្ត្រីចូលរួមសកម្មភាពសេដ្ឋកិច្ចនិងសង្គមបានច្រើន ។

## ? សំណួរ

1. តើប្រជាជនពិភពលោកមានកំណើនដូចម្ដេច ? ចូរពន្យល់ ។
2. តើប្រទេសលោកខាងត្បូង មានកំណើនប្រជាជនបែបណា ? ចូរពន្យល់ ។
3. តើប្រទេសលោកខាងជើង មានកំណើនប្រជាជនបែបណាដែរ ? ចូរពន្យល់ ។
4. បើប្រជាជនពិភពលោក កើនឡើងឥតឈប់ឈរយ៉ាងនេះ តើអ្នកអាចរំពឹងគិតថានឹងមានបញ្ហាអ្វីខ្លះដែលកើតឡើង ? ហើយតើគួរដោះស្រាយដោយរបៀបណា ?
5. តើកំណើនខ្ពស់នៃប្រជាជន នាំមកនូវផលប៉ះពាល់អ្វីខ្លះដល់បរិស្ថានធម្មជាតិ សង្គម និងសេដ្ឋកិច្ចជាតិនីមួយៗ ?
6. ហេតុអ្វីបានជាប្រជាជនពិភពលោកកើនរហ័សនៅសតវត្សទី20 ?
7. អ្វីទៅដែលហៅថាលោកខាងត្បូង ? ហេតុអ្វីបានជានៅប្រទេសលោកខាងត្បូង កំណើនប្រជាជនមានកម្រិតខ្ពស់ ?
8. អ្វីទៅដែលហៅថាលោកខាងជើង ? ហេតុអ្វីបានជានៅប្រទេសលោកខាងជើង កំណើនប្រជាជនមានកម្រិតទាប ?

*ពន្យល់ពាក្យ*

លោកខាងត្បូង : ពាក្យប្រើសម្រាប់សម្គាល់ប្រទេសទាំងឡាយ ដែលមានឡើនសេដ្ឋកិច្ចអន់ថយ ។

លោកខាងជើង : ពាក្យប្រើសម្រាប់សម្គាល់ប្រទេសទាំងឡាយ ដែលមានឡើនសេដ្ឋកិច្ចរីកចម្រើន ។

អាមេរិកឡាទីន : ផ្នែកមួយសំខាន់នៃទ្វីបអាមេរិក ដែលលាតសន្ធឹងពីប្រទេសម៉ិកស៊ិករហូតដល់ជ្រោយហ៊ន ។

លទ្ធភាពបង្កកំណើត : ភាពដែលអាចបង្កើតកូនបានរបស់ស្ត្រីភេទក្នុងជំណាក់បន្តពូជ ។

សង្ឃឹមរស់ពីកំណើត : រយៈពេលមធ្យមរបស់ប្រជាជន ដែលអាចរស់រានមានជីវិតបាន ។

អត្រាជាតិប្រមាណ : ចំនួនទារកដែលកើតគិតក្នុងចំណោមប្រជាជនចំនួនមួយពាន់នាក់ក្នុងរយៈពេលមួយឆ្នាំ( គិតជាភាគពាន់) ។

អត្រាមរណប្រមាណ : ចំនួនមនុស្សដែលស្លាប់គិតក្នុងចំណោមប្រជាជនចំនួនមួយពាន់នាក់ក្នុងរយៈពេលមួយឆ្នាំ( គិតជាភាគពាន់) ។

អត្រាកំណើនប្រជាជន : ជាផលសងរវាងអត្រាជាតិប្រមាណ និងអត្រាមរណប្រមាណគិតជាភាគរយ ។

ក្រាប : ជាគំនូសតាងអ្វីមួយ ដែលមានលក្ខណៈជាខ្សែឬជាសសរ ។

មេរៀនទី

# 2 របាយប្រជាជនពិភពលោក

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់បានពីរបាយប្រជាជនពិភពលោក
- ពន្យល់បានពីកត្តាកំណត់នៃដំណុះប្រជាជនលើភពផែនដី ។

នៅលើភពផែនដី មានមនុស្សរស់នៅជាច្រើនលានឆ្នាំមកហើយ ។ នៅឆ្នាំ2008នេះ ប្រជាជនពិភពលោកមានចំនួនប្រហែល 6,708 ពាន់លាននាក់ គិតជាដង់ស៊ីតេមធ្យមមាន 51 នាក់ក្នុង $1km^2$ ។ តើប្រជាជនទាំងនោះរស់នៅទីណាខ្លះ ? តើតំបន់ណាខ្លះ ដែលមានមនុស្សរស់នៅកុះករ ? តើតំបន់ណាខ្លះ ដែលមានមនុស្សរស់នៅមធ្យម ? តើតំបន់ណាខ្លះដែលខ្សត់មនុស្ស ?

## 1. កំណុំធំៗនៃដំណុះប្រជាជន




• ចំណុចនីមួយៗតាង 500 000 នាក់ ◯ កំណុំរង ◯ កំណុំសំខាន់ៗ

*ផែនទីបង្ហាញពីកំណុំនៃដំណុះប្រជាជន (2004)*

ប្រជាជនពិភពលោកចំនួនពាក់កណ្តាលរស់នៅពពាក់ពពួនក្នុងតំណុំធំៗទាំងបួននៃតំណុំប្រជាជន ដូចជា អាស៊ីបូព៌ា (1 500 លាននាក់) អាស៊ីទក្សិណ (1 300 លាននាក់) អឺរ៉ុប (700 លាននាក់) ។

ក្រៅពីនេះ នៅមានតំណុំរងនៃដំណុះប្រជាជនផ្សេងៗទៀត ដូចជា អាស៊ីអាគ្នេយ៍ តំបន់ឈូងគីនេ ភាគអាគ្នេយ៍ប្រេស៊ីល តំបន់ក្បែរបូព៌ា និងមជ្ឈិមបូព៌ា អាមេរិកកណ្តាល ភាគខាងកើតអាហ្វ្រិក (តំបន់បឹងធំ) ។

## 2. តំបន់ខ្សត់មនុស្ស



តំបន់ខ្សត់មនុស្ស : សាហារ៉ា

គេអាចធ្វើដំណើរជាច្រើនថ្ងៃនៅតំបន់មួយចំនួនលើផ្ទៃផែនដី ដោយមិនបានជួបមនុស្សម្នាក់ទាល់តែសោះ គឺជាតំបន់វាលលំហាគ្មានមនុស្សរស់នៅ ។

វាលលំហាធំៗបំផុតស្ថិតនៅតំបន់ស្ងួតហែង ដូចជា សាហារ៉ាជាដើម ។ នៅតំបន់ប៉ូលដង់ស៊ីតេប្រជាជន គឺមានកម្រិតទាបណាស់ដែរ ។ នៅអាមេរិកខាងត្បូង ព្រៃអាម៉ាសូនីមានមនុស្សរស់នៅតិចតួច ជាក្រុមតូចៗ ។

ជាទូទៅ តំបន់ត្រជាក់ឬស្ងួតហែង និងតំបន់ភ្នំមានមនុស្សរស់នៅតិចតួច ។ អាកាសធាតុនិងសណ្ឋានដី ហាក់ដូចជាមានតួនាទីសំខាន់ក្នុងដំណុះប្រជាជនលើភពផែនដី ។

## 3. មជ្ឈដ្ឋានមិនអនុគ្រោះដល់ដំណុះប្រជាជន

ភាពត្រជាក់ហួសហេតុ ជាអចិន្ត្រៃយ៍នៃមជ្ឈដ្ឋានប៉ូល ភាពខ្វះទឹកនៅតំបន់វាលលំហា តំហាយចុះសីតុណ្ហភាព និងអុកស៊ីសែននៅតំបន់ភ្នំខ្ពស់ៗបង្កើតបានជាលក្ខខណ្ឌរស់នៅដ៏លំបាកលំបិនបំផុត ។

នៅមជ្ឈដ្ឋានទាំងនោះ មនុស្សមិនអាចដាំដុះបានទេ ។ ដំណុះប្រជាជនខ្សោយរួមមកនៅត្រឹមក្រុមតូចៗ រស់នៅឯកោស្ទើរមើលមិនឃើញ កណ្តាលមហាលំហាដ៏ធំធេង ។ ភាពមិនអនុគ្រោះនៃធម្មជាតិ ជាកត្តាកំណត់ការកាន់កាប់លំហាផែនដី ។




*អវិភាពធម្មជាតិ*




*មិត្តភាពធម្មជាតិ*

## 4. មជ្ឈដ្ឋានអនុគ្រោះដល់ដំណុះប្រជាជន

កំណុំធំៗនៃដំណុះប្រជាជនទាំងអស់កើតឡើងដោយសារលក្ខខណ្ឌអាកាសធាតុផ្ដល់អំណោយផលដល់សកម្មភាពមនុស្ស ។ កាលណាក្ដៅនិងសំណើម អាចឱ្យគេដាំដុះបាន នោះប្រជាជនតែងប្រមូលផ្ដុំគ្នារស់នៅយ៉ាងកុះករ ។

គេក៏សង្កេតឃើញផងដែរថា មនុស្សប្រមូលផ្ដុំគ្នារស់នៅតាមបណ្ដោយឆ្នេរសមុទ្រតាមវាលទំនាបដីធំធេង និងជ្រលងធំៗ ។សណ្ឋានដីដីមានជីជាតិទាំងនេះ បង្កលក្ខណៈងាយស្រួលដល់ដំណុះប្រជាជន ។

## 5. ករណីដោយឡែកនៃដំណុះប្រជាជន

តើកត្តាអាកាសធាតុ និងសណ្ឋានដី អាចពន្យល់បានគ្រប់គ្រាន់ពីរបាយប្រជាជននៅលើផែនដីដែរឬទេ ? តាមពិតទៅ នៅមានករណីខ្លះហាក់ដូចជាផ្ទុយពីវិធានទូទៅនេះ ។

តំបន់ភ្នំមិនមែនសុទ្ធតែគ្មានមនុស្សរស់នៅនោះទេ ។ នៅជួរភ្នំអង់ មានពួកអ្នកស្រុកដើម ( ពួកឥណ្ឌា)រស់នៅត្រង់រយៈកម្ពស់ខ្ពស់ ។ នៅកណ្ដាលភ្នំអាល់ មានទីក្រុងជាច្រើនបានបង្ហាញរូបរាងឡើង ។

គេបានសង្កេតឃើញទៀតថា កោះភ្នំពីរនៅក្បែរគ្នាមានដំណុះប្រជាជនផ្ទុយគ្នា ៖

- កោះជ្វាមានដង់ស៊ីតេប្រជាជនខ្ពស់ណាស់ ( 1 026 នាក់ / $km^2$ ឆ្នាំ2006 ) ។
- ចំណែកកោះបរនេអូស្ទើរតែគ្មានប្រជាជនរស់នៅ ។

***សន្និដ្ឋាន*** : របាយប្រជាជននៅលើភពផែនដីមិនស្មើគ្នាទេ ។ នៅលើផ្ទៃផែនដីជិតពាក់កណ្ដាលមានក្រុមមនុស្សតិចតួចរស់នៅឯកោ ។ ផ្ទុយទៅវិញមនុស្សលោកចំនួនពាក់កណ្ដាលប្រជ្រៀតគ្នារស់នៅក្នុងកំណុំសំខាន់ៗទាំងបួននៃដំណុះប្រជាជន ។ អរិភាពនិងមិត្តភាពនៃធម្មជាតិ ចំពោះដំណុះប្រជាជនពន្យល់បានមួយភាគធំ ពីរបាយប្រជាជនក្នុងពិភពលោក ។ តែក៏អាចមានករណីដោយឡែកនៃដំណុះប្រជាជនផងដែរ ។ ដូចនេះ មានតែការសិក្សាមេរៀនភូមិវិទ្យាកន្លងមកនេះទេ ដែលអាចជួយបកស្រាយបញ្ហានេះបាន ។

## មេរៀនសង្ខេប

- នៅមជ្ឈដ្ឋានប៉ូល តំបន់វាលលំហ និងតំបន់ភ្នំខ្ពស់ៗមិនអនុគ្រោះដល់ដំណុះប្រជាជនឡើយ ។ គេសង្កេតឃើញមនុស្សប្រមូលផ្ដុំគ្នារស់នៅតាមបណ្ដោយឆ្នេរសមុទ្រ តាមវាលទំនាប និងតាមជ្រលងធំៗ ព្រោះដីមានជីជាតិ បង្កលក្ខណៈងាយស្រួលដល់ដំណុះប្រជាជន ។
- របាយប្រជាជនពិភពលោកមិនស្មើគ្នាទេ ។ ដង់ស៊ីតេប្រជាជនខ្ពស់បំផុតមាននៅអឌ្ឍគោលខាងជើង ។ ចំណែកនៅតំបន់ត្រជាក់ តំបន់ស្ងួតហែង និងតំបន់ភ្នំមានមនុស្សរស់នៅតិចតួច ។

## ? សំណួរ

1. តើកំណុំធំៗនៃដំណុះប្រជាជនពិភពលោកមាននៅទីណាខ្លះ ?
2. ហេតុអ្វីបានជាមានមនុស្សរស់នៅច្រើននៅអឌ្ឍគោលខាងជើង ?
3. " ប្រវត្តិសាស្ត្រ និងសកម្មភាពសេដ្ឋកិច្ច ជាកត្តាសំខាន់ពីរទៀតនៃដំណុះប្រជាជនពិភពលោក " ។ ចូរពន្យល់ ។
4. តើលក្ខខណ្ឌធម្មជាតិបង្កភាពអនុគ្រោះ និងការលំបាកដល់ការរស់នៅរបស់មនុស្សមានអ្វីខ្លះ ?
5. តើមជ្ឈដ្ឋានធម្មជាតិបែបណាខ្លះ ដែលបង្កើតមិត្តភាពនិងអរិភាពចំពោះដំណុះប្រជាជន ?

***ពន្យល់ពាក្យ***

កំណុំប្រជាជន : តំបន់ដែលមានដង់ស៊ីតេខ្ពស់ខ្លាំង តំបន់មួយនៃពិភពលោកដែលប្រជាជនកុំគ្នារស់នៅយ៉ាងកុះករ ។

ជួរភ្នំអង់ : ជួរភ្នំមួយនៅអាមេរិកខាងត្បូងលាតសន្ធឹងលើបណ្ដោយជិត 8 000 km ។

ជួរភ្នំអាល់ : ជួរភ្នំមួយនៅទ្វីបអឺរ៉ុបលាតសន្ធឹងលើបណ្ដោយជាង 1 000km ពីសមុទ្រមេឌីទែរ៉ាណេដល់ទីក្រុងវីយែន( ប្រទេសអូទ្រីស) ។

អ្នកស្រុកដើម : ក្រុមជនម្ចាស់ស្រុក ដែលរស់នៅលើទឹកដីមួយដ៏យូរលង់មកហើយ ។

## ? សំណួរជំពូក 4

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវតែមួយគត់**

1. លោកខាងជើងប្រើសម្រាប់សម្គាល់បណ្តាប្រទេស ៖

☐ក. ដែលមានល្បឿនសេដ្ឋកិច្ចរីកចម្រើន

☐ខ. ដែលមានល្បឿនសេដ្ឋកិច្ចអន់ថយ

☐គ. ដែលប្រកាន់យករបបមូលធននិយម

☐ឃ. ដែលប្រកាន់យករបបសង្គមនិយម ។

2. តំណុំប្រជាជនធំជាងគេបំផុតក្នុងលោកគឺ

☐ក. អាស៊ីទក្សិណ ☐ខ. អាស៊ីបូព៌ា

☐គ. អាស៊ីអាគ្នេយ៍ ☐ឃ. អឺរ៉ុប ។

**II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ**

1. ប្រជាជនពិភពលោកចំនួនបួនភាគប្រាំរស់នៅ . . . . . . . . . ។

2. ប្រជាជនពិភពលោកកើនយ៉ាងឆាប់រហ័សនៅសតវត្ស. . . . . . . . . ។

**III. ចូរផ្គូផ្គងផ្នែក A និងB រួចសរសេរចម្លើយក្នុងផ្នែកC ឱ្យបានត្រឹមត្រូវ**

| A ( តំបន់) | B ( ដំណាំអាហារចាំបាច់) | C ( ចម្លើយ) |
|---|---|---|
| 1 អាស៊ីមូសុង | ក. ស្រូវសាលី | 1. ⟶ |
| 2. អាហ្វ្រិក | ខ. មីល សរកូ | 2. ⟶ |
| 3 អឺរ៉ុប | គ. ពោត សណ្តែក | 3. ⟶ |
| | ឃ. ស្រូវ | |

**IV ចូរឆ្លើយសំណួរខាងក្រោម**

1. អ្វីទៅដែលហៅថា " លោកខាងត្បូង" ? ហេតុអ្វីបានជាលោកខាងត្បូងមានកំណើនប្រជាជនខ្ពស់ ?

2. នៅអន្តរគោលទាំងពីរ តើរបាយប្រជាជនមានលក្ខណៈដូចម្តេចខ្លះ ?

3. តើអ្វីខ្លះដែលជាអវិភាពធម្មជាតិនៃដំណុះប្រជាជនពិភពលោក ?